ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ប៊ូ មេង ៖ អ្នកនៅរស់ពីរបបខ្មែរក្រហមនៅមន្ទីរស-២១

◆ ការទទួលបាននូវយុត្តិធម៌ និង ការផ្សះផ្សានៅកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១២៥ ខែឧសភា ឆ្នាំ២០១០

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ១២៥ ខែឧសភា ឆ្នាំ២០១០

## មាតិកា

◆ប៊ូ ម៉េង ៖ អ្នកនៅរស់ជីវិតពីមន្ទីរស-២១ ............................... ១

**ផ្នែកឯកសារ**

◆វគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋាន នៅខេត្តកំពត ............................... ២

◆កុមារជនជាតិចាមក្នុងរបបខ្មែរក្រហម ............................... ៦

◆ជាប់គុកដោយសារបដិសេធនឹងអន្ដការ ............................... ៨

**ផ្នែកប្រវត្តិសាស្ដ្រនិងការស្រាវជ្រាវ**

◆រំឭកថ្ងៃចងចាំ ៖ មន្ទីរបូជនីយដ្ឋានវត្តស្លួនពេជ្រ ............................... ១០

◆ការជួបប្រជុំជាមួយអ្នកភូមិ ៖ កម្មាភិបាលខ្មែរក្រហមបាន ............................... ១២

◆គុកគ្រោចក្រោលរបស់ខ្មែរក្រហម ............................... ១៦

◆គេចពីការសម្លាប់របស់ខ្មែរក្រហម ............................... ១៨

◆សុក្រិត្យ ៖ ខ្មែរក្រហមអាក្រក់ផង ល្អផង ............................... ២០

◆ប៊ូ ម៉េង ៖ សៀវភៅដើម្បីការចងចាំ និង យុត្តិធម៌សង្គម ............................... ២៤

◆គម្រោងជួយជនរងគ្រោះ ៖ ការចូលរួមដ៏មានអត្ថន័យ ............................... ២៥

◆វេទិកាអ្នកភូមិនៅក្នុងខេត្តពោធិ៍សាត់ ៖ ប្រតិកម្មចំពោះការ ............................... ២៨

**ផ្នែកច្បាប់**

◆ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សានៅកម្ពុជា ............................... ៣២

**វេទិកាពិភាក្សាសាធារណៈ**

◆ការជួបជុំរបស់អ្នកយកព័ត៌មានក្នុងសម័យសង្គ្រាមនៅកម្ពុជា ............................... ៤៦

◆អ្នកសារព័ត៌មានដែលស្លាប់ក្នុងសម័យសង្គ្រាមនៅកម្ពុជា ............................... ៥១

◆ការជួបសំណេះសំណាលរវាងសហព្រះរាជអាជ្ញា ............................... ៥៤

◆ទស្សនៈទូទៅចំពោះការស្នើសុំឲ្យមានការផ្លាស់ប្ដូរ ............................... ៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ម្ដាយខ្ញុំក្នុងរបបខ្មែរក្រហម ............................... ៦០





ពិធីដង្ហែអដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅវត្តស្លួនពេជ្រ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ដ្រីនិងរដ្ឋមន្ដ្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាលេខនេះ ៖** ជា កល្យាណ, បាន ផល្លា, ស៊ីរី សាវីណា, ផេង ពង្សរ៉ាស៊ី, សើ សាយ្យាណា, គ្រី ស៊ុយហៀង, ម៉ារីឌីត ឌីន, ណាតាហ្សា បាច, ស៊ីម សុភ័ក្រ្ត គិត សេរី, អានទ្រូ ហុ.ដាយមេន, ខាល ដែលប៊ឺក, ឆាយ ឈុនលី **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែៈ** ជា ផល្លា, ទេស ម៉ារ៉ែម **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ីម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# ប៊ូ ម៉េង ៖ អ្នកនៅរស់ជីវិតពីមន្ទីរស-២១

## យុត្តិធម៌សម្រាប់ពេលអនាគត មិនមែនគ្រាន់តែសម្រាប់ជនរងគ្រោះប៉ុណ្ណោះទេ

***និពន្ធដោយ ៖ ហ៊ុយ វណ្ណៈ***

*អស់រយៈពេលជិតសាមសិបឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមដ៏ឃោរឃៅបានដួលរលំ អ្នករួចរស់ជីវិតម្នាក់ពីយន្តការនៃការធ្វើទារុណកម្មដ៏គ្មានមេត្តាបានងើបខ្លួនចេញពីប្រវត្តិសាស្ត្រហើយប្រកាសថា «ខ្ញុំមានជីវិតរស់នៅឡើយ» ។*

*ខ្មែរក្រហមបានឃុំឃាំងនិងធ្វើទារុណកម្មប្រជាជនកម្ពុជាចំនួនប្រមាណ១៤.០០០នាក់ នៅគុកទួលស្លែង ឬ «មន្ទីរស-២១» ។ ការឃុំឃាំងនៅមន្ទីរស-២១ គឺជាការកាត់ទោសប្រហារជីវិតដ៏ពិតប្រាកដមួយ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលអាចចេញមកក្រៅរួចរស់ជីវិត ។ ក្នុងចំណោមនោះក៏មាន ប៊ូ ម៉េង ម្នាក់ដែរ ដែលជាជាងគំនូរម្នាក់ ។ ជាច្រើនឆ្នាំបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម រឿងមួយដែលគួរឲ្យរន្ធត់ជាងគេនៅក្នុងប្រវត្តិសាស្ត្រ (១៩៧៥-១៩៧៩) ហើយជាងបីទសវត្សរ៍បន្ទាប់ពីមន្ទីរស-២១ បានដួលរលំ ប៊ូ ម៉េង ត្រូវបានគេជឿជាក់ថា បានស្លាប់បាត់ទៅហើយ ។ នៅក្នុងខែមករា ឆ្នាំ២០០២ កាសែតក្នុងស្រុកជាភាសាអង់គ្លេសមួយនៅក្នុងទីក្រុងភ្នំពេញបានរាយការណ៍ថា គាត់បានស្លាប់នៅក្នុងឆ្នាំ១៩៩៧ ឬ នៅក្នុងឆ្នាំ១៩៩៨ ហើយនៅក្នុងខែតុលា ឆ្នាំ២០០២ ទស្សនាវដ្ដីកម្ពុជាមួយ ដែលមានឈ្មោះថា «ទស្សនាវដ្ដីស្វែងរកការពិត» បានឃើញរូបថតមួយសន្លឹករបស់អ្នករួចរស់ជីវិតពីមន្ទីរស-២១ដែលប្រមូលបាននៅអតីតគុកទួលស្លែងនោះ បានរាយការណ៍ថា ប៊ូ ម៉េង «បាត់ខ្លួន» ។*

*ប៉ុន្តែ ប៊ូ ម៉េង នៅរស់ជីវិតយ៉ាងពិតប្រាកដ ។ ការដែលគាត់អាចរួចពីទីស្ថានដ៏ព្រៃផ្សៃមួយនេះគឺដោយសារតែគាត់មានជំនាញជាអ្នកគូរគំនូរ ។ នៅក្នុងអំឡុងពេលឃុំឃាំងខ្លួនរបស់គាត់នៅមន្ទីរស-២១ ប៊ូ ម៉េង ត្រូវបានខ្មែរក្រហមបង្ខំឲ្យគូររូបរបស់ប៉ុល ពត និងមេដឹកនាំកុម្មុយនីសផ្សេងៗទៀតក្នុងបំណងឃោសនានយោបាយ ។ ដោយសារតែជំនាញពិសេសរបស់គាត់ មេឃាតករនៅមន្ទីរស-២១បានទុកគាត់ឲ្យនៅរស់ជីវិត ។ ប៉ុន្តែ ប្រពន្ធរបស់ ប៊ូ ម៉េង ដែលមានឈ្មោះ ម៉ា យឿន ឬកូនប្រុសពីរនាក់របស់គាត់មិនមានវាសនារស់រានមានជីវិតឡើយ ។ ម៉ា យឿន ត្រូវទទួលរងនូវទារុណកម្ម ហើយត្រូវបានសម្លាប់នៅវាលពិឃាតជើងឯក ។ កូនរបស់ ប៊ូ ម៉េង ត្រូវស្លាប់ដោយអត់អាហារនៅកងកុមារ ។*



*រូបគំនូររបស់ ប៊ូ ម៉េង និងប្រពន្ធ នៅមន្ទីរស-២១*

*រឿងរ៉ាវរបស់ ប៊ូ ម៉េង គឺជាសាច់រឿងមួយក្នុងចំណោមរឿងរ៉ាវរាប់លានរបស់ប្រជាជនកម្ពុជាដែលទទួលរងនូវភាពទុក្ខវេទនា ការធ្វើទារុណកម្ម និងការជាប់ឃុំឃាំងក្នុងអំឡុងរបបព្រៃផ្សៃរបស់ខ្មែរក្រហម ។*

*សព្វថ្ងៃរឿងរ៉ាវរបស់ ប៊ូ ម៉េង បានក្លាយជារឿងរ៉ាវដ៏ពិសេសមួយ ហើយការចងចាំរបស់គាត់អាចប្រើប្រាស់ជាឧបករណ៍មួយក្នុងការស្វែងរកការពិតនិងយុត្តិធម៌ ។* **ឆាំង យុ**

# វគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋាន នៅខេត្តកំពត អំពី: “ការផ្ដល់វិធីសាស្ត្រទំនើបក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”

នៅព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ មជ្ឈមណ្ឌលឯកសារកម្ពុជា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត បានបើកវគ្គបណ្ដុះបណ្ដាលដល់គ្រូមូលដ្ឋានចំនួន៨៥នាក់ ស្ដីពីការផ្ដល់វិធីសាស្ត្រទំនើបថ្មីៗក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅសាលប្រជុំមន្ទីរអប់រំ ដោយមានការអញ្ជើញចូលរួមជាគណៈអធិបតីពីលោក តាក់ ហាប់ ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពត លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា សាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ និងគ្រូឧទ្ទេសថ្នាក់ជាតិនិងថ្នាក់ខេត្តមួយចំនួន មកពីខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពង់ចាម និងខេត្តកំពង់ធំ ។

លោក ផេង ពង្សរ៉ាស៊ី ប្រធានគម្រោងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងជាអ្នកសម្របសម្រួលក្នុងវគ្គបណ្ដុះបណ្ដាលនេះបានបញ្ជាក់ថា គោលបំណងសំខាន់នៃវគ្គបណ្ដុះបណ្ដាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺដើម្បីបង្កើតឲ្យមានការផ្សះផ្សាពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ និងដើម្បីអភិវឌ្ឍន៍សង្គមតាមរយៈការបំបាត់ចោលនូវភាពគុំកួន និងរើសអើង ។ បន្ទាប់មកលោកបានបង្ហាញរបាយការណ៍ស្ដីពីវគ្គបណ្ដុះបណ្ដាលដូចគ្នានេះដល់គ្រូឧទ្ទេសថ្នាក់ជាតិចំនួន២៤រូប និងគ្រូឧទ្ទេសថ្នាក់ខេត្តចំនួន១៨០រូបមកពីខេត្តគ្រប់ខេត្ត-ក្រុងទូទាំងប្រទេសកម្ពុជា ។

នៅក្នុងឆ្នាំ២០១០នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាលធំៗលើកទីពីររបស់ខ្លួន គឺវគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋាននៅទូទាំងប្រទេសចំនួន១.៦២៧រូប ហើយនេះគឺជាការចាប់ផ្ដើមដំបូងសម្រាប់វគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋានក្នុងខេត្តចំនួនបួនគឺ ខេត្តកំពត ព្រះសីហនុ ក្រចេះ និងស្ទឹងត្រែង ។ គ្រូមូលដ្ឋានដែលបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាចំនួន



សាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា ធ្វើបទបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលគ្រូមូលដ្ឋាននៅខេត្តកំពត



៨៥រូបមកពីខេត្តកំពត និងកែប បានមកជួបជុំគ្នាចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលប្រារព្ធធ្វើនៅខេត្តកំពតពីថ្ងៃទី៥-១១ ខែមេសា ឆ្នាំ២០១០ ដើម្បីក្រេបជញ្ជក់យកចំណេះដឹងថ្មីៗដែលផ្តល់ឲ្យដោយគ្រូឧទ្ទេសថ្នាក់ជាតិ និងថ្នាក់ខេត្តស្តីពីវិធីសាស្ត្រទំនើបថ្មីៗក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីចប់វគ្គបណ្តុះបណ្តាលនេះ គ្រូមូលដ្ឋានទាំងអស់នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ដែលផ្តល់ឲ្យដោយក្រសួងអប់រំ យុវជន និងកីឡា ។

វគ្គបណ្តុះបណ្តាលនេះនឹងផ្តល់ឲ្យលោកគ្រូអ្នកគ្រូនូវវិធីសាស្ត្របង្រៀនថ្មី ដែលមាននៅក្នុងសៀវភៅ "ណែនាំសម្រាប់គ្រូបង្រៀន" ជាស្នាដៃនិពន្ធដោយអ្នកនិពន្ធជនជាតិខ្មែរ និងអាមេរិក ដែលមានសញ្ញាបត្រជាន់ខ្ពស់ខាងអប់រំមកពីសហរដ្ឋអាមេរិក ។

លោកសាស្ត្រាចារ្យ សំបូរ ម៉ាណ្ណារ៉ា ធ្វើបទបង្ហាញពីការចងក្រងឯកសារប្រវត្តិសាស្ត្រ និង ស្រាវជ្រាវ ដោយបានលើកឡើងថា នៅក្នុងការបង្រៀន លោកគ្រូអ្នកគ្រូត្រូវរៀបចំឯកសារអានសៀវភៅ ពិចារណា និងប្រៀបធៀបប្រវត្តិសាស្ត្រ ។ ចំណែកនៅក្នុងបរិបទក្នុងការស្រាវជ្រាវ គ្រូត្រូវកំណត់ពីទំហំប្រធានបទ និងទិន្នន័យដែលត្រូវប្រមូល ។ លោក សំបូរ ម៉ាណ្ណារ៉ា បញ្ជាក់ថា វគ្គបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់សម្រាប់លោកគ្រូអ្នកគ្រូយកទៅអប់រំសិស្ស ជាពិសេសរវាងជនដៃដល់ និងជនរងគ្រោះឲ្យផ្សះផ្សាគ្នា ។

បន្ទាប់មកលោក គាក់ ហាប់ សម្តែងនូវទឹកចិត្តរីករាយដោយសារខេត្តរបស់លោកបានទទួលលោកគ្រូអ្នកគ្រូឧទ្ទេសថ្នាក់ខេត្ត ថ្នាក់ជាតិ និងបុគ្គលិកមជ្ឈមណ្ឌលកម្ពុជាមកបើកវគ្គបណ្តុះបណ្តាលលោកគ្រូអ្នកគ្រូប្រវត្តិវិទ្យានៅខេត្តកំពតនេះ ។ វិធីសាស្ត្រថ្មីនេះ លោកគ្រូអ្នកគ្រូអាចនឹងយកមកបញ្ចូលក្នុងវិធីសាស្ត្រដែលមានស្រាប់យកទៅបង្រៀន និងអាចឲ្យសិស្សរំពុកឡើងវិញពីរបបកម្ពុជាប្រជាធិបតេយ្យ ។

លោក គាក់ ហាប់ បញ្ជាក់ថា ប្រវត្តិវិទ្យាគឺជាវិទ្យាសាស្ត្របង្ហាញប្រាប់ការពិត ប៉ុន្តែ អាស្រ័យទៅលើអ្នកអនុវត្តនិងអ្នកដឹកនាំ ។ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះនឹងមិននាំឲ្យសិស្សមានការឈឺចាប់និងបង្កអស្ថិរភាពនៅក្នុងសង្គមកម្ពុជាទេ ប៉ុន្តែផ្ទុយទៅវិញ ដើម្បីឲ្យសិស្សនិងប្រជាជនយល់កាន់តែច្បាស់លាស់ថែមទៀត ។ លោកបានបន្តថា នៅសាលាចំណេះទូទៅមួយចំនួន លោកគ្រូអ្នកគ្រូមួយចំនួននៅតែមានការលំបាកក្នុងការការពន្យល់ឲ្យសិស្សជឿថា មានរបបខ្មែរក្រហម ប៉ុន្តែនៅពេលនេះដោយយោងតាមខ្លឹមសារ មេរៀនវិធីសាស្ត្របង្រៀនថ្មី និងឯកសារជាច្រើនដែលផ្តល់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើឲ្យសិស្សជឿ ។



លោក ឆាំង យុ និង លោក អេនឌ្រូ ខេលី ជួបជាមួយគ្រូមូលដ្ឋាននៅខេត្តកំពត

នៅចុងបញ្ចប់ លោក គាក់ ហាប់ បានផ្តាំផ្ញើលោកគ្រូអ្នកគ្រូទាំងអស់ដែលមកចូលរួមវគ្គបណ្តុះបណ្តាលឲ្យខិតខំយកចិត្តទុកដាក់ស្តាប់ និងរៀនសូត្រ ដើម្បីយកចំណេះដឹងទាំងនេះអប់រំសិស្សនៅតាមសាលារៀនៗខ្លួន បន្ទាប់មកលោកក៏ប្រកាសបើកវគ្គបណ្តុះបណ្តាល ។

**សោម ប៊ុនថន និង សេី សាយ្យាណា**

# វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានស្តីអំពីការប














# ង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ













# កុមារជនជាតិចាមក្នុងរបបខ្មែរក្រហម

ក្រោមការគ្រប់គ្រងពីឆ្នាំ(១៩៧៥-១៩៧៩) ខ្មែរក្រហមបានលុបបំបាត់ទំនៀមទម្លាប់ ប្រពៃណី និងបង្ខំឲ្យជនជាតិចិន, ចាម, វៀតណាម និងជនជាតិផ្សេងទៀត ធ្វើការងារស្ទើរគ្មានពេលសម្រាក ហើយថែមទាំងហាមឃាត់មិនឲ្យគោរពប្រណិប័តន៍សាសនាទៀត ។

ជាក់ស្តែង ប៉ូរហាន ជាអតីតកុមារអ៊ីស្លាមម្នាក់បានរៀបរាប់ថា គាត់កើតក្នុងគ្រួសារកសិករម្នាក់ និងជាកូនទីប្រាំមួយក្នុងចំណោមបងប្អូនប្រាំពីរនាក់ (ប្រុសប្រាំមួយនាក់ និងស្រីម្នាក់) ។ នៅឆ្នាំ១៩៧៤ ខ្មែរក្រហមក៏បានយកភូមិបាសែតជាសមរភូមិប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់ ។ ដោយសារតែសភាពការណ៍ប្របូកប្របល់បែបនេះ ប៉ូរហាន និងគ្រួសារត្រូវភៀសខ្លួនទៅរស់នៅភូមិនរាយណ៍វិញ ។ នៅទីនោះ គ្រួសាររបស់ ប៉ូរហាន បានជួលផ្ទះមួយសម្រាប់សម្រាកពេលយប់ ។ រហូតមកដល់ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមក៏បានចូលមកដល់ផ្សារនរាយណ៍ ដោយដំបូងបានធ្វើល្អជាមួយប្រជាជន សូម្បីតែការនិយាយស្តីក៏មិនឲ្យប៉ះពាល់ដល់ប្រជាជនឡើយ ។ រយៈពេលពីរបីថ្ងៃក្រោយមក ខ្មែរក្រហមក៏ប្រាប់ឲ្យប្រជាជនទាំងអស់ចាកចេញពីក្រុងបាត់ដំបង ព្រោះអង្គការត្រូវរៀបចំបោសសម្អាតក្រុងឲ្យស្អាត ។ ប៉ូរហាន និងគ្រួសារក៏បានត្រឡប់មករស់នៅភូមិកំណើតវិញ ។ ប៉ុន្តែ ពេលមកដល់ភូមិ ខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនទៅរស់នៅផ្ទះរៀងៗខ្លួនទេ ដោយផ្ទះនោះទុកឲ្យយោធាស្នាក់នៅវិញ ។ ចំណែកការរស់នៅរបស់ជនជាតិអ៊ីស្លាមមិនទាន់មានការរិតត្បិតនៅឡើយទេ ដោយប្រជាជនអាចប្រណិប័តន៍សាសនាដូចមុនដដែល ។

រហូតមកដល់ឆ្នាំ១៩៧៦ ស្ថានការណ៍មានការប្រែប្រួលទាំងស្រុង ដោយសារអង្គការបានហាមឃាត់ប្រជាជនមិនឲ្យប្រតិបត្តិសាសនាដូចពីមុនៗ ។ ពេលនោះ ជីតារបស់ ប៉ូរហាន បានលួចសំយ៉ាំងនៅក្នុងមុង ដោយឲ្យគាត់ជាអ្នកយាមមើលផ្លូវព្រោះខ្លាចឈ្លបខ្មែរក្រហមលបមើលឃើញ ។ បន្តិចក្រោយមក ប្រធានវរៈឈ្មោះ ឆោម ក៏ដើរមកដល់ ហើយក៏សួរថា «តាអ្វែងទៅណា»? ភ្លាមនោះ ប៉ូរហាន ក៏ឆ្លើយថា គាត់ដេកនៅក្នុងមុង រួចហើយក៏ធ្វើសញ្ញាឲ្យជីតារបស់គាត់ធ្វើពុតជាដេកលក់ ។ ឃើញដូច្នេះ តាឆោម ក៏ដើរត្រឡប់ទៅវិញ ។

ប៉ូរហាន និងក្មេងជាច្រើននៅក្នុងភូមិបានចូលរៀនដោយមានលោកគ្រូ សារុណ (អតីតគ្រូនៅសម័យសាធារណរដ្ឋខ្មែរ) ជាអ្នកបង្រៀន ។ នៅសាលា ប៉ូរហាន តែងតែឮគ្រូអប់រំសិស្សនៅក្នុងថ្នាក់ឲ្យមានសីលធម៌ ខិតខំជួយធ្វើការស្រែចម្ការឪពុកម្តាយ និងត្រូវគោរពវិន័យរបស់អង្គការ ។ នៅពេលដល់ម៉ោងចេញលេងម្តងៗ ប៉ូរហាន មិនដែលបានសម្រាកទេ គឺគ្រូឲ្យគាត់និងសិស្សនៅក្នុងថ្នាក់ដើរកាប់ និងប្រមូលដើមទន្ទ្រានខែត្រមកចញ្ច្រាំធ្វើជី ។ ប៉ូរហាន រៀនបានរយៈពេលមួយឆ្នាំប៉ុណ្ណោះ ក៏ឈប់រៀនដោយសារគ្រូរបស់គាត់បានបាត់ខ្លួនដោយពុំដឹងពីមូលហេតុ ។

ក្រោយពីឈប់រៀន អង្គការចាត់តាំង ប៉ូរហាន ដើររើសកួរស្រូវ ធ្វើជី និងរកខស ។ រៀងរាល់ថ្ងៃ ប៉ូរហាន ខិតខំធ្វើការងារដោយពុំមានហ៊ានសម្រាកឡើយ ចំណែករបបអាហារត្រូវខ្មែរក្រហមបង្ខំឲ្យគាត់ហូបសាច់ជ្រូក ។ ប៉ុន្តែទោះបីជាគ្មានអាហារហូបយ៉ាងណាក៏ដោយ ក៏ ប៉ូរហាន មិនដែលហូបសាច់ជ្រូកដែរ ហើយគាត់តែងតែលួចយកទៅចាក់ចោល ។ នៅក្នុងភូមិ ប្រសិនបើក្មេងណាដែលមិនបានទៅធ្វើការ អង្គការនឹងកាត់របបអាហារ ឬបង្អត់អាហារតែម្តង ។

ដើមឆ្នាំ១៩៧៨ ជារដូវទឹកឡើងខ្លាំង ខ្មែរក្រហមចាត់តាំងកុមារទាំងអស់ឲ្យហែលឆ្លងទឹកទៅរកខសមួយថ្ងៃឲ្យបានមួយដុំ ។ ដោយសារ ប៉ូរហាន រកខសមិនបាន ឪពុករបស់គាត់ព្រួយបារម្ភយ៉ាងខ្លាំងព្រោះខ្លាចអង្គការដាក់វិន័យ ដូច្នេះឆ្លៀតពេលសម្រាកហូបបាយ គាត់បានលួចដើររកខសមកទុកនៅផ្ទះដើម្បីឲ្យ ប៉ូរហាន យកប្រគល់ឲ្យអង្គការ ។ មិនយូរប៉ុន្មានខ្មែរក្រហមបានបំបែក ប៉ូរហាន ពីម្តាយដោយផ្លាស់ប្តូរឲ្យគាត់ទៅ

រស់នៅភូមិតាប៉ុនវិញ ។ នៅថ្ងៃមួយ ពេល ប៉ូរហាន ចេញទៅធ្វើការនៅវាលស្រែ ស្រាប់តែកុមារឈ្មោះ ទី ដែលធ្វើការក្នុងកងជាមួយមកផ្តាំគាត់ថា "បើអង្គការហៅឈ្មោះខ្ញុំ សូមមិត្តជួយឆ្លើយជំនួសផង ព្រោះខ្ញុំទៅលេងឪពុកម្តាយនៅផ្ទះ" ។ នៅថ្ងៃបន្ទាប់មេកងបានហៅឈ្មោះកុមារទាំងអស់ ខណៈនោះ ប៉ូរហាន ក៏ឆ្លើយជំនួសឈ្មោះ ទី ស្រាប់តែមេកងចំណាំសំឡេង រួចក៏ចាប់គាត់វាយយ៉ាងដំណំ ហើយថែមទាំងចោទគាត់ថាជាខ្មាំងទៀតផង ។ ប៉ុន្តែក្រោយមក ដោយដឹងថា ប៉ូរហាន មិនមានបំណងកុហកអង្គការ (មិត្តភក្តិផ្តាំផ្ញើ) ទើបមេកងដោះលែងវិញ ។ នៅការដ្ឋានភូមិតាប៉ុន ប្រសិនបើកុមារ ឬអ្នកធ្វើការនៅក្នុងណាដែលចង់ជួបឪពុកម្តាយ ឬក្រុមគ្រួសារ ត្រូវសុំច្បាប់អនុញ្ញាតជាមុនសិន ។ ចំណែកអ្នកដែលធ្វើខុសនឹងវិន័យដូចជា តា ចេង ជាអ្នកឡើងត្នោត ត្រូវខ្មែរក្រហមយកទៅវាយសម្លាប់ចោលជាមួយនឹងដំបងឫស្សីនៅក្បែរវត្តតាប៉ុនតែម្តង ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រកាសតាមវិទ្យុភ្នំពេញថា ខ្មាំងជិតចូលមកដល់ហើយ ដូច្នេះបងប្អូនត្រូវជម្លៀសទៅប៉ែកខាងលិចនៅខេត្តបាត់ដំបងវិញ ។ ពេលនោះ មានប្រជាជនបីគ្រួសារ ដែលរួមទាំងគ្រួសាររបស់ ប៉ូរហាន ផង ក៏បានលួចគេចទៅរស់នៅក្នុងសហករណ៍ឪម៉ាល់ ស្ថិតនៅក្នុងភូមិបឹងរាំងដែលមានតាប្រេ ជាប្រធាន ។ នៅទីនោះ ដោយសារមេកងចិត្តល្អ ទើបប្រជាជនទាំងអស់មានរបបអាហារគ្រប់គ្រាន់ ប៉ុន្តែទោះបីជាឃើញមេកងយកចិត្តទុកដាក់ពីជីវភាពរបស់ប្រជាជនយ៉ាងនេះក្តី ក៏គ្រួសាររបស់ ប៉ូរហាន នៅតែព្រួយបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួនដែរ ។ រយៈពេលកន្លះខែក្រោយមក ដោយសារនៅសហករណ៍ឪម៉ាល់តែងតែមានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហម ទើបគ្រួសាររបស់ ប៉ូរហាន រត់ភៀសខ្លួនទៅរស់នៅកន្លែងថ្មីវិញ ។ ចំណែកគ្រួសារមួយ ចំនួនដែលមិនព្រមចាកចេញត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ចោលទាំងអស់ ។

ក្រោយពីកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ គ្រួសាររបស់ ប៉ូរហាន ក៏ធ្វើដំណើរត្រឡប់មករស់នៅភូមិនរាយណ៍វិញបានរយៈពេលមួយឆ្នាំ ក្រោយមកគ្រួសាររបស់ ប៉ូរហាន ក៏ផ្លាស់ទៅនៅភូមិបាសែតរហូតមក ។ នៅក្នុងរបបខ្មែរក្រហម ប៉ូរហាន បាត់បង់មីងពីរនាក់ឈ្មោះ ម៉ារីយ៉ាន និង ទីល្មាស់ ដែលលួចរត់ពីសហករណ៍មកលេងផ្ទះ ហើយត្រូវខ្មែរក្រហមចាប់បាន ។ ចំណែកឪពុកមាម្នាក់ត្រូវ ខ្មែរក្រហមចាប់យកទៅសម្លាប់ដោយមិនដឹងពីមូលហេតុ ។

សព្វថ្ងៃ ប៉ូរហាន គឺជាទូននៅវិហារក្នុងភូមិបាសែត និងមានកូនចំនួនបីនាក់នៅក្នុងបន្ទុក ។ ប៉ូរហាន រំពឹងថា តុលាការនឹងរកយុត្តិធម៌ជូនប្រជាជនគ្រប់ជាតិសាសន៍ដែលបានបាត់បង់ជីវិតនិងទប់ស្កាត់កុំឲ្យរបបឃោរឃៅនេះកើតឡើងម្តងទៀត ។ **ឆាយ ឈុនលី**

# ដំណឹងស្វែងរកប្អូនស្រី

នាងខ្ញុំឈ្មោះ ខៀង ស៊ីផានី សព្វថ្ងៃនេះរស់នៅផ្ទះលេខ២០អា ផ្លូវលេខ៣៣៦ ក្រុមទី៥២ ភូមិទី៧ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំឈ្មោះ ខៀង សាម និងម្តាយខ្ញុំឈ្មោះ ម៉ាយ កាន និងមានបងប្អូនចំនួន៧នាក់ ១) ខ្ញុំ, ២) ប្អូនប្រុស ខៀង សុផាត, ៣) ប្អូនប្រុស ខៀង សាមចន្ទ្រាវុធ, ៤) ប្អូនប្រុស ខៀង តារ៉ា, ៥) ប្អូនប្រុស ខៀង សំសុផន, ៦) ប្អូនស្រី ខៀង សុផល ហៅ ម៉ៅ និង ៧) ប្អូនស្រីពៅ ខៀង វណ្ណារី ។ នាងខ្ញុំសូមប្រកាសស្វែងរកប្អូនស្រីឈ្មោះ ខៀង សុផល ហៅ ម៉ៅ ដែលបានបែកគ្នានៅឆ្នាំ១៩៧៨ នៅខេត្តបាត់ដំបង ។ មុនពេលបែកគ្នា សុផល ហៅ ម៉ៅ បានមកលេងផ្ទះដែលខ្ញុំស្នាក់នៅសហករណ៍ខេត្តបាត់ដំបង «ភូមិតាគង់ ស្រុកភ្នំស្រុក» បានរយៈពេលមួយយប់ទើបត្រឡប់ទៅកងចល័តបន្ទាយរំចេក «កងចល័តកុមារឈានមុខ» វិញ ។ ចាត់តាំងពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីប្អូនស្រីឈ្មោះ សុផល ហៅ ម៉ៅ ឡើយ ។

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ខៀង សុផល ហៅ ម៉ៅ ខាងលើនេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១១ ២៧៨ ០៦៦ ឬ០១១ ៩១៤ ៥៥២ ឬក៏ទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ជាប់គុកដោយសារបដិសេធនឹងអង្គការ

ឃុន សាមឿន អាយុ៤៨ឆ្នាំ មានស្រុកកំណើតនៅភូមិពោធិ៍ព្រះសង្ឃ ឃុំតាភេម ស្រុកត្រាំ កក់ ខេត្តតាកែវ បានរៀបរាប់ថាៈ នៅឆ្នាំ១៩៧០ ខ្មែរក្រហមបានវាយចូលដល់ភូមិពោធិ៍ព្រះសង្ឃ ហើយជម្លៀសប្រជាជនចេញពីភូមិដើម្បីឲ្យទៅធ្វើការតាមតំបន់ផ្សេងៗ ចំណែកឯក្រុមគ្រួសាររបស់ខ្ញុំមិនត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅធ្វើការនៅកន្លែងផ្សេងឡើយ គឺអង្គការបានបញ្ជាឲ្យនៅធ្វើការក្នុងភូមិពោធិ៍ព្រះសង្ឃដដែល ។ នៅក្នុងភូមិ អង្គការបានចាត់តាំងឈ្មោះ គុច ឲ្យធ្វើជាប្រធានភូមិ ហើយបន្ទាប់មកគាត់ក៏បានប្រមូលទ្រព្យសម្បត្តិ ដូះសម្លៀង ស្រូវ អង្ករបស់ប្រជាជនធ្វើជារបស់រួម ។ នៅពេលដឹងរឿងនេះ ពូរបស់ខ្ញុំខឹងយ៉ាងខ្លាំង ប៉ុន្តែគាត់មិនអាចតវ៉ាបានទេដោយសារ គុច មានឋានៈធំ ។ ថ្ងៃមួយពេលដែល គុច កំពុងតែពន្យល់តាយាយរបស់ មឿន អំពីមូលហេតុដែលគាត់ប្រមូលយកទ្រព្យសម្បត្តិ និងរបស់របរទៅធ្វើជារបស់រួម ស្រាប់តែពូរបស់គាត់បានលួចវាយ គុច ពីក្រោយខ្នង ។ រឿងនេះបានធ្វើឲ្យ គុច ខឹងជាខ្លាំង ហើយបានបញ្ជាឲ្យឈ្លបមកចាប់តានិងពូរបស់ខ្ញុំយកទៅដាក់គុកនៅខាងលិចវត្តក្នុងភូមិដោយចោទថារួមគំនិតក្បត់ ។ សព្វថ្ងៃនេះ គុច កំពុងរស់នៅសហរដ្ឋអាមេរិក ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៥ អង្គការចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅអង្គត្នោត ដោយត្រូវបែកចេញពីឪពុកម្តាយ ហើយទោះបីជាមានការនឹករឭកយ៉ាងណាក៏ដោយក៏ខ្ញុំមិនហ៊ានប្រកែកនឹងបញ្ជានេះដែរ ។ ពេលទៅដល់អង្គត្នោត អង្គការបានឲ្យខ្ញុំចូលធ្វើជាកងទ័ព និងចូលប្រយុទ្ធនៅសមរភូមិដូចជាបុរសៗដែរ ។ នៅឆ្នាំ១៩៧៥ អង្គការបានដកខ្ញុំទៅធ្វើការនៅភ្នំដិនវិញ ដោយមានឈ្មោះ ខុន ប្រធានគ្រប់គ្រងទ័ព, ណាន អនុប្រធាន និង នៀនប្រធានកងវរៈ ។ នៅទីនោះ ណាន បានចាត់តាំងបុរស១២នាក់ និងនារី១២នាក់ដែលក្នុង នោះមានឈ្មោះខ្ញុំដែរ ទៅការពារឃ្លាំងអំបិលនៅតាមជើងភ្នំដោយលើកឡើងថា កងទ័ពវៀតណាមខស្សរាហ៍ចូលមកលួចរបស់របរណាស់ ។ នៅពេលយប់ថ្ងៃមួយកងទ័ពវៀតណាមបានបាញ់គ្រាប់ផ្លោងធ្លាក់នៅក្បែរជើងភ្នំបណ្តាលឲ្យមនុស្សស្លាប់ក្នុងមួយយប់ប្រមាណពី២ទៅ៣នាក់ ។ នៅក្នុងឆ្នាំដដែលអង្គការបានដកខ្ញុំឲ្យទៅធ្វើការនៅខាងផ្នែកសេដ្ឋកិច្ចនៅស្រែរនោងវិញ ដោយត្រូវសម្លាប់គោក្នុងមួយថ្ងៃ២៥ក្បាល ។ រាល់ថ្ងៃ ទោះបីខ្ញុំមិនចង់សម្លាប់សត្វក៏ដោយ ក៏ខ្ញុំមិនហ៊ានប្រកែកនឹងបញ្ជារបស់អង្គការដែរ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល ហើយម្យ៉ាងទៀតខ្ញុំបារម្ភខ្លាចខ្មែរក្រហមធ្វើបាបឪពុកម្តាយដែលរស់នៅស្រុកកំណើតឯណោះ ។ នៅស្រែរនោង ខុន ជាប្រធានគ្រប់គ្រងដដែល ហើយ សារុន ជា អនុប្រធាន ។

រហូតដល់ឆ្នាំ១៩៧៦ អង្គការបានផ្លាស់ខ្ញុំឲ្យទៅធ្វើការនៅស្រែអំបិល ដែលនៅទីនោះអង្គការបានចាត់តាំងឲ្យខ្ញុំមកធ្វើជាគ្រូបង្ហាត់ទ័ពដែលស្ថិតនៅក្នុងផ្សារតាកែវទៀត ។ ខ្ញុំបង្ហាត់ទ័ពបានពីរសប្តាហ៍ អង្គការក៏ដកឲ្យទៅរែកអំបិល បុកអង្គប់បង្ហាប់ដីកុងស្រែអំបិល ហើយក្នុងមួយថ្ងៃអង្គការអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកតែបីម៉ោងប៉ុណ្ណោះ ។ ខ្ញុំត្រូវធ្វើការទាំងយប់ទាំងថ្ងៃនៅទីនោះបានរយៈពេលមួយឆ្នាំ អង្គការក៏ផ្លាស់គាត់ឲ្យធ្វើជាទ័ពការពារនៅឆ្នេរសមុទ្រជាមួយនឹងប្រធានឈ្មោះ ខុន និងកងទ័ពជាច្រើនទៀតព្រោះកងទ័ពយួនខស្សរាហ៍ចូលលួចអំបិលនៅឃ្លាំង ។ នៅពេលដែលខ្ញុំ និងទ័ពទាំងអស់ស្នាក់នៅទីនោះបានមួយរយៈ ប៉ុន្តែពុំឃើញមានកងទ័ពវៀតណាមចូលមក ពេលនោះប្រធានបានខ្ញុំត្រឡប់មករែកអំបិលនិងបង្ហាប់វិញ ។ ក្រោយមក អង្គការបានឲ្យខ្ញុំទៅសង់ឃ្លាំងជាមួយបុរសៗទុកសម្រាប់ដាក់អំបិល ហើយបន្ទាប់ពីមេជាងនៅទីនោះស្លាប់ ខ្ញុំក៏ប្តូរទៅធ្វើការខាងកាប់ស្លឹកត្នោត


ឃុន សាមឿន

ដើម្បីទុកសម្រាប់ប្រក់ឃ្លាំងអំបិលវិញ ។ ថ្ងៃមួយពេលដែលខ្ញុំកំពុងតែឡើងដើមត្នោត ស្រាប់តែឃើញសត្វតុកកែមួយទំដាប់នឹងធាងស្លឹកត្នោតបណ្តាលឲ្យខ្ញុំភ័យយ៉ាងខ្លាំង ក៏របូតដៃធ្លាក់ពីលើដើមត្នោតបណ្តាលឲ្យសន្លប់ ។ ឃើញហេតុការណ៍ដូច្នេះ អ្នកធ្វើការក្នុងកងជាមួយក៏បានទៅរាយការណ៍ប្រាប់អង្គការដើម្បីបញ្ជូនខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យ ។

ក្រោយពីបានជាសះស្បើយ អង្គការបានប្រាប់ខ្ញុំថា “មឿនមិនចាំបាច់ទៅកាប់ស្លឹកត្នោតទៀតទេ ហើយឥឡូវអង្គការតម្រូវឲ្យមិត្តធ្វើការជាមួយប្រធានកងរយឈ្មោះ នឿន វិញ” ។ ខ្ញុំបានយល់ព្រម ហើយទៅធ្វើការឲ្យ នឿន ដោយគ្រាន់តែបើកឡានជូនគាត់ទៅភ្នំពេញ និងកំពង់សោមប៉ុណ្ណោះ គឺពុំមានធ្វើការអ្វីទៀតទេ ។ ខ្ញុំបើកឡានបានរយៈពេលប្រាំខែ រហូតដល់ចុងឆ្នាំ១៩៧៦ កងវរៈរបស់ នឿន ធ្វើអំបិលបានផលច្រើនជាងកងវរៈដទៃទៀត ពេលនោះអង្គការក៏ជ្រើសរើសយកកងវរៈរបស់ នឿន ឲ្យទៅធ្វើការនៅពោធិ៍សាត់ ហើយខ្ញុំក៏បានផ្លាស់ទៅនៅជាមួយគាត់ដែរ ។ ទៅដល់ខេត្តពោធិ៍សាត់ដំបូង នឿន បានចាត់តាំងឲ្យខ្ញុំមើលការខុសត្រូវខាងកម្លាំងកងចល័តនៅភូមិសែនជ័យជាមួយប្រធានភូមិឈ្មោះ ជា ។ ប៉ុន្តែមិនយូរប៉ុន្មាន អង្គការបានផ្លាស់ខ្ញុំឲ្យទៅលើកទំនប់នៅការដ្ឋានជាមួយឈ្មោះ ណាន និង រឿន ដែលជាអនុប្រធានវិញ ។

នៅឆ្នាំ១៩៧៨ នៅការដ្ឋានលើកទំនប់ អង្គការក៏បានរៀបចំខ្ញុំឲ្យរៀបការជាមួយឈ្មោះ ឃី ប៉ុន្តែខ្ញុំប្រកែក ។ ក្រោយមកអង្គការបានបង្ខំខ្ញុំជាលើកទីពីរនិងជាបន្តបន្ទាប់ជាមួយឈ្មោះ ខន, វ៉ាន់, ឈាវ, ហួន, ខ្មៅ និង លើកទី៧ជាមួយឈ្មោះ ប្រុញ ប៉ុន្តែខ្ញុំនៅតែមិនយល់ព្រមដដែល ព្រោះគិតថា ពេលដែលខ្ញុំយកប្តីនឹងមានកូន ហើយអាចទទួលរងការលំបាក ។ ខ្ញុំលើកហេតុផលថាចាំយកប្តីនៅស្រុកកំណើត ព្រោះមានឪពុកម្តាយជាអ្នករៀបចំឲ្យនិងមានបងប្អូនដឹងឮផង ។ ដោយសារការបដិសេធនេះ អង្គការខឹងនឹងខ្ញុំយ៉ាងខ្លាំង រួចហើយក៏យកខ្ញុំទៅកសាងដោយឲ្យខ្ញុំទៅមើលការងារស្រែ ដែលពេលនោះទឹកទន្លេឡើងខ្លាំងបណ្តាលឲ្យលិចស្រូវយ៉ាងច្រើន ។ អង្គការបានចោទខ្ញុំថា ក្បត់នឹងបដិវត្តន៍ រួចបញ្ជូនខ្ញុំទៅដាំឪឡឹកនៅរដូវភ្លៀងបណ្តាលឲ្យខូចខាតផលដំណាំយ៉ាងច្រើនទៀត ។ ក្រោយមក អង្គការបានផ្លាស់ខ្ញុំទៅរៀនដេរនៅភ្នំពេញវិញ ។ ដោយសារខ្ញុំមិនធ្លាប់ប្រើប្រាស់ម៉ាស៊ីនដេរពីមុន ខ្ញុំក៏ធ្វើឲ្យបាក់ម្ជុលអស់ពីរដើម ហើយអង្គការក៏ចោទខ្ញុំថាក្បត់ រួចចាប់ខ្ញុំយកទៅដាក់គុកមួយដែលស្ថិតនៅជិតរោងចក្រកាត់ដេរ ។

ខ្ញុំជាប់ឃុំឃាំងអស់រយៈពេល៧ថ្ងៃ ក្រោយមកក៏ឮសូសំឡេងរថក្រោះនិងយន្តហោះរបស់កងទ័ពវៀតណាមកាន់តែជិតមកៗ ។ ពេលនោះ ប្រធានក្រុមទាំងអស់ដែលធ្វើការនៅរោងចក្រកាត់ដេរបាននាំគ្នារត់ចោលរោងចក្រនៅសល់តែខ្ញុំនិងកូនរបស់ឈ្មោះ ប៊ុត ប៉ុណ្ណោះ ។ ខ្ញុំបាននិយាយគំរាមកូនរបស់ ប៊ុត ថា “មិត្តត្រូវយកពូថៅមកកាត់ខ្នោះដៃរបស់យើងចេញ បើមិនដូច្នេះទេនៅពេលដែលយើងដោះរួច យើងនឹងសម្លាប់ឯងវិញ” ។ ឮពាក្យគំរាមនេះ កូនរបស់ ប៊ុត ភិតភ័យយ៉ាងខ្លាំងរួចក៏រត់ទៅយកពូថៅមកវាយខ្នោះរហូតរបូតចេញពីដៃរបស់ខ្ញុំ ។ ក្រោយមក ខ្ញុំបានរត់ចូលក្នុងព្រៃក៏ជួបនឹងកងទ័ពវៀតណាមដែលនិយាយសំឡុតខ្ញុំថា “បើមិត្តឯងជាឈ្លបរបស់ខ្មែរក្រហម ពួកយើងនឹងចិញ្ច្រាំសាច់របស់ឯងឲ្យទាស៊ី” ។ ឮដូច្នេះខ្ញុំភិតភ័យយ៉ាងខ្លាំងហើយក៏លួចរត់ទៅនៅលើភ្នំ ។ ក្រោយពីដឹងរឿងនេះ កងទ័ពវៀតណាមដេញតាមបាញ់ និងតាមចាប់ខ្លួនត្រឡប់មកវិញ ។ រៀងរាល់ថ្ងៃ ខ្ញុំមិនដែលហ៊ានដាំបាយទេ ព្រោះខ្លាចមានភ្លើងនិងផ្សែងបណ្តាលឲ្យកងទ័ពវៀតណាមមើលឃើញ ។ ដូច្នេះខ្ញុំហូបតែអង្ករត្រាំទឹកលាយជាមួយមើមក្តួច គល់ល្ហុង និងគល់ចេក ។

នៅឆ្នាំ១៩៨៥ ខ្ញុំក៏សម្រេចចិត្តយកគ្រួសារឈ្មោះ ម៉ឹង សុផល ដោយប្រកបមុខរបរចិញ្ចឹមមាន់ ទានៅលើភ្នំ ហើយក្រោយមកខ្ញុំបានចូលរៀនពេទ្យជាមួយអង្គការកាកបាទក្រហមនៅជំរំថៃមទៀត ។ នៅឆ្នាំ១៩៩២ ខ្ញុំនិងគ្រួសារបានត្រឡប់ទៅរស់នៅស្រុកកំណើតនិងបានជួបជុំជាមួយឪពុកម្តាយវិញ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានបាត់បង់បងប្អូនពីរនាក់ ទីមួយឈ្មោះ ខន និងទីពីរឈ្មោះ ទ្រី ។ សព្វថ្ងៃ ខ្ញុំមានកូនបីនាក់ ហើយខ្ញុំតែងតែនិយាយរឿងរ៉ាវដែលខ្មែរក្រហមប្រាប់បងប្អូនពីការឈឺចាប់ដែលខ្ញុំបានឆ្លងកាត់ និងអំពើឃោរឃៅដែលខ្មែរក្រហមធ្វើមកលើប្រជាជនឯង ។

**ចាន ផល្លា**

# រំឭកថ្ងៃចងចាំ : មន្ទីរបូជនីយដ្ឋានវត្តស្វាយពេជ្រ

នៅរសៀលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ឆ្អឹងលលាដ៍ក្បាលនិងឆ្អឹងខ្លួនសាកសពដែលបានស្លាប់ក្នុងរយៈពេលនៃការកាន់កាប់អំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ ចំនួន៦កញ្ចប់ បានត្រូវដង្ហែយកទៅដាក់តម្កល់នៅក្នុងមន្ទីរបូជនីយដ្ឋានដ៏ថ្មីសន្ធាងមួយដែលមានទីតាំងស្ថិតនៅក្នុងបរិវេណវត្តស្វាយពេជ្រស្ថិតនៅក្នុងឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។ ថ្លែងក្នុងពិធីរំឭកការចងចាំនេះ ឯកឧត្តម សួង សិទ្ធី បានមានប្រសាសន៍ពីគោលបំណងនៃការសាងសង់នេះថា គឺដើម្បីជាការចងចាំនូវរឿងរ៉ាវដ៏ជូរចត់ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ទៅលើជីវិតប្រជាជនកម្ពុជារាប់លាននាក់ ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ជីវិតប្រជាជនដែលបានស្លាប់ដោយអំពើអយុត្តិធម៌ក្នុងរបបខ្មែរក្រហមឥឡូវនេះព្រលឹងអ្នកទាំងនោះនឹងទទួលបានការយកចិត្តទុកដាក់និងថែទាំយ៉ាងកក់ក្តៅពីសំណាក់អ្នកដែលនៅរស់រានមានជីវិតក្រោយរបបខ្មែរក្រហមនិងក្មេងៗជំនាន់ក្រោយដែលបាននិងកំពុងតែទទួលស្គាល់ការពិតទាំងនេះតាមរយៈការសិក្សានៅក្នុងថ្នាក់រៀនរបស់ខ្លួនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩» ។ ប្រជាជនមកពីគ្រប់ឃុំក្នុងស្រុកអង្គស្នួល ព្រមទាំងសិស្សានុសិស្សមកពីសាលាមួយចំនួនផងបានមកចូលរួមក្នុងពិធីនេះ និងបានដង្ហែអដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមយកទៅដាក់តម្កល់នៅក្នុងបូជនីយដ្ឋានថ្មីដែលមានសណ្ឋានដូចគ្នានឹងមន្ទីរបូជនីយដ្ឋាននៅវាលពិឃាតជើងឯក ដោយមានការរៀបចំយ៉ាងត្រឹមត្រូវនិងល្អឥតខ្ចោះតាមបែបបទប្រពៃណី និងទំនៀមទម្លាប់ខ្មែរ ។ កសិណសាក្សីដែលមិនអាចប្រកែកបាននេះបានជួយបន្ថែមល្បឿនក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមចំនួនបួនរូបឲ្យកាន់តែមានភាពរលូននិងឆាប់រហ័ស ។ វត្តមាននៅក្នុងឱកាសនេះដែរ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក អេនជ្រូ ខាយលី សហព្រះរាជអាជ្ញាអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានអញ្ជើញជាភ្ញៀវកិត្តិយសនៅក្នុងពិធីរំឭកការចងចាំនេះនិងបានអុជធូបបួងសួងដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានស្លាប់ដោយអំពើអយុត្តិធម៌ឲ្យបានដល់សុគតិភពនិងទទួលបានភាពយុត្តិធម៌តាមរយៈការខិតខំប្រឹងប្រែងទាំងផ្លូវតុលាការ និងប្រវត្តិសាស្ត្រ ។ ប្រជាជនខ្មែរគ្រប់រូបពិតជាមិនអាចបំភ្លេចបានឡើយនូវព្រឹត្តិការណ៍ដ៏ជូរចត់ដែលខ្លួនបានជួបប្រទះនៅក្នុងរបបខ្មែរក្រហម ហើយព្រឹត្តិការណ៍ទាំងនេះបានក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម្រាប់ប្រទេសកម្ពុជាដែលយុវជនយុវតីជំនាន់ក្រោយដែលពុំធ្លាប់ឆ្លងកាត់របបខ្មែរក្រហមត្រូវតែសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅដើម្បីជាចំណេះដឹងអំពីប្រវត្តិសាស្ត្រនិងរឿងរ៉ាវពិតដែលបានកើតឡើងលើឪពុកម្តាយ ជីដូនជីតា និងសាច់ញាតិរបស់ខ្លួនកាលពីរបបខ្មែរក្រហម ។ ខាងក្រោមនេះជារឿងរ៉ាវប្រវត្តិសាស្ត្រមួយដែលបានកើតឡើងនៅក្នុងបរិវេណវត្តស្វាយពេជ្រកាលពីអំឡុងឆ្នាំ១៩៧៦ដល់១៩៧៩ :

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខប្រចាំស្រុកអង្គស្នួលមួយកន្លែងនៅក្នុងបរិវេណវត្តស្វាយពេជ្រ ដែលមានសមមិត្ត ឌុន ជាប្រធាន និង សមមិត្ត អឹម ជាអនុប្រធានមន្ទីរសន្តិសុខ ។ កុដិនិងសាលារៀនត្រូវកងឈ្លបខ្មែរក្រហមប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំងអ្នកទោសនិងកន្លែងស្នាក់នៅរបស់កម្មាភិបាលធ្វើការនៅក្នុងមន្ទីរ ។ ចំណែកព្រះវិហារគឺជារោងបាយ ហើយបរិវេណជុំវិញវត្តគឺជាកន្លែងកប់សាកសពអ្នកទោស ។



ពិធីដង្ហែរអដ្ឋិធាតុជនរងគ្រោះ នៅវត្តស្វាយពេជ្រ

អ្នកទោសដែលជាប់នៅវត្តស្ទួនពេជ្រគឺជាប្រជាជនដែលខ្មែរក្រហមចាប់មកពីឃុំនានាទូទាំងស្រុកអង្គស្នួលបូករួមទាំងជនជាតិចិននិងចាមផង ។ ក្នុងចំណោមអ្នកទោសទាំងអស់ មានតែប្រជាជនជម្លៀសប៉ុណ្ណោះដែលត្រូវចោទប្រកាន់ថាជាខ្មែរសភ្នាក់ងារកាហ្សេប សេអ៊ីអា និងមន្ត្រីរដ្ឋការដែលជាប់និន្នាការនយោបាយពីសង្គមចាស់ ។ ចំណែកអ្នកទោសជាប្រជាជនមូលដ្ឋានវិញត្រូវបានចោទប្រកាន់ពីបទមិនគោរពអង្គការវិន័យឬបម្រើបដិវត្តន៍មិនបានល្អ ។ គឹម សែ រស់នៅភូមិស្ទួនពេជ ឃុំកន្ទោក ស្រុកអង្គស្នួល បាននិយាយប្រាប់ថា ក្រុមកងឈ្លបរបស់គាត់ដែលមានសមាជិក៣០នាក់ត្រូវកងសន្តិសុខចាប់ខ្លួនមកដាក់ឃុំឃាំងទាំងអស់ ដោយគ្រាន់តែរើសបានត្នោតទុំមួយយកមកចែកគ្នាហូបប៉ុណ្ណោះ ។ អ្នកទោសទាំងអស់បានទទួលរបបអាហារប្រចាំថ្ងៃតិចតួចបំផុត ។ សែ និយាយថា ពេលកំពុងធ្វើការអ្នកទោសខ្លះបានលួចក្តិចត្រួយស្ពៅខ្ចីៗដែលដុះតាមភ្លឺស្រែយកមកហូបនិងអ្នកទោសខ្លះបានស្លាប់នៅកន្លែងធ្វើការតែម្តងដោយសារតែគ្មានកម្លាំងកំហែង ។ សែ បានលើកឧទាហរណ៍ប្រាប់ថា អ្នកទោសម្នាក់បានស្លាប់ក្នុងពេលកំពុងជញ្ជូនកំប្លោកពីក្នុងទឹកមកដាក់លើគោក ។ ក្រៅពីស្លាប់ដោយសារធ្វើការហួសកម្លាំងនិងអត់អាហារ មានអ្នកទោសភាគច្រើនទៀតបានស្លាប់ដោយសារការធ្វើទារុណកម្មនិងសួរចម្លើយនៅលើព្រះវិហារវត្តស្ទួនពេជ្រតាមវិធីចងជើងព្យួរជាប់នឹងខ្សែរតែដែលភ្ជាប់ពីលើដំបូលព្រះវិហារ ហើយទាញឡើងទៅលើ រួចទម្លាក់មកក្រោមវិញ ។

នៅចុងឆ្នាំ១៩៧៨ អ្នកទោសភាគច្រើននៅក្នុងមន្ទីរសន្តិសុខវត្តស្ទួនពេជ្រត្រូវកងសន្តិសុខនាំយកទោសម្លាប់ចោលនៅជុំវិញបរិវេណវត្ត ស្រះទឹកខាងមុខព្រះវិហារ និងនៅខាងលិចសាលារៀន ។ នៅក្នុងឆ្នាំដដែលនេះដែរ អ្នកទោសខ្លះបានលួចរត់រួចពីមន្ទីរឃុំឃាំង និងខ្លះទៀតត្រូវកងសន្តិសុខចាប់យកមកវិញ ។


លោក អេនឌ្រូ ខេលី អុជធូបទទិសដល់ជនរងគ្រោះ

នៅក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខវត្តស្ទួនពេជ្របានបន្សល់ទុកឧបករណ៍សម្រាប់ធ្វើទារុណកម្មយ៉ាងច្រើននិងមានស្នាមឈាមប្រឡាក់ជិតជាមពេញនៅលើជញ្ជាំងព្រះវិហារ ។ នៅឆ្នាំ១៩៨២ ឧបករណ៍ដែលនៅសេសសល់ទាំងប៉ុន្មានត្រូវបានដឹកជញ្ជូនមកកាន់ទីក្រុងភ្នំពេញ ហើយរណ្តៅមួយចំនួនត្រូវប្រជាជនគាស់ឡើងដើម្បីយកអដ្ឋិធាតុមកដាក់តម្កល់នៅក្នុងបរិវេណវត្តស្ទួនពេជ្រ ។ រណ្តៅទាំងនោះមានទាំងតូចដែលអាចកប់សាកសពបានពីម្នាក់ឬពីរនាក់និងរណ្តៅធំដែលមានទំហំចាប់ពី៥ម៉ែត្របួនជ្រុង និងជម្រៅពី១,៥០ ម៉ែត្រឬ២ម៉ែត្រ ដែលអាចដាក់សាកសពបានពី១៥០នាក់ទៅ២០០នាក់ ឬពី៣០០នាក់ទៅ៥០០នាក់ ។ រហូតមកដល់បច្ចុប្បន្ននេះ ពុំមានបន្សល់ទុកស្លាកស្នាមរណ្តៅដែលបានជីកទាំងនោះឡើយ ។

អគាររបស់ទ្រុឌទ្រោមមួយកន្លែងស្ថិតនៅប៉ែកខាងលិចឆៀងខាងត្បូងព្រះវិហារវត្តស្ទួនពេជ្រត្រូវបានប្រើប្រាស់ធ្វើជាកន្លែងតម្កល់ឆ្អឹងសាកសពក្រោយពីការគាស់ចេញពីរណ្តៅចំនួនជាងដប់នៅជុំវិញបរិវេណវត្ត ។ ជាច្រើនឆ្នាំក្រោយមក អគារដ៏ចំណាស់មួយនេះបានបាក់ស្រុតស្ទើរទាំងស្រុង ។ អដ្ឋិធាតុដែលដាក់តម្កល់នៅក្នុងអគារនេះបានត្រូវព្រះសង្ឃ គណៈកម្មការវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តជញ្ជូនចេញយកទៅដាក់តម្កល់ជាបណ្តោះអាសន្ននៅក្នុងសាលាឆាន់នាវត្តដដែលនេះ ។ ក្នុងរយៈកាលនេះ ព្រះសង្ឃ គណៈកម្មការវត្ត និងពុទ្ធបរិស័ទចំណុះជើងវត្តព្រមទាំងសប្បុរសជននានាជាច្រើនបានផ្តួចផ្តើមគំនិតកសាងមន្ទីរបូជនីយដ្ឋានថ្មីមួយដោយបានធ្វើការរៃអង្គាសថវិកាតាមរយៈការធ្វើបុណ្យផ្កាសាមគ្គីចំនួនពីរដង និងបានសំណូមពរដល់ថ្នាក់ដឹកនាំស្រុកនឹងខេត្តឲ្យជួយជ្រោមជ្រែងក្នុងការកសាងនេះ ។ នៅពាក់កណ្តាលខែឧសភា ឆ្នាំ២០១០ មន្ទីរបូជនីយដ្ឋាននេះបានកសាងរួចរាល់ជាស្ថាពរនិងបានប្រកាសជាសាធារណៈនៅរសៀលថ្ងៃទី១៩ ខែឧសភា ថាជាមន្ទីរបូជនីយដ្ឋានរបស់ជាតិសម្រាប់ការចងចាំ ។ **ផេង ពង្សរ៉ាស៊ី**

# ការជួបប្រជុំជាមួយអ្នកភូមិ ៖ កម្មាភិបាលខ្មែរក្រហម ថ្នាក់ក្រោមបានកាត់បន្ថយភាពភ័យខ្លាច

ឃុំក្រាំងលាវ ស្ថិតនៅក្នុងស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ធ្លាប់ជាកន្លែងដែលមានការបះបោរប្រឆាំងនឹងអាណានិគមបារាំង នៅអំឡុងទសវត្សរ៍២០ ។ កន្លែងនេះត្រូវបានផ្លាស់ឈ្មោះទៅជាភូមិតិរច្ឆានវិញបន្ទាប់ពីប្រជាជនបះបោរប្រឆាំងនឹងការធ្វើបាបរបស់អាណានិគមបារាំងនិងអាជ្ញាធរក្នុងស្រុក ។ នៅក្នុងហេតុការណ៍នោះ វ៉ែស៊ីដង់បារាំងឈ្មោះ បាដេស, អ្នកយាមឈ្មោះ សួន, និង ចុងភៅម្នាក់ត្រូវបានសម្លាប់ (នៅជិតវត្តក្រាំងលាវ) ។ នៅដើមទសវត្សរ៍៧០ ពេលដែលសម្តេចនរោត្តម សីហនុ ត្រូវបានបណ្តេញចេញពីអំណាច ឃុំនេះបានក្លាយទៅជាតំបន់រំដោះរបស់ខ្មែរក្រហមដែលមានប្រជាជនជាច្រើនចូលរួមធ្វើបដិវត្តន៍ ហើយក្រោយមកអ្នកទាំងនោះក្លាយជាកម្មាភិបាលខ្មែរក្រហម ។

ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ ក្រុមការងារនៃគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅឃុំក្រាំងលាវ ដើម្បីបញ្ចាំងខ្សែភាពយន្តឯកសារខ្មែរក្រហម និងជជែកពិភាក្សាជាមួយអ្នកភូមិ ។ គោលបំណងនៃការចាក់បញ្ចាំងខ្សែភាពយន្ត និងជួបពិភាក្សា គឺដើម្បីផ្តល់ដំណឹងដល់អ្នកភូមិអំពីដំណើរវិវត្តរបស់តុលាការខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដើម្បីបង្ហាញពីសារសំខាន់នៃសំណុំរឿង០០២ដែលមានជាប់ពាក់ព័ន្ធនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់បួនរូប ៖ ខៀវ សំផន, នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ។

### វេទិកាពិភាក្សាភូមិ

នៅថ្ងៃទី១១ខែមីនា វេលាម៉ោង៨ ដោយមានការចូលរួមរបស់អ្នកភូមិប្រមាណ១៥០នាក់ ក្រុមការងារបានចាប់ផ្តើមកម្មវិធីដោយការណែនាំឲ្យស្គាល់អំពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំង



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាប្រជុំជាមួយអ្នកភូមិ នៅឃុំក្រាំងលាវ

គោលបំណងនៃការទៅដល់ភូមិនោះ ។ បន្ទាប់មក ស៊ីវ សាវីណា ដែលជាប្រធានគម្រោងបានបង្ហាញពីរចនាសម្ព័ន្ធរបស់តុលាការ និងដំណើរការមកដល់ពេលបច្ចុប្បន្នដល់អ្នកភូមិ ។ បន្ទាប់មក សាវីណា បានជម្រាបអ្នកភូមិអំពីសំណុំរឿង០០២ ដែលមានជាប់ពាក់ព័ន្ធនឹងជនត្រូវចោទ៤រូប បច្ចុប្បន្នកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។ សាវីណា បានសួរទៅអ្នកភូមិថាតើធ្លាប់បានដឹងឮ ឬក៏ស្គាល់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងនោះដែរឬទេ ។ អ្នកភូមិបានគ្រវីក្បាល ប៉ុន្តែសម្ដែងទឹកមុខចង់ដឹងពីប្រវត្តិរបស់ជនត្រូវចោទ ។ បន្ទាប់មក សាវីណា បានបង្ហាញពីសៀវភៅណែនាំអំពីសំណុំរឿង០០២ របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានបង្ហាញពីរូបថតរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួននៅតុលាការ និងរូបភាពនៃភ័ស្តុតាងដែលបង្ហាញពីទំនាក់ទំនងរបស់ជនទាំងបួនរូបនឹងឧក្រិដ្ឋកម្មដែលអ្នកទាំងនោះបានប្រព្រឹត្តនៅក្នុងរបបនោះថែមទៀត ។

បន្ទាប់ពីបង្ហាញរូបថតមេដឹកនាំទាំងបួន សាវីណា បានបង្ហាញពីសេចក្ដីសង្ខេបនៃប្រវត្តិរបស់អ្នកទាំងនោះ និងបទឧក្រិដ្ឋដែលសហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះបានចោទប្រកាន់អ្នកទាំងនោះផងដែរដែលរួមមានឧក្រិដ្ឋកម្មអន្តរជាតិ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម) និង ឧក្រិដ្ឋកម្មក្នុងស្រុក (ការធ្វើទារុណកម្ម ការសម្លាប់ និងការធ្វើទុក្ខបុកម្នេញ) ។ បន្ទាប់មក ក្រុមការងារបានធ្វើសេចក្ដីសន្និដ្ឋានទៅលើបទបង្ហាញដោយពិភាក្សាអំពីភាពស្មុគស្មាញនៃដំណើរការរបស់អង្គជំនុំជម្រះ និងមូលហេតុដែលត្រូវចំណាយពេលយូរដើម្បីដំណើរការ ។ ក្រុមការងារបានបង្ហាញនូវរាល់ដំណើរការនីតិវិធីដែលអង្គជំនុំជម្រះត្រូវធ្វើមុននឹងធ្វើការកាត់ក្ដីជនត្រូវចោទនីមួយៗ ។ បទបង្ហាញបានបញ្ចប់ដោយមានការពន្យល់អំពីមធ្យោបាយផ្សេងគ្នាដើម្បីចូលរួមក្នុងដំណើរការរបស់តុលាការ ដែលរួមមានការបំពេញបែបបទសុំធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកប្ដឹង និងមធ្យោបាយដើម្បីចូលរួមស្ដាប់សវនាការតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ឬទៅអង្គជំនុំជម្រះដោយផ្ទាល់ ។

អ្នកភូមិបានបង្ហាញពីការពេញចិត្តនឹងបទបង្ហាញ ។ អ្នកភូមិខ្លះបានបញ្ចេញយោបល់របស់ខ្លួន និងសួរសំណួរខ្លីមួយចំនួនទៅកាន់ក្រុមការងារ ។ សំណួររបស់អ្នកភូមិមានដូចជាៈ ហេតុអ្វីបានជាត្រូវចំណាយពេញយូរដើម្បីកាត់ទោសជនត្រូវចោទ? តើ



អ្នកភូមិសួរសំណួរទៅកាន់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា

កម្មាភិបាលថ្នាក់ទាបត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលគេបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមដែរឬទេ? តើនឹងមានសំណងអ្វីដល់ជនរងគ្រោះបន្ទាប់ពីការកាត់ទោស? តើខ្ញុំអាចចូលរួមក្នុងសវនាការបានដែរឬទេនៅពេលដែលការកាត់ទោសចាប់ផ្តើម?

បន្ទាប់ពីក្រុមការងារបានឆ្លើយនឹងសំណួររបស់អ្នកភូមិ អ្នកភូមិបានចាប់អារម្មណ៍ចង់ចូលរួមសវនាការនៅអង្គជំនុំជម្រះ ហើយបន្ទាប់មកចុះឈ្មោះដើម្បីមកធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មានអ្នកភូមិម្នាក់បានមកជួបក្រុមការងារដើម្បីប្រាប់ពីសមាជិកគ្រួសារដែលបានបាត់ខ្លួន ហើយបានស្នើឲ្យក្រុមការងារយើងជួយប្រកាសរកដំណឹងនោះនៅក្នុងទស្សនាវដ្តីស្វែងរកការពិតផង ។

ដោយសារតែក្រុមការងារបាននាំយកសៀវភៅណែនាំអំពីសំណុំរឿង០០២ទៅភូមិតិចពេក (ដោយសារតែភាពយឺតយ៉ាវក្នុងការបោះពុម្ព) មានតែសាលាឃុំ និងមេភូមិប៉ុណ្ណោះដែលទទួលបានសៀវភៅនោះសម្រាប់ដាក់ឲ្យអ្នកភូមិអាន ។ អ្នកភូមិមួយចំនួនបានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះសៀវភៅណែនាំ ហើយបានស្នើឲ្យក្រុមការងារចែកសៀវភៅនេះដល់អ្នកភូមិឲ្យបានគ្រប់ៗគ្នានៅពេលក្រោយ ។ ទោះបីជាមិនមានសៀវភៅគ្រប់គ្រាន់ក៏ដោយ ក៏ក្រុមការងារបានចែកទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅណែនាំអំពីអង្គជំនុំជម្រះដែលមានចំណងជើងថា ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដល់អ្នកភូមិគ្រប់រូបផងដែរ ។

## ការបង្ហាញខ្សែភាពយន្ត

បន្ទាប់ពីការជួបប្រជុំនៅពេលព្រឹក អ្នកភូមិបានបំបែកគ្នាដើម្បីទៅទទួលទានអាហារថ្ងៃត្រង់និង សម្រាកពេលថ្ងៃ ដែលធ្វើឲ្យក្រុមការងារមានឱកាសសម្រាប់រៀបចំការបង្ហាញខ្សែភាពយន្តនៅពេលល្ងាច ។ ក្រុមការងារបានជ្រើសរើសខ្សែភាពយន្តអំពីគុកខ្មែរក្រហមដែលហៅថា ស-២១ (បច្ចុប្បន្នត្រូវបានស្គាល់ជាសារមន្ទីរទួលស្លែង) ដែលបានរៀបរាប់ពីបទពិសោធន៍របស់អ្នកទោសដែលនៅរស់ពីគុកនោះ និងសវនាការនៅអង្គជំនុំជម្រះដោយមាន ឌុច សំផន ឡើងនិយាយបដិសេធមិនទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។

អ្នកភូមិមានប្រតិកម្មចំពោះពាក្យសម្តីរបស់ ខៀវ សំផន ជាខ្លាំង ។ ស្ត្រីម្នាក់បាននិយាយអំពីការបដិសេធមិនទទួលខុសត្រូវរបស់ ខៀវ សំផន ថានោះគឺជាពាក្យដោះសាដើម្បីមិនចង់ទទួលខុសត្រូវ ។ គាត់បាននិយាយថា ខៀវ សំផន គឺជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយគឺជាគណៈប្រធានរដ្ឋទៀតផង ។ គាត់មិនជឿថា ខៀវ សំផន មិនមានអំណាច ហើយមិនដឹងពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ ឬផែនការសម្រាប់កម្មាភិបាលថ្នាក់ក្រោមទេ ។ អ្នកភូមិម្នាក់ទៀតដែលយល់ស្របនឹងគំនិតរបស់ស្ត្រីម្នាក់នេះបានបន្ថែមថា មិនត្រឹមតែ ខៀវ សំផន ទេដែលត្រូវយកមកកាត់ទោស មេដឹកនាំដទៃទៀតគួរតែទទួលការកាត់ទោសដែរចំពោះអ្វីដែលខ្លួនបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម ។ ពាក្យសម្តីទាំងនេះធ្វើឲ្យយើងអាចធ្វើសេចក្តីសន្និដ្ឋានចំពោះការបង្ហាញខ្សែភាពយន្តនៅពេលល្ងាចដែលឆ្លុះបញ្ចាំងពីអារម្មណ៍របស់ប្រជាជនចំពោះមេដឹកនាំខ្មែរក្រហម ។

## ការអង្កេតរបស់ក្រុមការងារ និងបទសម្ភាសន៍ជាមួយអ្នកភូមិ

នៅដើមទសវត្សរ៍៧០ មេឃុំក្រាំងលាវ និងមេឃុំនៅជាប់នោះត្រូវបានកងទ័ពខ្មែរក្រហមអំពាវនាវឲ្យទៅប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាល លន់ នល់ និងបន្ទាប់មកវាយយកបានតំបន់រំដោះ ។ អ្នកភូមិជាច្រើនត្រូវបានជ្រើសតាំងឲ្យចូលបម្រើកងទ័ព និងបញ្ជូនទៅវាយទាហាន លន់ នល់ ។ យោងទៅតាម សំ ឆោម អាយុ៧៣ ដែលរស់នៅក្នុងស្រុកនេះនៅមុនឆ្នាំ១៩៧៥បានឲ្យដឹងថា អ្នកភូមិជាច្រើនដែលមកពីឃុំក្រាំងសាអែរ ដែលគាត់រស់នៅ និងឃុំនៅជិតនេះ ត្រូវបានទាហាន លន់ នល់ គំរាមកំហែង ដោយសារតែអ្នកទាំងនោះគាំទ្រសម្តេចនរោត្តម សីហនុ ។ ឆោម ជឿជាក់ថាការគំរាមកំហែងរបស់ទាហាន លន់ នល់ និងអាជ្ញាធរបានធ្វើអ្នកភូមិរត់ចូលព្រៃដើម្បីចូលរួមជាមួយខ្មែរក្រហម ។ ជាងនេះទៅទៀត ការគាបសង្កត់ផ្នែកនយោបាយមិនត្រឹមតែធ្វើឲ្យប្រជាជនរស់នៅក្នុងភូមិដែល ឆោម រស់នៅកាលពីដើមទសវត្សរ៍៧០ រត់ចូលព្រៃប៉ុណ្ណោះទេ ថែមទាំងធ្វើឲ្យប្រជាជននៅក្នុងឃុំផ្សេងទៀតដូចជា ក្រាំងលាវ ព្យាយាមដណ្តើមយកសេរីភាព និងការជួបជុំគ្រួសារសាច់ញាតិថែមទៀត ។

ខណៈពេលអ្នកភូមិខ្លះបានចូលបម្រើកងទ័ព និងធ្វើសង្គ្រាម

ជាមួយរដ្ឋាភិបាល លន់ នល់ អ្នកភូមិដទៃទៀតដែលនៅក្នុងភូមិត្រូវបានអង្គការរៀបចំឲ្យធ្វើការនៅក្នុងកង និងរស់នៅជាសហគមន៍ ។ ជាទូទៅ អ្នកភូមិភាគច្រើនត្រូវបានចាត់ទុកថាជាខ្មែរក្រហម ហើយត្រូវអង្គការជឿជាក់ ។ គីម យ៉ូត មកពីភូមិស្រែវាល ឃុំក្រាំងលាវបាននិយាយថា ប្រជាជនខ្លះដែលបានចូលរួមជាមួយខ្មែរក្រហមគឺដើម្បីរំដោះប្រទេសពីពួកចក្រពត្តិនិយម រីឯប្រជាជនខ្លះទៀតចូលរួមជាមួយខ្មែរក្រហមគឺដោយសារតែគ្មានជម្រើស ។ ទោះបីជាអ្នកភូមិបានចូលរួមជាមួយខ្មែរក្រហម ដោយហេតុផលផ្សេងគ្នាក៏ដោយ ប៉ុន្តែអ្នកភូមិជាច្រើនត្រូវបានខ្មែរក្រហមតែងតាំងឲ្យមានឋានៈដែរ ។ គីម យ៉ូត ត្រូវបានចាត់តាំងឲ្យធ្វើជាអ្នកយាមភូមិនៅអំឡុងពេលដែលខ្មែរក្រហមកំពុងវាយជាមួយ លន់ នល់ ។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានយោធា ហើយមានតួនាទីចាប់អ្នកដែលប្រព្រឹត្តកំហុសប្រឆាំងនឹងអង្គការ ។

ឆោម និង យ៉ូត គឺជាអតីតកម្មាភិបាលខ្មែរក្រហម ។ យោងទៅតាមអ្នកភូមិមួយចំនួនបានឲ្យដឹងថា អ្នកទាំងពីរមានតួនាទីខ្ពស់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែអ្នកទាំងពីរបដិសេធមិនទទួលស្គាល់ឡើយ ។ នៅពេលក្រុមការងារធ្វើបទសម្ភាសន៍ជាមួយអ្នកពួកគាត់ អ្នកទាំងពីរបានបង្ហាញពីការព្រួយបារម្ភថាអាចនឹងក្លាយគោលដៅសម្រាប់ការកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកទាំងពីរបានរិះគន់តុលាការដោយបានលើកឡើងពីបញ្ហាតាំងពី៣០ឆ្នាំមុនដែលអ្នកភូមិទទួលបានការផ្សះផ្សានិងការយល់ចិត្តគ្នា ព្រមទាំងរស់នៅជាមួយគ្នារួចទៅហើយ ។ ដំបូងអ្នកទាំងពីរគិតថាវាមានការលំបាកខ្លះក្នុងការទទួលស្គាល់ការពិត ។ អ្នកទាំងពីរក៏យល់ស្របថាវាមានសារសំខាន់សម្រាប់បុគ្គលនិងសង្គមដែលថាតុលាការបង្ហាញពីដែនកំណត់របស់ខ្លួន ។ អ្នកទាំងពីរក៏បានផ្តល់អនុសាសន៍ថា ការពិភាក្សាតាមភូមិបែបនេះគួរតែបង្កើតឡើង ជាពិសេសនៅតាមភូមិដែលគាត់រស់នៅ ដើម្បីបង្កើតការយល់ដឹងរវាងសមាជិករបស់សហគមន៍និងកាត់បន្ថយការព្រួយបារម្ភពីព្រោះសមាជិកខ្លះធ្លាប់ជាខ្មែរក្រហមដែរ ។

ជាសរុបសេចក្តី ការពិភាក្សានិងការបញ្ចាំងខ្សែភាពយន្តបានផ្តល់ការយល់ដឹងជាច្រើនដល់អ្នកភូមិក្រាំងលាវចំពោះអង្គជំនុំជម្រះ ។ សំណួររបស់សមាជិកក្រុមប្រឹក្សាឃុំដែលបានចូលរួមពិភាក្សាទាក់ទងថាតើនឹងត្រូវកាត់ទោសអ្នកណា បានបង្ហាញពីចំណុចសំខាន់ទាក់ទងនឹងស្ថានភាពនៅក្នុងឃុំ ។ ការពន្យល់បង្ហាញពីដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទៅកាត់ទោសមានសារសំខាន់សម្រាប់កាត់បន្ថយភាពភ័យខ្លាចរបស់កម្មាភិបាលថ្នាក់ក្រោម និងស្តារឡើងវិញនូវទំនាក់ទំនងរវាងអតីតជនដៃដល់ និងជនរងគ្រោះនៃរបបខ្មែរក្រហម ។ ការពិភាក្សាតាមភូមិបានបង្ហាញយ៉ាងច្បាស់ថាវាមានសារសំខាន់ក្នុងការធ្វើឲ្យប្រជាជននៅតាមមូលដ្ឋានយល់ដឹងពីដំណើរការនីតិវិធីនៃការកាត់សេចក្តីដើម្បីកាត់បន្ថយការព្រួយបារម្ភថា ខ្លួននឹងត្រូវប្រឈមមុខនឹងការកាត់ទោសខណៈពេលដែលតុលាការកំពុងតែដំណើរការ ។ វាក៏អាចផ្តល់ជាដំណឹងដល់អ្នកដែលធ្លាប់បម្រើខ្មែរក្រហម ឬមានពាក់ព័ន្ធដោយផ្ទាល់ជាមួយឧក្រិដ្ឋកម្មដែលខ្លួនប្រព្រឹត្តកុំឲ្យមានការភ័យខ្លាចមិនចង់សហការជាមួយតុលាការនិងប្រាប់ពីការពិតផងដែរ ។


អ្នកភូមិទស្សនាខ្សែភាពយន្តឯកសាររឿង នៅក្រោយជញ្ជាំងស-២១

**ស៊ីរិ សាវីណា**

# គុកត្រាចក្រោលរបស់ខ្មែរក្រហម

ជាមួយនឹងដំណើរការវិវត្តថ្មីៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ តុលាការខ្មែរក្រហម ។ គុកខ្មែរក្រហមមួយកន្លែងទៀតត្រូវបានរកឃើញនៅក្នុងភូមិព្រះម្លូវ ឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ គុកនេះមានឈ្មោះថា «គុកត្រាច-ក្រោល» ។

នៅមុនរបបខ្មែរក្រហមកាន់កាប់អំណាចទាំងស្រុង ត្រាចក្រោលគឺជាដីព្រៃគ្មានមនុស្សរស់នៅ ។ នៅឆ្នាំ១៩៧៧ ទីនេះត្រូវកម្មាភិបាលខ្មែរក្រហមជ្រើសរើសធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលជាប់និន្នាការនយោបាយពីសង្គមចាស់ ប្រជាជនជម្លៀសនិងប្រជាជនមូលដ្ឋានដែលមានកំហុស បន្តិចបន្តួចប្រឆាំងនឹងអង្គការ ។ ខន គឺជាប្រធានមន្ទីរសន្តិសុខដែលបានគ្រប់គ្រងមន្ទីរនេះតាំងពីដំបូងមក ហើយនៅពេលដែល ខន ត្រូវអង្គការផ្លាស់ចេញទៅធ្វើការនៅកន្លែងផ្សេង ឌី បានចូលមកជំនួសតំណែងនេះរហូតដល់ឆ្នាំ១៩៧៩ ។ អ្នកទោសភាគច្រើនដែលជាប់នៅក្នុងគុកនេះ គឺជាអ្នកទោសដែលកងសន្តិសុខបញ្ជូនមកពី «មន្ទីរថ្កោល» ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីគុកត្រាចក្រោល ។ ជា គន អាយុ៥០ឆ្នាំ ជាប្រជាជនរស់នៅភូមិព្រះម្លូ ឃុំបឹងខ្នារ បានប្រាប់ថា គាត់គឺជាអតីតអ្នកទោសនៅ «មន្ទីរថ្កោល» ដែលត្រូវកងសន្តិសុខបញ្ជូនបន្តមដាក់នៅមន្ទីរសន្តិសុខត្រាចក្រោល មុនពេលដែលកម្មាភិបាលខ្មែរក្រហមរំលាយ «មន្ទីរថ្កោល» ចោល ។ មូលហេតុដែលនាំឲ្យ គន និងក្រុមគ្រួសារទាំងអស់របស់គាត់មានម្តាយឈ្មោះ ប៉ុល ហៀម និងប្អូនស្រីពីរនាក់ទៀត ជា គី និង ជា គា ជាប់ក្នុងមន្ទីរឃុំឃាំងគឺដោយសារពួកគាត់មានឪពុកជាមន្ត្រីរបស់របប លន់ នល់ ។ គន និយាយដូច្នោះថា «ពួកខ្ញុំត្រូវកងឈ្លបចាប់ខ្លួនទាំងគ្រួសារមកដាក់នៅមន្ទីរថ្កោល បន្ទាប់ពីឪពុករបស់ខ្ញុំត្រូវកងឈ្លបចាប់ខ្លួនមួយសប្តាហ៍ ដោយចោទប្រកាន់គាត់ថា ជាអ្នកមានឥទ្ធិពល (និន្នាការ) ទាហាន» ។

នៅដើមឆ្នាំ១៩៧៧ អ្នកទោសប្រភេទស្រាលទាំងអស់ដែលជាប់នៅក្នុង «មន្ទីរថ្កោល» ត្រូវកម្មាភិបាលគ្រប់គ្រងមន្ទីរនោះបញ្ជូនមកដាក់ឃុំឃាំងបន្តនៅ «គុកត្រាចក្រោល» ។ គន បាននិយាយប្រាប់ថា មានអ្នកទោសរាប់រយនាក់បានចាកចេញពីមន្ទីរថ្កោលដោយថ្មើរជើងឆ្ពោះមកកាន់ «គុកត្រាចក្រោល» ។ ដំបូងឡើយ គន និងអ្នកទោសឯទៀតគិតថា ពួកគាត់នឹងមានសេរីភាពបន្ទាប់ពីបានមករស់នៅ «ត្រាចក្រោល» ។ ប៉ុន្តែអ្វីៗមិនដូចការគិតឡើយ ។ គន បានក្រឡេកឃើញរោងធំៗវែងៗចំនួនពីរនៅក្នុងបរិវេណ «ត្រាចក្រោល» និង ក្រៅពីនេះពុំមានអ្វីទៀតឡើយ ។ គន បានបញ្ជាក់ប្រាប់ថា «តាមពិតរោងធំៗទាំងពីរនេះ គឺជាមន្ទីរឃុំឃាំងអ្នកទោសប្រភេទធ្ងន់ដែលខ្មែរក្រហមចាប់មកពីកន្លែងផ្សេងៗក្នុងស្រុកបាកាន ។ ចំណែកអ្នកទោសស្រាលដូច គន និងអ្នកឯទៀតគឺពុំមានរោងសម្រាប់ស្នាក់នៅឡើយ ។ វង់ វ៉ន អាយុ៦៤ឆ្នាំ រស់នៅភូមិព្រះម្លូ ឃុំបឹងខ្នារ ស្រុកបាកាន ក៏ជាអតីតអ្នកទោសប្រភេទធ្ងន់ម្នាក់ដែលជាប់ឃុំឃាំងនៅក្នុងរោងជាមួយអ្នកទោសរាប់រយនាក់ផ្សេងទៀតដែរ ។ ទោសកំហុសរបស់គាត់ត្រូវបានចោទប្រកាន់ថាបានលួចលាក់ស្រូវរបស់អង្គការ ។ ចំណែក អ៊ូក សំយ៉ុល ជាក្រុមប្រឹក្សាឃុំបឹងខ្នារនាពេលបច្ចុប្បន្ននេះ ក៏ជាអតីតអ្នកទោសដែលខ្មែរក្រហមចោទប្រកាន់ថាបានលួចលាក់ស្រូវរបស់អង្គការដែរ ។ រីឯអ្នកទោសជាប្រភេទប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ និងខេត្តមួយចំនួនទៀត សុទ្ធតែត្រូវទទួលការចោទប្រកាន់ពីទោសកំហុសផ្សេងៗគ្នា ។ សំយ៉ុល, វ៉ន, គន និងប្រជាជនក្នុងភូមិជាច្រើននាក់ទៀត មិនបាននិយាយពីទោសកំហុសរបស់អ្នកទាំងនោះឡើយ ប៉ុន្តែគាត់បានសន្និដ្ឋានដូចគ្នាថា ប្រជាជនជម្លៀសទាំងនោះមានជាប់និន្នាការនយោបាយពីសង្គម និងជាអ្នកដែលអង្គការមិនពេញចិត្ត ។

អ្នកទោសប្រភេទធ្ងន់ និងស្រាលរាប់ពាន់នាក់ត្រូវបានសម្លាប់ និងស្លាប់ជាបន្តបន្ទាប់ដោយសារអត់អាហារបរិភោគ និងគ្មានថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺ ។ សាកសពទាំងអស់ត្រូវកងសន្តិសុខនាំយកទៅកប់ចោលនៅក្នុងរណ្តៅរាប់រយស្ថិតនៅប៉ែកខាងក្រោយបរិវេណគុកប្រហែល២០០ម៉ែត្រ ។

ស្ថិតក្នុងសម្លៀកបំពាក់ជាអ្នកស្រែចម្ការម្នាក់ វ៉ន បានអង្គុយ

លើក្រែបុស្សីតូចមួយផ្តល់បទសម្ភាសន៍យ៉ាងក្បោះក្បាយពីប្រវត្តិរបស់គាត់តាំងពីមិនទាន់ក្លាយខ្លួនជាអ្នកទោសរបស់អង្គការរហូតដល់ពេលបច្ចុប្បន្ននេះប្រាប់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

វ៉ន ត្រូវបានខ្មែរក្រហមជម្លៀសឲ្យមករស់នៅក្នុងភូមិអូរព្រាល ឃុំមេទឹក ស្រុកបាកាន ខេត្តពោធិ៍សាត់ នៅឆ្នាំ១៩៧៣ ជាមួយអ្នកភូមិព្រះម្លូទាំងអស់ ដោយមូលហេតុខ្លាចក្រែងប្រជាជនក្នុងភូមិរត់ទៅចុះចូលជាមួយទាហាន លន់ នល់ ។ ទៅដល់ភូមិអូរព្រាលភ្លាម ខ្មែរក្រហមបានចាត់តាំង វ៉ន ឲ្យធ្វើជាប្រធានក្រុមបង្កបង្កើនផល ដោយមានតួនាទីពិនិត្យ និងដឹកនាំការបង្កបង្កើនផលស្រូវ ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុញ្ញាតឲ្យអ្នកភូមិទាំងអស់វិលចូលមករស់នៅក្នុងភូមិកំណើតវិញ គឺភូមិព្រះម្លូ ហើយប្រជាជនដែលបានជម្លៀសមកពីទីក្រុងភ្នំពេញ និងខេត្តមួយចំនួនទៀតដែលទើបតែត្រូវបានជម្លៀសមកកាន់ស្រុកបាកាន បានចូលមកស្នាក់នៅទីនេះជំនួសវិញ ។ នៅខែមេសា ឆ្នាំ១៩៧៧ គណៈកងស្រែប្រាំងឈ្មោះ វិញ បានមកចាប់ខ្លួន វ៉ន នៅពេលដែលគាត់កំពុងធ្វើការនៅក្នុងកងដឹកជញ្ជូន ដោយចោទប្រកាន់ថាជាខ្មាំងលួចដឹកជញ្ជូនស្រូវរបស់អង្គការ ។ វ៉ន បានបដិសេធការចោទប្រកាន់នេះ ប៉ុន្តែទីបំផុត គាត់ត្រូវបានចាប់ចងរួចបណ្តើរចេញទៅកាន់គុកត្រាចក្រោល ។ ពេលទៅដល់ក្នុងគុកភ្លាម វ៉ន បានឃើញអ្នកទោសជាច្រើននាក់កំពុងជាប់ខ្នោះជាជួរៗនៅក្នុងរោងឃុំឃាំង ដោយក្នុងមួយជួរៗមានអ្នកទោសប្រហែល១០នាក់ និងឃើញមានច្រវាក់រាប់រយខ្សែសម្រាប់ទាក់កជើងរបស់អ្នកទោស ។ វ៉ន បានឃើញមនុស្សស្លាប់ជារៀងរាល់ថ្ងៃ ។ នៅឆ្នាំ១៩៧៩ ឌី ដែលជាប្រធានគុកបានដោះលែង វ៉ន ហើយអនុញ្ញាតឲ្យគាត់ត្រឡប់ទៅរស់នៅភូមិកំណើតរបស់គាត់វិញ បន្ទាប់ពីកងសន្តិសុខស៊ើបដឹងថាគាត់ពុំបានលួចស្រូវដូចការចោទប្រកាន់ទេ ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ គុកត្រាចក្រោលបានក្លាយទៅជាភូមិត្រាចក្រោល ដែលមានប្រជាជនរស់នៅយ៉ាងច្រើនកុះករ ។ ទោះជាយ៉ាងនេះក្តី ប្រជាជនដែលធ្លាប់ដឹងរឿងរ៉ាវគុកត្រាចក្រោលបានចងចាំប្រវត្តិនេះទុកក្នុងចិត្ត និងបាននិយាយប្រាប់កូនចៅរបស់ខ្លួនពីអ្វីដែលបានកើតឡើង និងពីការសម្លាប់មនុស្សអស់យ៉ាងច្រើននៅក្នុងទឹកដីភូមិត្រាចក្រោលកាលពីជំនាន់ខ្មែរក្រហម ។ រណ្តៅជាច្រើនត្រូវបានគាស់ឡើងកាលពីអំឡុងឆ្នាំ១៩៧៩-១៩៨០ ដើម្បីរកមាសនិងវត្ថុមានតម្លៃ ហើយឆ្អឹងជាច្រើនបានត្រូវប្រជាជនដឹកជញ្ជូនយកទៅដាក់តម្កល់នៅក្នុងមន្ទីរឃុំបឹងខ្នារសម្រាប់គោរពបូជា ។

**ទេស ម៉ារ៉ែម និង ផេង ពង្សរ៉ាស៊ី**

## ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញាចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហម សូមទាក់ទង ស៊ិរិសាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

**សូមអរគុណ**

# គេចពីការសម្លាប់របស់ខ្មែរក្រហម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានប្រជាជនណាម្នាក់ហ៊ានប្រឆាំង ឬជំទាស់នឹងបញ្ជារបស់អង្គការឡើយ ។ ខុសប្លែកពីអ្នកទាំងនោះ លោក ខៀវ រិទ្ធី ដែលសព្វថ្ងៃជានាយករងនៅវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរ បានរៀបរាប់ឲ្យដឹងថា ឪពុករបស់គាត់ បែរជាហ៊ានរត់គេចខ្លួនក្រោយពីដឹងថាខ្មែរក្រហមនឹងចុះមកចាប់គាត់យកទៅសម្លាប់ ។ តើហេតុអ្វីបានជាឪពុករបស់ រិទ្ធី សម្រេច ចិត្តបែបនេះ?

មុនឆ្នាំ១៩៧៥ គ្រួសាររបស់ រិទ្ធី រស់នៅភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ។ ក្រោយពីខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ គ្រួសាររបស់ រិទ្ធី ត្រូវបានជម្លៀសទៅតាមផ្លូវរទេះភ្លើងរហូតទៅដល់ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។ តាមផ្លូវធ្វើដំណើរ គ្រួសាររបស់ រិទ្ធី បានឃើញកងឈ្លបជាច្រើននាក់ឈរយាមនៅតាមផ្លូវដែលមានមានចម្ងាយឆ្ងាយពីគ្នាប្រហែលជា១០ម៉ែត្រ ដើម្បីឆែកឆេរអីវ៉ាន់របស់ប្រជាជន ។

ទៅដល់ទីនោះភ្លាម គ្រួសាររបស់ រិទ្ធី ដែលមានសមាជិកចំនួន៦នាក់ត្រូវបានចាត់តាំងឲ្យស្នាក់នៅក្នុងផ្ទះមួយ ។ បន្ទាប់មកខ្មែរក្រហមក៏បែងចែកឲ្យប្រជាជនដែលជម្លៀសទាំងអស់ធ្វើការនៅតាមកងរៀងៗខ្លួន ។ ម្តាយរបស់ រិទ្ធី បានរៀបរាប់ឲ្យគាត់ដឹងថា នៅទីនោះខ្មែរក្រហមបានបង្ខំឲ្យប្រជាជនធ្វើការស្ទើរគ្មានពេលសម្រាក និងឲ្យហូបតែបបររាវដែលមានតែគ្រាប់អង្ករបីបួនគ្រាប់ប៉ុណ្ណោះ ក្រោយមកក៏បណ្តាលឲ្យប្រជាជនមួយចំនួនបានធ្លាក់ខ្លួនឈឺស្ទើរគ្រប់គ្នា ។ ចំណែកការព្យាបាលវិញ គឺមានតែថ្នាំអាចម៍ទន្សាយប៉ុណ្ណោះ ដូច្នេះអ្នកដែលកើតជំងឺនេះភាគច្រើនបានត្រូវស្លាប់តែម្តង ។ លើសពីនេះទៅទៀត ទោះបីជាអ្នកទាំងនេះមិនស្លាប់ដោយសារជំងឺ ក៏ខ្មែរក្រហមយកទៅសម្លាប់ដែរ ។

ជាក់ស្តែង នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់ផ្តើមយកប្រុសៗដែលពេញកម្លាំងជាមេគ្រួសារទៅសម្លាប់ចោលនៅវេលាយប់ ។ រិទ្ធី បានបន្តថា ពេលនោះ ម្តាយរបស់គាត់បានឃើញខ្មែរក្រហមបីបួននាក់មានស្ពាយកាំភ្លើងផងដើរសំដៅមកផ្ទះប្រជាជន រួចប្រាប់ថាយកទៅរៀនសូត្រ ។ សកម្មភាពនេះមានបន្តរហូតដោយថ្ងៃបន្ទាប់កងឈ្លបទាំងនោះនឹងដើរមកយកមនុស្សនៅផ្ទះអ្នកបន្ទាប់ទៀត ដែលប្រជាជននៅក្នុងភូមិទាំងអស់សុទ្ធតែដឹងថាអ្នកទាំងនោះប្រាកដជាស្លាប់ហើយ ហើយគ្មាននរណាម្នាក់ហ៊ានសួរអង្គការទេ ។ រិទ្ធី នៅចាំបានថា ឪពុករបស់គាត់ក៏បានបាត់ខ្លួន នៅពេលនោះដែរ ដោយនៅយប់ដល់វេនដែលខ្មែរក្រហមត្រូវមកយកឪពុករបស់គាត់ទៅរៀនសូត្រ គាត់បានជំនុំគ្នាជាមួយបងប្អូនប្រុសៗរបស់គាត់បីនាក់ទៀតថា "បើទៅតាមខ្មែរក្រហមមានតែស្លាប់ ដូច្នេះគឺមានតែរត់ទេទើបអាចមានជីវិតត្រឡប់មកវិញ" ។ ក្រោយពីពិភាក្សាគ្នារួច ម្តាយរបស់ រិទ្ធី បានដាំបបរដាក់កាមែលដើម្បីឲ្យឪពុករបស់គាត់រត់គេច ។ ប៉ុន្តែក្តីសង្ឃឹមថាពេលប្រទេសរំដោះហើយនឹងបានជួបគ្នាវិញ មកដល់ពេលនេះយើងមិនដែលបានទទួលដំណឹងពីគាត់ ព្រមទាំងបងប្អូនបីនាក់ទៀតរបស់គាត់បន្តិចឡើយ ។

ក្រោយហេតុការណ៍នេះ គ្រួសាររបស់ រិទ្ធី ត្រូវស្ថិតនៅក្រោមការតាមដានរបស់អង្គការជានិច្ច ហើយថែមទាំងត្រូវផ្លាស់ឲ្យទៅរស់នៅកន្លែងថ្មីមួយទៀត ។ នៅទីនោះ ខ្មែរក្រហមបានបញ្ជាឲ្យម្តាយរបស់ រិទ្ធី លើកទំនប់ ជីកប្រឡាយ តាំងពីព្រឹកព្រលឹមរហូតដល់ម៉ោង៩យប់ ទើបអាចសម្រាកបាន ។ ក្រោយមក ដោយសារម្តាយរបស់ រិទ្ធី ធ្វើការបានល្អ គាត់ក៏ទទួលបានការទុកចិត្តពីអង្គការ ហើយថែមទាំងអនុញ្ញាតឲ្យគាត់បានមកលេងផ្ទះបានមួយថ្ងៃនៅក្នុងរយៈពេលមួយសប្តាហ៍ និងឲ្យបងស្រីរបស់គាត់មកសម្រាកព្យាបាលជំងឺនៅផ្ទះរហូតដល់ជាសះស្បើយ ទើបបញ្ជូនទៅកងវិញ ។ ប៉ុន្តែ ទោះបីយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែដើរតាមដាននៅតាមផ្ទះជារៀងរាល់យប់ ខ្លាចក្រែងប្រជាជនលួច ហូបផ្លែឈើ ឬដំឡូងអង្គការជានិច្ច ។ រិទ្ធី បន្តថា យប់មួយ ពេលដែលម្តាយរបស់គាត់លួចគាស់ដំឡូងជ្វាយកមកស្ងោរហូប ស្រាប់តែឈ្លបមកឃើញ ។ ដោយសារតែភ័យខ្លាំងពេក យប់នោះម្តាយរបស់គាត់សម្រាន្តមិនលក់ទេ ព្រោះគិតថាច្បាស់ជាអង្គការយកទៅសម្លាប់ជាមិនខាន ។ ប៉ុន្តែ ព្រលឹមឡើង អង្គការបែរជាមិន

យកទោសពៃរ៍អ្វីឡើយ ដោយគ្រាន់តែហៅទៅកសាងប៉ុណ្ណោះ រួចនិយាយថា "របស់ទាំងអស់ហ្នឹងជារបស់អង្គការមិនមែនជារបស់យើងទេ មានការអីត្រូវសុំអង្គការ ប្រសិនបើហាមហើយនៅតែមិនស្តាប់នោះនឹងយកទៅសម្លាប់ចោលជាមិនខាន" ។ ចំណែកក្មួយរបស់ម្តាយ រិទ្ធី ឈ្មោះ កាន បានលួចកាប់អំពៅនៅពេលថ្ងៃ ពេលដែលអង្គការចាប់បាន ក៏យកគាត់ទៅធ្វើទារុណកម្មបន្ទាប់មកចងគាត់នៅចម្ការតែម្នាក់ឯងទៀត ។ ចាប់តាំងពីពេលនោះមក កាន មិនដែលហ៊ានលួចទៀតឡើយ ។

នៅឆ្នាំ១៩៧៨ ដោយសារតែមេកងស្រឡាញ់ម្តាយរបស់ រិទ្ធី គាត់ស្រាប់តែត្រូវបានអង្គការតែងតាំងឲ្យធ្វើជាមេចុងភៅ ។ ការឡើងឋានៈនេះ បានធ្វើឲ្យម្តាយរបស់ រិទ្ធី មានការព្រួយបារម្ភជាខ្លាំងខ្លាចខ្មែរក្រហមយកគាត់ទៅសម្លាប់ ដោយសារតែគាត់មិនបានស្រឡាញ់មេកងនោះទេ ។ នៅឆ្នាំ១៩៧៩ គ្រួសាររបស់ រិទ្ធី នាំគ្នាធ្វើដំណើរត្រឡប់មករស់នៅក្រុងភ្នំពេញវិញ ។ ដោយសារតែផ្ទះរបស់ រិទ្ធី ត្រូវបានរុះរើអស់ ដូច្នេះម្តាយរបស់គាត់ក៏នាំកូនៗមករស់នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាមវិញ ។ តាមផ្លូវធ្វើដំណើរក្រុមគ្រួសារ របស់ រិទ្ធី នាំគ្នាស្វែងរកដំណឹងពីឪពុករបស់គាត់រហូត ប៉ុន្តែនៅតែគ្មានបានដំណឹងពីគាត់ទាល់តែសោះ ។

នៅឆ្នាំ១៩៨៥ រិទ្ធី ក៏ផ្លាស់មករៀននៅក្រុងភ្នំពេញវិញ ។ ដោយសារតែស្រឡាញ់មុខវិជ្ជាប្រវត្តិវិទ្យា និងចង់បង្រៀនឲ្យក្មេងជំនាន់ក្រោយដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ក្រោយពីប្រឡងជាប់ទុតិយភូមិ រិទ្ធី ក៏បានដាក់ពាក្យប្រឡងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្នែកប្រវត្តិវិទ្យា ។ នៅឆ្នាំ១៩៩៨ រិទ្ធី ត្រូវបានចាត់តាំងឲ្យមកធ្វើគ្រូបង្រៀននៅវិទ្យាល័យប៊ុនរ៉ានី-ហ៊ុនសែនរលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ដោយសារតែ រិទ្ធី បង្រៀនបានល្អ និងទទួលបានការស្រឡាញ់ពីគ្រូបង្រៀនផ្សេងទៀត នៅឆ្នាំ២០០៧ គាត់ត្រូវបានតែងតាំងឲ្យធ្វើជានាយករងនៅវិទ្យាល័យនេះតែម្តង ។ រិទ្ធី យល់ថា ការបង្រៀនអំពីរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ ពិតជាមានសារសំខាន់ និងមានប្រយោជន៍ជាខ្លាំងសម្រាប់កូនខ្មែរជំនាន់ក្រោយ ដើម្បីកុំឲ្យប្រព្រឹត្តអំពើបែបនេះទៀត ជាពិសេសទន្ទឹមពេលដែលតុលាការកំពុងតែកាត់ទោសមេដឹកនាំខ្មែរក្រហមផង ។ **គាត លក្ខិណា**



ការវិលត្រឡប់របស់អ្នកភូមិក្នុងឆ្នាំ១៩៧៩

# សុក្រិត្យ : ខ្មែរក្រហមអាក្រក់ផង ល្អផង

កាលពីវ័យកុមារ ខ្ញុំតែងគិតថា រឿងរ៉ាវខ្មែរក្រហមដែលខ្ញុំបានឮពីឪពុកម្តាយ អ្នកជិតខាង និងពីសាលារៀនគឺជារឿងប្រឌិត ។ ខ្ញុំមិនដែលជឿនូវអ្វីដែលឪពុកម្តាយរបស់ខ្ញុំប្រាប់ខ្ញុំទេ ហើយខ្ញុំយល់ថាឈ្មោះ ប៉ុល ពត, អៀង សារី និង ខៀវ សំផន គឺគ្រាន់តែជាឈ្មោះដែលប្រជាជនទូទៅហៅសម្រាប់ជនក្បត់ជាតិប៉ុណ្ណោះ ។ ខ្ញុំមិនជឿរឿងរ៉ាវរបស់ខ្មែរក្រហមទេ ពីព្រោះវាជារឿងមួយដែលពិបាកនឹងជឿណាស់សម្រាប់ខ្ញុំ ។ អ្វីដែលខ្ញុំបានឮគឺសុទ្ធតែទាក់ទិននឹងភាពអត់ឃ្លាន ការសម្លាប់ ទុក្ខលំបាកវេទនា ការបង្ខំឲ្យធ្វើការហួសកម្លាំង ការប្រមាថ ជេរប្រទេច និងការស្តីបន្ទោស ។ គ្មានភ័ស្តុតាងណាមួយបន្សល់ទុកឲ្យធ្វើការសិក្សាក្រៅពីការរៀបរាប់និងរូបគំនូរដែលមាននៅក្នុងសៀវភៅសិក្សានៅសាលារៀននោះឡើយ ។ ក្រោយមកនៅដើមឆ្នាំ១៩៩០ ផ្ទះរបស់ខ្ញុំដែលមានទីតាំងនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ត្រូវទទួលរងការខូចខាតដោយសារការបាញ់គ្នារវាងកងទ័ពព្រៃខ្មែរក្រហមជាមួយនឹងកងទ័ពរាជរដ្ឋាភិបាល ។ ប៉ុន្តែ ខ្ញុំនៅតែគិតថាវាគ្រាន់តែជាក្រុមប្រឆាំងនឹងរាជរដ្ឋាភិបាលដែលគេហៅថាកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៩៩ ខ្ញុំបានដឹងពីការពិតតាមរយៈការអានសៀវភៅជាច្រើនក្បាលដែលត្រូវបានសរសេរ និងប្រើប្រាស់នៅអំឡុងរបបខ្មែរក្រហម និងតាមរយៈការរុករកចម្លើយសារភាព និងបញ្ជីឈ្មោះអ្នកទោសនៅគុកទួលស្លែង ។

ចាប់តាំងពីឆ្នាំ២០០៥មក អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអប់រំបានខិតខំប្រឹងប្រែងបញ្ជ្រាបប្រវត្តិសាស្ត្រស្តីពីខ្មែរក្រហមដល់សាធារណជន ជនរងគ្រោះ អ្នករស់រានមានជីវិត ក្រុមអ្នកសាសនានិងយុវជន ។ គម្រោងផ្សព្វផ្សាយអប់រំនិស្សិតគឺជាកម្មវិធីមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៥ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងអប់រំយុវជនពីរបបកម្ពុជាប្រជាធិបតេយ្យនិងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។ គម្រោងនេះត្រូវបានរៀបចំឡើង និងអនុវត្តសកម្មភាពជាច្រើនបែបដើម្បីបង្កើនការយល់ដឹងរបស់សាធារណជនពីប្រវត្តិសាស្ត្រខ្មែរក្រហម រួមជាមួយនឹងដំណើរការកាត់ទោសខ្មែរក្រហមផងដែរ ។

ក្រុមផ្សព្វផ្សាយអប់រំនិស្សិតបានបំពេញកិច្ចការរបស់ខ្លួនជាមួយនឹងសិស្សវិទ្យាល័យ និងសកលវិទ្យាល័យទាំងស្ថាប័នរដ្ឋនិងឯកជនដោយផ្តោតលើសកម្មភាពមួយចំនួនរួមមានការបំពេញការងារស្ម័គ្រចិត្ត កម្មវិធីសិក្សាណែនាំពីប្រវត្តិសាស្ត្រខ្មែរក្រហម ច្បាប់និងកិច្ចព្រមព្រៀងរបស់អ.វ.ត.ក វិធីសាស្ត្រសម្ភាសន៍ ការសរសេររបាយការណ៍ និងដំណើរទស្សនកិច្ចសិក្សា ។

ដើម្បីផ្សព្វផ្សាយព័ត៌មានទៅដល់សិស្សនិស្សិតតាមរយៈការប្រើប្រាស់អនុសាសន៍ផ្សេងទៀត ក្រុមការងាររបស់យើងគ្រោងនឹងធ្វើដំណើរទស្សនកិច្ចទៅកាន់សាលារៀនជាច្រើនតាមខេត្តផ្សេងៗគ្នាក្នុងរយៈពេលមួយខែម្តងឬពីរខែម្តង ។ ដំណើរទស្សនកិច្ចនេះធ្វើឡើងដើម្បីជួបជាមួយសិស្សនិស្សិតដែលត្រូវបានជ្រើសរើសនិងដើម្បីរៀបចំដំណើរទស្សនកិច្ចតាមតំបន់ដោយនាំសិស្សនិស្សិតតាមសាលារៀនផ្សេងៗមកកាន់ទីក្រុងភ្នំពេញដើម្បីឲ្យគេបានចូលរួមតាមដានអង្គសវនាការនិងដំណើរទស្សនកិច្ចសិក្សាទីកន្លែងប្រវត្តិសាស្ត្រផ្សេងៗ ។ ខេត្តដំបូងដែលយើងបានជ្រើសរើសនោះគឺខេត្តកំពត ។ យើងបានរៀបចំដំណើរទស្សនកិច្ចនេះកាលពីពាក់កណ្តាលខែមីនា ឆ្នាំ២០១០ ។ តំបន់មួយចំនួននៅខេត្តកំពតនៅមានសភាពលំបាកក្នុងការធ្វើដំណើរនៅឡើយបើទោះបីជារយៈពេលជាង២៥ឆ្នាំក្រោយពីរបបខ្មែរក្រហមបានដួលរលំហើយក៏ដោយ ។ កាលពីខែមិថុនា ឆ្នាំ១៩៩៦ កងទ័ពព្រៃខ្មែរក្រហមបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនិងរបស់របររបស់ប្រជាជន ថែមទាំងចាប់ប្រជាជននៅកោះស្លារាប់រយនាក់ទៅព្រៃតាកែនធ្វើជាចំណាប់ខ្មាំងទៀតផង ។ លើសពីនេះទៅទៀត ជនជាតិបរទេសចំនួនបីនាក់ក៏ត្រូវបានចាប់ខ្លួនដោយកងទ័ពព្រៃខ្មែរក្រហមមកកាន់ភ្នំវល្លិ៍ និងសម្លាប់ចោលដែរ ។

ខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកឈូក នៅខេត្តកំពតជាមួយនឹងក្រុមការងាររបស់ខ្ញុំ លោក ដាត ពិសិដ្ឋ ដើម្បីធ្វើការជាមួយ

នឹងសិស្សានុសិស្សមួយក្រុមដែលត្រូវបានចាត់តាំងដោយគ្រូបង្រៀនភាសាបរទេសម្នាក់គឺលោក ម៉ាតធូ រូឡូ ដែលជាអ្នកធ្វើការស្ម័គ្រចិត្តឲ្យភ្នាក់ងារភីសខបកម្ពុជា ។ យើងបានទៅដល់វិទ្យាល័យហ៊ុន សែន ឈូក នៅរសៀលថ្ងៃទី១៧ ខែមីនា និងបានជួបជាមួយនឹងលោកស្រីនាយករង យឹក ញ៉ូន ។ ខ្ញុំបានគ្រោងជាមួយនឹងលោក ម៉ាតធូ ថានឹងឲ្យជនរស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ឬពីរនាក់និយាយរៀបរាប់ពីបទពិសោធន៍ និងរឿងរ៉ាវដែលអ្នកទាំងនោះចងចាំបំផុតកាលពីរបបខ្មែរក្រហមទៅកាន់សិស្សានុសិស្ស ។ ជាមួយគ្នានេះ អ្នកគ្រូបង្រៀនពីររូបដែលមានជីវិតរស់រានពីរបបខ្មែរក្រហមក៏មានចំណាប់អារម្មណ៍ចង់និយាយរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ផងដែរ ។

សិស្សានុសិស្សប្រមាណ៤០នាក់ចាប់ពីថ្នាក់ទី១០រហូតដល់ថ្នាក់ទី១២បានចូលរួមស្តាប់ក្រុមការងាររបស់ខ្ញុំ ។ ជាបឋមខ្ញុំចាប់ផ្តើមណែនាំឲ្យស្គាល់និងដឹងក្រុមការងាររបស់ខ្ញុំនិងគោលបំណងនៃដំណើរទស្សនកិច្ចនេះ ។ បន្ទាប់មក ខ្ញុំបានរៀបរាប់ពីប្រវត្តិខ្មែរក្រហម និងសំណុំរឿង០០២របស់ អ.វ.ត.ក ។ ខ្ញុំបានសួរទៅកាន់សិស្សានុសិស្សទាំងអស់នោះថាតើពួកគេជឿថារបបខ្មែរក្រហមពិតជាកើតមានមែនដែរទេ និងថាតើពួកគេធ្លាប់បានសិក្សាពីរបបនេះនៅក្នុងថ្នាក់ដែរឬទេ ។ សិស្សមួយចំនួនបានឆ្លើយថា ពួកគេជឿថាខ្មែរក្រហមពិតជាកើតមានមែនចាប់ពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ។ សិស្សទាំងនោះនិយាយថាពួកគេបានដឹងពីរបបខ្មែរក្រហមនេះតាមរយៈឪពុកម្តាយ សាច់ញាតិ និង គ្រូបង្រៀន ព្រមទាំងតាមទូរទស្សន៍និងវិទ្យុផងដែរ ។ តាមរយៈចម្លើយរបស់សិស្សទាំងអស់នេះ ខ្ញុំបានកត់សម្គាល់ឃើញថាពួកគេបានដឹងពីរឿងរ៉ាវរបស់ខ្មែរក្រហមច្រើនជាងរូបខ្ញុំកាលពីខ្ញុំមានអាយុស្របាលនេះដែរ ។ ពួកគេហាក់បីដូចជាមានប្រាជ្ញាឈ្លាសវៃគ្រាន់បើ ។

សិស្សានុសិស្សបានចោទសំណួរមួយចំនួនមកកាន់ក្រុមការងាររបស់ខ្ញុំដូចជា តើរបបខ្មែរក្រហមកើតឡើងនៅក្នុងប្រទេសកម្ពុជាដោយរបៀបណា? ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស? តើប្រជាជនអាចរួចរស់រានមានជីវិតតាមរបៀបណា? បន្ថែមពីលើនេះ គ្រូបង្រៀនបួនរូបបានចូលរួមចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនទៅកាន់សិស្សានុសិស្សនៅក្នុងថ្នាក់ ។ គ្រូបង្រៀនទាំងនោះរួមមានលោកគ្រូប្រវត្តិវិទ្យា ណែត កាប អាយុ៦៧ឆ្នាំ អ្នកគ្រូ យឹក ញ៉ូន អាយុ ៥៨ឆ្នាំ អ្នកគ្រូ សុខ ឡាងសាត អាយុ៥៩ឆ្នាំ និងអ្នកគ្រូ កុំ សារុន អាយុ ៥៧ឆ្នាំ ។ ក្រោយពីបានស្តាប់រឿងរ៉ាវនិងពិភាក្សាជាមួយនឹងគ្រូបង្រៀនទាំងបួនរូបរួចមក សិស្សានុសិស្សទាំងអស់ក៏ទទួលបានសៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា «អំពើប្រល័យពូជសាសន៍ៈ សារសំខាន់របស់សំណុំរឿងលេខ០០២» ម្នាក់មួយក្បាលព្រមទាំងសៀវភៅរបស់អ.វ.ត.ក ដែលមានចំណងជើងថា «ការណែនាំពីតុលាការកាត់ទោសខ្មែរក្រហម» ផង ។

នៅព្រឹកថ្ងៃទី១៨ មីនា យើងបាននាំសិស្សានុសិស្ស និងគ្រូបង្រៀនចំនួនបួនរូបទៅទស្សនាភ្នំល្អាង ។ យើងមានបំណងបង្ហាញសិស្សានុសិស្សពីមន្ទីរសន្តិសុខរបស់ខ្មែរក្រហមមួយកន្លែងដែលស្ថិតនៅក្បែរភូមិនោះ ។ ភ្នំល្អាងគឺជាទីកន្លែងដ៏ស្រស់ស្អាតស្ថិតនៅភូមិល្អាង ឃុំល្អាង ស្រុកដងទង់ (អតីតស្រុកឈូក) ដែលមានចម្ងាយ១៥គីឡូម៉ែត្រពីវិទ្យាល័យ ហ៊ុន សែន ឈូក ។ ល្អាងនៅក្នុងភ្នំល្អាងនេះត្រូវបានប្រើប្រាស់សម្រាប់ឃុំខ្លួនប្រជាជន «ថ្មី» ឬក៏ «ប្រជាជន១៧មេសា» និងទាហាន មន្ត្រី ប៉ូលិស របស់លន់ នល់ ចាប់ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ តំបន់ដែលនៅជុំវិញភ្នំនេះត្រូវបានហ៊ុមព័ទ្ធដោយរណ្តៅសម្លាប់មនុស្សរាប់រយ បានគ្របដណ្តប់ទៅដោយទឹកនិងវាលស្រែ ។ លលាដ៍ក្បាលប្រមាណ៣២៥ភ្ជាប់ជាមួយនឹងរបស់របរសេសសល់ត្រូវបានកាយចេញពីរណ្តៅទាំងអស់នេះ ។ បច្ចុប្បន្ននេះ លលាដ៍ក្បាលទាំងនេះត្រូវបានតម្កល់នៅបូជនីយដ្ឋានវត្តស៊ឹង ក្នុងស្រុកឈូក ។

សិស្សានុសិស្សមិនអាចចូលទៅទស្សនានៅក្នុងល្អាងបានទេពីព្រោះថាតំបន់ទាំងមូលបានក្លាយជាទីតាំងផលិតស៊ីម៉ង់ត៍របស់ក្រុមហ៊ុនឯកជនមួយដែលមានឈ្មោះថាក្រុមហ៊ុនស៊ីម៉ង់ត៍ប៊ុនរ៉ុង ។ ដោយសារតែហេតុផលសន្តិសុខនេះ យើងមិនត្រូវបានអនុញ្ញាតឲ្យទៅក្បែរភ្នំ ឬដើរទស្សនាជុំវិញតំបន់នេះទេ ។ យើងអាចត្រឹមតែមើលទិដ្ឋភាពភ្នំល្អាង និងថតរូបពីរបងខាងក្រៅប៉ុណ្ណោះ ។

ក្រោយពីសម្រាកមួយរយៈពេលខ្លីមក យើងបានបន្តដំណើរពីល្អាងភ្នំទៅកាន់ទំនប់រំលេច ស្ថិតនៅក្នុងស្រុកជុំគិរី ក្នុងរយៈពេល

៣០នាទី ។ ទំនប់រំលេចនេះមានទទឹងប្រមាណជា១០ម៉ែត្រ ។ ទំនប់នេះត្រូវបានពង្រីកឲ្យធំក្នុងអំឡុងរបបខ្មែរក្រហមដោយការធ្វើពលិកម្មរបស់ប្រជាជនទាំងបង្ខំ ។ យោងតាមសម្តីរបស់គ្រូបង្រៀនពីររូបដែលបានចូលរួមលើកទំនប់នេះកាលពីរបបខ្មែរក្រហមបានឲ្យដឹងថា ទីកន្លែងនេះមានសភាពកខ្វក់និងពោរពេញទៅដោយសត្វរុយខ្មៅគ្រប់ទិសទីទាំងអស់ ។ មនុស្សរាប់រយនាក់បានស្លាប់បាត់បង់ជីវិតនៅទីនេះដោយសារការលើកទំនប់ទាំងបង្ខំ បាក់កម្លាំង ការអត់ឃ្លាន និងជំងឺ ។

បើសិនជាយើងមើលតែសំបកក្រៅ ភ្នំល្អាង និងទំនប់រំលេចនេះគឺជាកន្លែងដ៏ស្រស់ស្អាត ។ មានអ្នកទេសចរតិចតួចណាស់ដែលបានដឹងពីអាថ៌កំបាំង និងរឿងរ៉ាវសោកនាដកម្មដែលបានកប់យ៉ាងជ្រៅនៅពីក្រោមទិដ្ឋភាពដ៏ស្រស់បំព្រងនេះ ។ នៅពេលដែលយើងបានមកដល់ទំនប់រំលេច យើងមានអារម្មណ៍ស្រស់ថ្លាជាមួយនឹងខ្យល់ត្រជាក់ដែលបក់ខ្លាំងៗពីទិសខាងលិចមកបើទោះបីជារដូវនេះជារដូវក្តៅហើយស្ងួតក៏ដោយ ។ ខ្យល់បក់កាន់តែខ្លាំងទៅៗដែលធ្វើឲ្យយើងទាំងអស់គ្នាមានអារម្មណ៍ថានេះជារដូវស្លឹកឈើជ្រុះ ខណៈពេលដែលយើងឈរនៅលើទំនប់សម្លឹងទៅកាន់បឹងដ៏ធំមួយដែលនៅព័ទ្ធជុំវិញភ្នំ ។ ទំនប់រំលេចបានក្លាយជារមណីយដ្ឋានសម្រាប់ភ្ញៀវទេសចរដែលទាក់ទាញទាំងភ្ញៀវទេសចរក្នុងស្រុក និងបរទេសក្នុងឱកាសបុណ្យជាតិម្តងៗ ។ ជាទូទៅ ភ្ញៀវទេសចរអាចជិះទូកកម្សាន្តនៅក្នុងបឹងដ៏ស្ងប់នេះបាន ។ ទោះជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថាគ្មានព័ត៌មានសម្រាប់ផ្តល់ជូនភ្ញៀវទេសចរដែលអាចជួយលាតត្រដាងពីប្រវត្តិរបស់ទីកន្លែងដ៏ស្រស់ស្អាតនេះឡើយ ។

នៅពេលទៅដល់ទំនប់រំលេចនេះ សិស្សានុសិស្សត្រូវបានបែងចែកជាក្រុមតូចៗ ហើយអ្នកខ្លះដើរជាមួយនឹងគ្រូបង្រៀនរបស់គេ ។ ខ្ញុំបាននិយាយជាមួយនឹងសិស្សថ្នាក់ទី១០ម្នាក់ឈ្មោះ សុក្រិត្យ ។ ខ្ញុំបានសួរ សុក្រិត្យ ថាតើយល់យ៉ាងដូចម្តេចដែរចំពោះខ្មែរក្រហម? សុក្រិត្យ បានឆ្លើយថា «ខ្ញុំគិតថាខ្មែរក្រហមជាមនុស្សល្អផងនិងអាក្រក់ផង» ។ ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះសម្តីរបស់ សុក្រិត្យ ។ ដូច្នេះ ខ្ញុំបានសួរបន្ថែមទៀតថា តើអ្វីជាចំណុចល្អ និងអាក្រក់របស់ខ្មែរក្រហម ។ សុក្រិត្យ និយាយថា «ខ្មែរក្រហមអាក្រក់ត្រង់ថាពួកគេបង្ខំមនុស្សឲ្យធ្វើការរហូតដល់ស្លាប់ ប៉ុន្តែខ្មែរក្រហមជាមនុស្សល្អត្រង់ថាខ្មែរក្រហមមានគំនិតសាងសង់ទំនប់ដែលក្លាយជាទីកន្លែងគួរឲ្យចាប់អារម្មណ៍ ។ នេះជាកេរដំណែលរបស់ខ្មែរក្រហម» ។

មុននឹងចាប់ផ្តើមដំណើរទស្សនកិច្ចនេះ លោក ម៉ាតធូ បានបង្រៀនសិស្សានុសិស្សដែលបានចូលរៀនភាសាអង់គ្លេសជាមួយនឹងលោកពីពាក្យកាព្យ ហៃឃូ ។ លោក ម៉ាតធូ បានឲ្យសិស្ស ទាំងនោះសរសេរកំណាព្យហៃឃូចេញពីទស្សនៈរបស់ខ្លួនចំពោះខ្មែរក្រហម ។ សុក្រិត្យបាន សរសេរថា ៖

ខ្មែរក្រហមល្ងង់ ។
ខ្មែរក្រហមសម្លាប់មនុស្សស្លូតត្រង់ជាច្រើននាក់ ។
ដូច្នេះ ខ្មែរក្រហមឆ្កួត ។

ក្រុមផ្សព្វផ្សាយអប់រំនិស្សិតបានរៀបចំដំណើរទស្សនកិច្ច



ស្តីពីការអប់រំពីអំពើប្រល័យពូជសាសន៍ និងយុត្តិធម៌ដែលមានរយៈពេលយ៉ាងហោចណាស់មួយឆ្នាំមកហើយ ដើម្បីនាំសិស្សនិស្សិតចំនួន៣០០នាក់មកទស្សនាអគ្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទីកន្លែងសំខាន់នៅទីក្រុងភ្នំពេញ ។ អ្នកចូលរួមនៅក្នុងដំណើរទស្សនកិច្ចនេះនឹងត្រូវបែងចែកជាពីរក្រុម គឺសិស្សវិទ្យាល័យ និងនិស្សិតសកលវិទ្យាល័យនៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តផ្សេងៗ ។ ជាមួយគ្នានេះ ក្រោយពីដំណើរទស្សនកិច្ចនេះបញ្ចប់ទៅ ក្រុមការងាររបស់យើងទទួលបាននូវមតិយោបល់និងការយល់ឃើញយ៉ាងច្រើនពីសិស្សនិស្សិតទាំងអស់នេះ រួមមានរបាយការណ៍ស្តីពីដំណើរទស្សនកិច្ច រឿងខ្លីៗ ពាក្យស្លោក កំណាព្យសំបុត្រថ្លែងអំណរគុណ និងការស្នើសុំពីសំណាក់លោកគ្រូអ្នកគ្រូនិងសិស្សនិស្សិតដែលចង់ចូលរួមក្នុងដំណើរទស្សនកិច្ចនេះ ។

គោលបំណងរបស់គម្រោងនេះគឺដើម្បីផ្តល់ឱកាសឲ្យសិស្សនិស្សិតបានធ្វើការយល់ដឹងបន្ថែមអំពីដំណើរការវិវត្តទៅមុខរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈដំណើរទស្សនកិច្ចតាមទីតាំងអំពើប្រល័យពូជសាសន៍ដោយផ្ទាល់ក្រៅពីបានស្តាប់រឿងរ៉ាវអស់ទាំងនេះពីឪពុកម្តាយ សាច់ញាតិ អ្នកជិតខាង និងគ្រូបង្រៀនរបស់ខ្លួន ។ ទិសដៅនេះគឺធ្វើឡើងដើម្បីឲ្យយុវជនជំនាន់ក្រោយបន្តរក្សាការពារនិងលើកតម្កើងការចងចាំ និងមនុស្សធម៌របស់ប្រជាជនដែលទទួលរងទុក្ខវេទនាក្នុងរបបខ្មែរក្រហម ។ ដំណើរទស្សនកិច្ចនេះបានផ្តល់ឱកាសឲ្យសិស្សនិស្សិតដែលមកពីវិទ្យាល័យនិងសកលវិទ្យាល័យផ្សេងៗបានជួបសំណេះសំណាលនិងធ្វើការសិក្សាពីគ្នាទៅវិញទៅមក ចងមិត្តភាពនឹងគ្នាដើម្បីធ្វើឲ្យការយល់ដឹងពីប្រវត្តិសាស្ត្ររបស់កម្ពុជាកាន់តែធំទូលាយឡើង ។

**សេី សាយ្យណា**



# ប៊ូ ម៉េង : សៀវភៅដើម្បីការចងចាំ និង យុត្តិធម៌សង្គម




*សាមសិបឆ្នាំក្រោយមក ប៊ូ ម៉េង បានធ្វើដំណើរទៅមុខរហូតបញ្ឈប់កំហឹងសងសឹករបស់ខ្លួន។ នេះដោយសារតែអំពើប្រល័យសាសន៍ជាសកម្មភាពបែបនយោបាយ ហើយវានៅតែបន្តជារឿងរហូត។ អ្នកនិពន្ធៈ ហ៊ុយ វណ្ណៈ ចាប់ផ្ដើមការងារនៅឆ្នាំ១៩៩៩ ដោយធ្វើអ្នកស្រាវជ្រាវស្ដីអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងជួយកែសម្រួលអត្ថបទទស្សនាវដ្ដីស្វែងរកការពិតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបោះពុម្ពជារៀងរាល់ខែ។ ហ៊ុយ វណ្ណៈ ក៏ជាអ្នកសរសេរសៀវភៅ "កងពលខ្មែរក្រហមលេខ៧០៣ៈ ពីជ័យជម្នះទៅការបំផ្លាញខ្លួនឯង" បោះពុម្ពឆ្នាំ២០០៣ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ពីឆ្នាំ២០០៦-២០០៩ ហ៊ុយ វណ្ណៈ ជាសមាជិកក្រុមប្រឹក្សានិពន្ធនាយករបស់វិទ្យុអាស៊ីសេរី ដែលផ្សាយចេញពីទីក្រុងវ៉ាស៊ីនតោន។ លោកទទួលបន្ទុកគ្រប់គ្រងព័ត៌មានប្រចាំថ្ងៃនៅក្នុងទីក្រុងភ្នំពេញនិងប្រទេសដទៃទៀតនៅតំបន់អាស៊ីអាគ្នេយ៍ដែលទាក់ទងកិច្ចការរបស់ប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ២០១០ ហ៊ុយ វណ្ណៈ គឺជានាយកផ្សាយព័ត៌មានរបស់បណ្ដាញទូរទស្សន៍ឯកជន ស៊ីធីអិន ដែលជាស្ថានីយទូរទស្សន៍ដ៏មានប្រជាប្រិយភាពបំផុតក្នុងប្រទេសកម្ពុជា។ ហ៊ុយ វណ្ណៈ ទទួលសញ្ញាបត្រផ្នែកអក្សរសាស្ត្រខ្មែរពីសកលវិទ្យាល័យភូមិន្ទភ្នំពេញនៅប្រទេសកម្ពុជានិងទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកកិច្ចការអន្តរជាតិពីសកលវិទ្យាល័យរ៉ាត់ហ្គ័រ រដ្ឋញូវជើស៊ី សហរដ្ឋអាមេរិក។* **ឆាំង យុ**

*មជ្ឈមណ្ឌលឯកសារកម្ពុជាបានចេញផ្សាយសៀវភៅមួយទៀតក្នុងខែឧសភានេះ។ សៀវភៅនេះមានកម្រាស់៨០ទំព័រដែលសរសេរជាភាសាអង់គ្លេសមានចំណងជើងថា "ប៊ូ ម៉េង អ្នករស់រានមានជីវិតពីមន្ទីរស-២១ៈ យុត្តិធម៌សម្រាប់អនាគត មិនគ្រាន់សម្រាប់តែជនរងគ្រោះប៉ុណ្ណោះទេ" ។*

*បច្ចុប្បន្ន ប៊ូ ម៉េង គឺជាអ្នករស់រានមានជីវិតពីមន្ទីរស-២១ម្នាក់ក្នុងចំណោមបីនាក់ដែលនៅរស់រានមានជីវិតសព្វថ្ងៃ។ ហើយថ្មីៗនេះដែរ ប៊ូ ម៉េង បានប្រឈមមុខជាមួយ ឌុច ដែលជាប្រធានមន្ទីរស-២១ ហើយ ឌុច នេះហើយដែលជាអ្នកបង្ខំ ប៊ូ ម៉េង ឲ្យគូររូបរបស់ ប៉ុល ពត ដើម្បីជាថ្នូរនឹងការរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។ រូបគំនូររបស់ ប៉ុល ពត ដែលគូរដោយ ប៊ូ ម៉េង ត្រូវបានបោះពុម្ពក្នុងសៀវភៅនេះដែរ។ ថ្វីដ្បិតតែ ប៊ូ ម៉េង អាចរស់រានមានជីវិត ប៉ុន្តែប្រពន្ធរបស់គាត់ដែលជាប់នៅមន្ទីរស-២១នេះដូចគ្នា មិនមានវាសនាដូចជាគាត់ទេ។ អ្នកនិពន្ធ ហ៊ុយ វណ្ណៈ បានជួប ប៊ូ ម៉េង លើកដំបូងនៅខែមករាឆ្នាំ២០០៣ ក្រោយពេលដែលប៊ូ ម៉េង ចាប់ផ្ដើមបង្ហាញខ្លួនជាសាធារណៈលើកដំបូង ហើយបានចាប់ផ្ដើមសិក្សាពីជីវិតរបស់គាត់រហូតមក។ ហ៊ុយ វណ្ណៈ បានស្គាល់នូវការឈឺចាប់ ភាពរីករាយ និងភាពមិនសងសឹកនៃជីវិតផ្ទាល់ខ្លួនរបស់ ប៊ូ ម៉េង។ ទោះធ្លាប់រស់នៅដោយភាពឈឺចាប់ពីអតីតកាល ប៊ូ ម៉េង នៅតែអាចធ្វើដំណើរទៅមុខជានិច្ច ហើយជម្នះនូវទ្រឹស្ដីមិនសងសឹកចំពោះជនដៃដល់ ជាពិសេស ឌុច។ សៀវភៅនេះគឺជាសារណាថ្នាក់អនុបណ្ឌិតរបស់ ហ៊ុយ វណ្ណៈ ហើយក្រោយមកបានយកគាត់តែង កែលម្អបន្ថែមដើម្បីបោះពុម្ពផ្សាយចេញជាសៀវភៅនេះ។ សៀវភៅនេះគឺជាការរៀបរាប់អំពីការចងចាំរបស់ជនរងគ្រោះម្នាក់ដែលត្រូវបានសរសេរជាសៀវភៅសម្រាប់ការចងចាំក្នុងរយៈកាលយូរអង្វែងទៅថ្ងៃអនាគត។*

**ញាណ សុជាតិ**

# គម្រោងជួយជនរងគ្រោះ ៖ ការចូលរួមដ៏មានអត្ថន័យ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានស្គាល់ច្បាស់ថាជាតុលាការខ្មែរក្រហម នៅពេលនេះកំពុងតែបោះជំហានទៅមុខឆ្ពោះទៅកាន់ដំណើរការនីតិវិធីកាត់ទោសក្នុងសំណុំរឿងព្រហ្មទណ្ឌ០០២ ដែលក្នុងនោះមានមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់នៅរស់ចំនួន៤នាក់ ដែលនឹងត្រូវនាំយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងកាលពីអំឡុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកគេ ។ នៅក្នុងរយៈពេលត្រឹមតែបីឆ្នាំប្រាំបីខែម្ភៃថ្ងៃប៉ុណ្ណោះ របបដ៏យង់ឃ្នងនេះបានសម្លាប់ជីវិតមនុស្សច្រើនជាង ១,៧ លាននាក់ ។ អ្វីដែលគួរឲ្យសោកស្តាយនោះគឺថា រយៈពេល៣០ឆ្នាំក្រោយពេលដែលឧក្រិដ្ឋកម្មនេះបានកើតឡើង ទើបតុលាការកាត់ទោសនេះលេចចេញជារូបរាងឡើង ។ ទោះបីជាយ៉ាងនេះក្តី តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះគឺជាក្តីសង្ឃឹមតែមួយគត់សម្រាប់អ្នករួចរស់ពីរបបខ្មែរក្រហមទាំងអស់ឲ្យមានឱកាសទទួលបាននូវយុត្តិធម ដែលចុងបញ្ចប់នឹងត្រូវបានផ្តល់ឲ្យពួកគាត់ជាមិនខាន ។ ជាពិសេសទៅទៀត ដោយសារតែតុលាការនេះត្រូវបានស្ថាបនាឡើងក្នុងគោលបំណងសំខាន់បំផុតគឺរកយុត្តិធម៌ជូនដល់ជនរងគ្រោះទាំងអស់ ដូច្នេះហើយដំណើរការដ៏លំបាកនេះនឹងក្លាយទៅជាគ្មានន័យប្រសិនបើការចូលរួមរបស់ជនរងគ្រោះមិនត្រូវបានយកចិត្តទុកដាក់ និងអើពើនោះទេ អ្វីសំខាន់នោះគឺថា ប្រសិនបើគ្មានការចូលរួមមួយដ៏មានអត្ថន័យពីសំណាក់ជនរងគ្រោះទាំងអស់ដែលទន្ទឹងរង់ចាំរកយុត្តិធម៌អស់រយៈពេលជាយូរណាស់មកហើយរហូតស្ទើរតែនឹងអស់សង្ឃឹមទៅហើយនោះ ។

ក្នុងគោលបំណងលើកតម្កើនការចូលរួមមួយដ៏ជិតស្និទ្ធ និងមានអត្ថន័យពីសំណាក់ប្រជាជនកម្ពុជាទាំងឡាយ នៅក្នុងដំណើរការកាត់ទោសរបស់តុលាការខ្មែរក្រហមនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានខិតខំប្រឹងប្រែងក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកភូមិ ដើម្បីបង្កើនការចាប់អារម្មណ៍របស់ពួកគាត់ចំពោះការងាររបស់តុលាការនិងដើម្បីជូនដំណឹងដល់ពួកគាត់ស្តីពីព័ត៌មានទាំងឡាយដែលទាក់ទងនឹងតុលាការនេះ ។ ក្នុងការគាំទ្រនូវកិច្ចខំប្រឹងប្រែងនេះផងដែរ គម្រោងជួយជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើននូវសកម្មភាពជាច្រើន ដែលក្នុងចំណោមសកម្មភាពដែលទើបតែរៀបចំឡើងថ្មីៗនេះ គឺការជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជ្រើសរើសអ្នកតំណាងផ្នែកច្បាប់ (ការជ្រើសតាំងមេធាវីតំណាងផ្នែកច្បាប់) ។

ដោយសារតែការទទួលស្គាល់អំពីសារសំខាន់នៃដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ដែលនឹងខិតជិតមកដល់នេះ គម្រោងជួយជនរងគ្រោះបានរៀបចំកិច្ចប្រជុំលើកទីមួយរបស់ខ្លួននៅថ្ងៃទី១៧-១៩ ខែមីនា ជាមួយនឹងជនរងគ្រោះទាំងអស់ដែលគម្រោងនេះបានចុះទៅជួយប្រជាជនក្នុងការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២នេះ ។ ជាសរុប ក្នុងកិច្ចប្រជុំលើកទីមួយនេះ មានដើមបណ្តឹងរដ្ឋប្បវេណីមកចូលរួមចំនួន៤៧នាក់ ដែលអញ្ជើញមកពីបណ្តាខេត្តក្រុងដូចជា កំពង់ចាម កណ្តាល សៀមរាប តាកែវ បន្ទាយមានជ័យ និងភ្នំពេញ ។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងធ្វើការណែនាំដល់ដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានការស្វែងយល់អំពីប្រវត្តិសង្ខេប និងសមត្ថភាពរបស់ក្រុមមេធាវីទាំងអស់ដែលនឹងធ្វើជាអ្នកតំណាងផ្នែកច្បាប់នៅក្នុងសំណុំរឿង០០២នេះ ។ ការធ្វើបែបនេះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចធ្វើការសម្រេចចិត្តដ៏ជាក់លាក់ត្រឹមត្រូវមួយក្នុងការជ្រើសតាំងមេធាវីតំណាងរបស់ខ្លួន ។ ការជ្រើសតាំងមេធាវីតំណាងផ្នែកច្បាប់គឺជារឿងមួយដ៏សំខាន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដោយសារតែនៅក្នុងដំណើរការនីតិវិធីទាំងមូលនេះ មេធាវីតំណាងនេះជាអ្នកការពារផលប្រយោជន៍ និងជួយគ្រប់គ្រងវិសាលភាពនិងគុណភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការឲ្យកាន់តែមានអត្ថន័យ ។

ក្នុងកិច្ចប្រជុំនេះ ជាដំបូងលោក ឆាំង យុ នាយកមជ្ឈ

មណ្ឌលឯកសារកម្ពុជាជាអ្នកចាប់ផ្តើមកិច្ចសំណេះសំណាល ។ ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចប្រជុំនេះ លោកនាយកបានលើកឡើងពីប្រធានបទដែលមានសារសំខាន់សម្រាប់សំណុំរឿងព្រហ្មទណ្ឌ ០០២ មកពិភាក្សាជាមួយដើមបណ្តឹងទាំងអស់ ។ លោកនាយកបានបង្ហាញសៀវភៅព័ត៌មានពណ៌ក្រហមថ្មីមួយដែលទើបតែបោះពុម្ពឡើងដោយមជ្ឈមណ្ឌល ដែលក្នុងនោះបានផ្តល់នូវព័ត៌មានជាច្រើនស្តីពីសំណុំរឿងព្រហ្មទណ្ឌនេះ ជាពិសេសមានរូបរបស់មេដឹកនាំខ្មែរក្រហមទាំងបួននាក់ដែលនឹងត្រូវនាំយកមកកាត់ទោសនៅក្នុងករណី ០០២នេះផងដែរ ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីក៏ចាប់ផ្តើមសួរសំណួរ និងចែករំលែកគំនិត និងយោបល់របស់ខ្លួនទៅកាន់លោកនាយក ។ ក្រោយពេលដែលលោកនាយកបញ្ចប់ការសំណេះសំណាលជាមួយដើមបណ្តឹងរដ្ឋប្បវេណី លោក ជី ទេរិទ្ធ ប្រធានគម្រោងជួយជនរងគ្រោះចាប់បន្តកិច្ចពិភាក្សាស្តីពីព័ត៌មានសង្ខេបនិងសមត្ថភាពរបស់ក្រុមមេធាវីតំណាងផ្នែកច្បាប់ទាំងអស់នៅក្នុងសំណុំរឿង ០០២ នេះ ។

លោក ជី ទេរិទ្ធ បានផ្តល់ព័ត៌មានសង្ខេបរបស់ក្រុមមេធាវីនីមួយៗរួមមានដូចជា បទពិសោធន៍នៅក្នុងច្បាប់ព្រហ្មទណ្ឌ ប្រភពធនធាន ការផ្តោតសំខាន់ក្នុងផ្នែកផ្សេងៗរបស់ក្រុមនីមួយៗ ។ល។ ដោយសារតែមានការព្រួយបារម្ភថា ដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកក្នុងការចាប់យកព័ត៌មានដ៏ច្រើនទាំងនេះក្នុងរយៈពេលយ៉ាងខ្លីបែបនេះ ដូច្នេះហើយ បន្ទាប់ពីបទបង្ហាញភ្លាម គឺមានការបែងចែកដើមបណ្តឹងរដ្ឋប្បវេណីជាបីក្រុមដើម្បីផ្តល់ពេលវេលាបន្ថែមទៀតដល់ពួកគាត់ឲ្យធ្វើការពិនិត្យឡើងវិញអំពីបញ្ហានេះមុនពេលដែលពួកគាត់ធ្វើការសម្រេច ។ នៅក្នុងក្រុមនីមួយៗ មានវត្តមានសមាជិករបស់គម្រោងជួយជនរងគ្រោះម្នាក់នៅប្រចាំការដើម្បីជួយសម្របសម្រួលការពិភាក្សានេះក្នុងករណីចាំបាច់ ។ ដើមបណ្តឹងរដ្ឋប្បវេណីខ្លះមានការពេញចិត្តក្រុមមេធាវីរហូតដល់ទៅពីរក្រុមឯណោះ ដែលធ្វើឲ្យពួកគាត់មានការពិបាកក្នុងការសម្រេចចិត្ត ខណៈពេលដែលដើមបណ្តឹងរដ្ឋប្បវេណីខ្លះទៀតបានសម្រេចចិត្តជ្រើសតាំងមេធាវីរួចទៅហើយ ។ នៅពេលពួកគាត់ធ្វើការសម្រេចចិត្តរួចហើយនោះ ពួកគាត់នឹងចុះហត្ថលេខាលើលិខិតជ្រើសតាំងមេធាវីតំណាងផ្នែកច្បាប់របស់គាត់ ។

ម្យ៉ាងទៀត ក៏មានដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចដែលធ្លាប់បានជ្រើសតាំងមេធាវីតំណាងរបស់គាត់រួចហើយនោះបានធ្វើការស្នើសុំផ្លាស់ប្តូរអ្នកតំណាងផ្នែកច្បាប់របស់ខ្លួនដោយបញ្ជាក់ពីមូលហេតុថា កាលពីពេលដែលពួកគាត់ជ្រើសតាំងមេធាវីតំណាងមុនដំបូង ពួកគាត់ពុំមានព័ត៌មានលម្អិតផ្សេងៗទាក់ទងនឹងមេធាវីនោះទេ ។ ឥឡូវនេះ ដោយសារតែមានព័ត៌មានទាំងអស់នេះ ធ្វើឲ្យពួកគាត់មានអារម្មណ៍ថា ខ្លួនមានសិទ្ធិ និងមានសមត្ថភាពក្នុងការជ្រើសរើសមេធាវីផ្សេងដោយភាពជឿជាក់ ។

ការជ្រើសតាំងមេធាវីនេះបានចំណាយពេលអស់ទៅជិតមួយថ្ងៃ ។ បន្ទាប់ពីនេះ គម្រោងជួយជនរងគ្រោះក៏បានរៀបចំការបញ្ចាំងកុនឯកសារជូនដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ផងដែរ ដូចជាៈ «ការធ្វើទស្សនកិច្ចរបស់គណៈប្រតិភូវៀតណាមមកកាន់កម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥» «ភ្នំពេញនៅក្នុងឆ្នាំ១៩៧៩» និង «ការសុំខមាទោសរបស់ ឌុច និងប្រតិកម្មរបស់ប្រជាជន» ។ ដើមបណ្តឹងរដ្ឋប្បវេណីមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកុនឯកសារនេះ ជាពិសេសកុនទីបីដែលមើលទៅពួកគាត់ដូចជាមានប្រតិកម្មខ្លាំង ។ ខណៈពេលដែលកំពុងមើលកុន



កញ្ញា គ្រី ស៊ុយហៀង ឡើងពន្យល់អ្នកភូមិស្តីពីគម្រោងជួយជនរងគ្រោះដាក់ពាក្យ

ទីបីនោះ មានដើមបណ្ដឹងរដ្ឋប្បវេណីវ័យចំណាស់ម្នាក់បានបន្លឺសំឡេងថា «ខ្ញីមស្ដាប់ ឌុច សុំទោសណាស់» ។ ហើយមានដើមបណ្ដឹងរដ្ឋប្បវេណីខ្លះទៀតបែរទៅរកអ្នកដែលអង្គុយជិតគាត់ដើម្បីពិភាក្សានូវអ្វីដែលគាត់បានមើលឃើញនៅក្នុងកុនឯកសារនោះ ហើយម្នាក់ៗធ្វើការសម្ដែងចេញនូវការមិនពេញចិត្តយ៉ាងខ្លាំងដោយបញ្ចេញតាមរយៈទឹកមុខនិងសម្ដី ។

នៅពេលដែលកុនឯកសារបានបញ្ចាំងចប់ភ្លាម ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ចាប់ផ្ដើមធ្វើការចែករំលែកនូវការយល់ឃើញទៅវិញទៅមករៀងៗខ្លួន ។ តួយ៉ាងដូចជា ដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិអ៊ីស្លាមម្នាក់បានក្រោកឈរហើយនិយាយថា គាត់ខំសង្កត់ចិត្តស៊ូទ្រាំទទួលរងការឈឺចាប់នេះជាយូរណាស់មកហើយ រហូតទាល់តែនិយាយថា ខ្លួនគាត់មានការខឹង ហើយប្រកាន់យកទស្សនៈ «ឈាមសងដោយឈាម» ជាមិនខាន ប្រសិនបើគាត់រាល់ថ្ងៃនេះមិនរស់ «ក្រោមច្បាប់រដ្ឋ» នោះទេ ។ ដូច្នេះ ការសុំអភ័យទោសគ្មានប្រយោជន៍អ្វីនោះទេចំពោះគាត់ ។ ចំណែកឯដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ទៀតយល់ស្របនឹងមតិនេះ ហើយក៏បញ្ចេញយោបល់ថា ដោយសារតែរស់នៅក្រោមច្បាប់ហ្នឹងហើយទើបធ្វើឲ្យគាត់អត់ធ្មត់នឹងការឈឺចាប់ទាំងឡាយដែលគាត់



ទ្រាំទ្រអស់រយៈពេលយ៉ាងយូរមកហើយនោះ ។ ចំណែកដើមបណ្ដឹងរដ្ឋប្បវេណីវ័យចំណាស់ម្នាក់បានបន្ថែមទៀតថា នេះជារឿងមួយមិនសមហេតុសមផលនោះទេកាលដែលមនុស្សម្នាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏យង់ឃ្នងបែបនេះ ហើយបែរជាចុងក្រោយធ្វើការសុំអភ័យទោសពីព្រះ ឬក៏ពីជនរងគ្រោះទៅវិញ ។

ចំពោះដើមបណ្ដឹងម្នាក់វិញទៀតបានសំណូមពរថា សុំឲ្យតុលាការរៀបចំដំណើរការនីតិវិធីរបស់ខ្លួនឲ្យរហ័សបន្តិច ហើយកុំមានការពន្យារពេលឲ្យសោះមុនពេលដែលអ្វីៗត្រូវយឺតពេលអស់ដោយសារតែទាំងជនជាប់ចោទ និងជនរងគ្រោះសុទ្ធតែមានវ័យចាស់ជរាទៅហើយ ។ លោក ជី ទេរិទ្ធ បានឆ្លើយតបថា តុលាការរាល់ថ្ងៃពិតជាដឹងពីការលំបាកមួយនេះ ប៉ុន្តែសង្ឃឹមថាជនរងគ្រោះទាំងអស់នឹងយល់ពីការពិតដែលថាអ្វីៗទាំងអស់ខាងតុលាការត្រូវតែអនុលោមទៅតាមនីតិវិធីត្រឹមត្រូវរបស់តុលាការ បើមិនអ៊ីចឹងទេ តុលាការនេះនឹងក្លាយទៅជា «តុលាការក្លែងក្លាយ» មួយដែលមិនប្រព្រឹត្តទៅតាមនីតិវិធីច្បាប់ ។

ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលអញ្ជើញមកពីខេត្តកណ្ដាលបាននិយាយថា កិច្ចប្រជុំនេះពិតជាបានលើកទឹកចិត្តគាត់ឲ្យកាន់តែមានការជឿជាក់លើការចូលរួមរបស់គាត់យ៉ាងខ្លាំងដែលធ្វើឲ្យគាត់មានជំនឿចិត្តថាគាត់នឹងអាចទទួលបានយុត្តិធម៌ត្រឹមត្រូវបើទោះបីជាវាយូរយ៉ាងនេះក្ដី ពីព្រោះគាត់ជឿថាគាត់ក៏ដូចជាជនរងគ្រោះដទៃទៀតមិនត្រូវបានបំភ្លេចចោលនោះទេ ។ ជាមួយនឹងកិច្ចការងារនៃដំណើរការរបស់តុលាការនេះផងដែរធ្វើឲ្យគាត់មានអារម្មណ៍ថាការឈឺចាប់របស់គាត់ក៏ដូចជាជនរងគ្រោះទាំងអស់ត្រូវបានគេទទួលស្គាល់ និងដឹងឮទូទាំងសកលលោក ដែលធ្វើឲ្យជនរងគ្រោះម្នាក់ៗមានក្ដីសង្ឃឹមនិងសប្បាយរីករាយឡើងវិញ ។

កំហុសឆ្គងយ៉ាងធ្ងន់ធ្ងរ និងភាពអាណោចអាធ័មបំផុតរបស់របបខ្មែរក្រហមនេះពិបាកនឹងប៉ះប៉ូវឡើងវិញណាស់ ដោយសារតែវាបានចាក់ចូលយ៉ាងជ្រៅទៅក្នុងសាច់ដោយបន្កជារបួសស្នាមមួយដែលមិនអាចបំភ្លេចបាននៅក្នុងខ្លួនរបស់ប្រជាជនកម្ពុជាគ្រប់រូប ។ សាមសិបឆ្នាំក្រោយមក ថ្វីបើកម្ពុជាអាចជាសះស្បើយផ្នែករាងកាយក្ដី ប៉ុន្តែនៅតែពិការផ្លូវចិត្តនៅឡើយ ។ គ្រប់ពេលដែលនឹកគិតពីរបបនោះឡើងវិញ វាមានភាពរស់រវើកដូចរឿងដែលទើបនឹងកើតឡើងអ៊ីចឹង ។ អាស្រ័យហេតុនេះហើយ មានតែតាមរយៈការចូលរួមមួយដ៏មានអត្ថន័យពីសំណាក់ជនរងគ្រោះទាំងអស់ទេ ទើបអាចធ្វើឲ្យពួកគាត់ទាំងអស់គ្នាប្រឈមមុខដោះស្រាយនឹងអតីតកាលដ៏ឈឺផ្សារដែលមិនអាចបំភ្លេចបាននេះ និងដើម្បីប្រែក្លាយការឈឺចាប់ទាំងអស់នេះឲ្យទៅជាការចងចាំមួយជាប្រវត្តិសាស្ត្រ និងជាសកលជូនដល់មនុស្សជាតិទាំងអស់ ។

**គ្រី ស៊ុយហៀង**

# វេទិកាអ្នកភូមិនៅក្នុងខេត្តពោធិ៍សាត់ : ប្រតិកម្មចំពោះការកត់សម្គាល់របស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម

គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅខេត្តជាលើកទីពីរនៅក្នុងខែមីនា ឆ្នាំ២០១០ នៅឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ការចុះទៅតាមខេត្តលើកនេះធ្វើឡើងចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១០ និងមានគោលបំណងពង្រីងចំណេះដឹងពីការងាររបស់តុលាការខ្មែរក្រហមដល់សាធារណជន (ដែលតុលាការនេះគេដឹងជាទូចថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ក៏ដូចជាធ្វើឲ្យអ្នកភូមិយល់ដឹងអំពីដំណើរការវិវត្តរបស់តុលាការ និងបទល្មើសព្រហ្មទណ្ឌក្នុងសំណុំរឿង០០២ ។ ក្រុមការងារបានចុះទៅឃុំបឹងខ្នារនេះព្រោះអ្នកដែលមានលំនៅដ្ឋាននៅទីនោះមួយចំនួនត្រូវបានអញ្ជើញឲ្យចូលរួមសវនាការជាសាធារណៈរបស់ ឌុច ដែលមានសារសំខាន់សម្រាប់គាត់ក្នុងការយល់ដឹងពីសំណុំរឿងបន្ទាប់ទៀត ។ បន្ថែមលើនេះ ការចុះទៅខេត្តនេះ ជាគោលបំណងរយៈពេលយូររបស់គម្រោងឯកសាររស់ ដើម្បីគាំទ្រទៅដល់ធនធានមនុស្សសម្រាប់ចែកចាយព័ត៌មានថ្មីៗបន្ថែមទៀត ។ ទីតាំងឃុំនេះ អំណោយផលល្អសម្រាប់ការប្រជុំ ពីព្រោះវាស្ថិតនៅជិតអតីតគុករបស់ខ្មែរក្រហមដែលមានឈ្មោះថា «គុកត្រាចក្រោល» ដែលអ្នកភូមិជាច្រើនត្រូវបានបញ្ជូនទៅសម្លាប់នៅអំឡុងរបបខ្មែរក្រហម ។

នៅព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ នៅក្នុងសាលាឆាន់របស់វត្តព្រះម្លូរ ក្រុមការងារនេះបានជ្រើសរើសដើម្បីរៀបចំកិច្ចប្រជុំ និងបញ្ចាំងខ្សែភាពយន្ត ។ មានអ្នកភូមិប្រហែល២៣០នាក់បានចូលរួមស្តាប់លោកមេឃុំឈ្មោះ បឹង បេន ធ្វើការកត់សម្គាល់ និងផ្តាំផ្ញើអង្គប្រជុំឲ្យយកចិត្តទុកដាក់ទៅនឹងអ្វីដែលក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើកយកមកបង្ហាញ និងអ្វីដែលមាននៅក្នុងខ្សែភាពយន្តនេះ ។ លោក បឹង បេន បានពន្យល់អ្នកភូមិឲ្យមើលឃើញពីតម្លៃរបស់តុលាការនៅក្នុងការផ្តល់យុត្តិធម៌ទៅដល់ជនរងគ្រោះដែលបានស្លាប់ និងអ្នកនៅរស់រានមានជីវិតដែលបានទទួលរងការឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ស្ថិតនៅក្នុងការកត់សម្គាល់ដ៏មានអត្ថន័យនេះ លោកនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា វ៉ាន់ថាន់ ពៅដារ៉ា បានចំណាយពេលពីរបីនាទីដំបូង ដើម្បីបង្ហាញនូវការថ្លែងអំណរគុណដល់លោក បឹង បេន និងលោក អុក សំយ៉ុល សមាជិកក្រុមប្រឹក្សាឃុំដែលបានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីផ្តល់ឱកាសឲ្យមានការជួបប្រជុំ និងផ្តល់ទីកន្លែងដ៏សមរម្យសម្រាប់ក្រុមការងារបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានជួបជាមួយនឹងអ្នកភូមិ ។ បន្ទាប់មក លោក វ៉ាន់ថាន់ ពៅដារ៉ា និយាយពីគោលបំណងនៃការប្រជុំ និងការបញ្ចាំងខ្សែភាពយន្តនេះ ។ លោកបន្តថាការប្រជុំនេះនឹងផ្តល់នូវព័ត៌មានថ្មីៗអំពីការងារនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិង



លោក វ៉ាន់ថាន់ ពៅដារ៉ា ប្រជុំជាមួយអ្នកភូមិ នៅខេត្តពោធិ៍សាត់

ផ្សព្វផ្សាយកិច្ចពិភាក្សាសំណុំរឿង០០២ដែលទាក់ទងនឹងអតីតមេដឹកនាំខ្មែរក្រហមបួនរូបទៀតដែលនឹងត្រូវកាត់ទោសក្រោមច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

លោក វ៉ាន់ថាន់ ពៅដារ៉ា បានចាប់ផ្ដើមកិច្ចសន្ទនាដោយសួរសំណួរទៅកាន់អ្នកភូមិថាតើបងប្អូនណាខ្លះធ្លាប់បានទៅមើលតុលាការឬធ្លាប់តាមដានពីដំណើរការសវនាការទេ? មនុស្សប្រមាណ១០នាក់នៅក្នុងអង្គប្រជុំបានលើកដៃ រួចឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញពួកគេឲ្យចូលរួមសវនាការដំបូងរបស់ ឌុច ។ នៅក្នុងចំណោមអ្នកលើកដៃទាំងនោះ ក៏មានអ្នកភូមិមួយចំនួនធ្លាប់បានចូលរួមសវនាការកន្លះថ្ងៃ ដែលរៀបចំឡើងដោយអង្គជំនុំជម្រះជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផ្ទាល់ផងដែរ ។ ស្ត្រីម្នាក់ដែលធ្លាប់បានចូលរួមសវនាការបាននិយាយថា គាត់ធ្លាប់បានចូលរួមពិភាក្សាពីដំណើរការសវនាការជាមួយនឹងគ្រួសារ និងសមាជិកសហគមន៍របស់គាត់ ។ គាត់សង្ឃឹមថា ដំណឹងនៃការចូលរួមជាមួយនឹងអ្នកភូមិបីបួននាក់នោះ នឹងរីកសាយភាយទៅដល់សហគមន៍ទាំងមូលយ៉ាងមានប្រសិទ្ធភាព ។

ក្រោយមក លោក វ៉ាន់ថាន់ ពៅដារ៉ា បានពន្យល់ពីសំណុំរឿង០០១ ដែលទាក់ទងនឹងជនជាប់ចោទឈ្មោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតប្រធានគុកនៅមន្ទីរស-២១ បានបញ្ចប់ដំណាក់ការសវនាការផ្ទាល់មាត់ ហើយបច្ចុប្បន្នកំពុងពិចារណាទៅលើការប្រកាសសាលក្រម ។ លោកបន្តថា ការស្នើសុំចុងក្រោយរបស់សហព្រះរាជអាជ្ញា គឺសូមឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិចារណាដាក់ទោស ឌុច ឲ្យជាប់គុករយៈពេល៤០ឆ្នាំ ដោយយោងទៅលើការសហការរបស់ជនជាប់ចោទ ឌុច ជាមួយតុលាការក្នុងដំណើរការនីតិវិធី ។ ការប្រកាសនេះមិនត្រឹមតែលើកទឹកចិត្តឲ្យអ្នកមកចូលរួមតាមដានព័ត៌មាននៃការប្រកាសសាលក្រមសម្រាប់សំណុំរឿង០០១ប៉ុណ្ណោះទេ វាក៏បានផ្ដល់នូវមូលដ្ឋានសម្រាប់អ្នកភូមិដើម្បីឲ្យគាត់យកចិត្តទុកដាក់តាមដាន និងចូលរួមនៅក្នុងដំណើរការនីតិវិធីសម្រាប់ករណីសំណុំរឿង០០២ ។

បន្ទាប់ពីសង្ខេបប្រាប់អ្នកភូមិអំពីករណីរបស់ ឌុច រួចមក លោក វ៉ាន់ថាន់ ពៅដារ៉ា បាន បង្ហាញសៀវភៅបោះពុម្ពថ្មីៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺ អំពើប្រល័យពូជសាសន៍ និងសារសំខាន់នៃករណីសំណុំរឿង០០២ ដែលមានបង្ហាញរូបភាពនៃជនជាប់ចោទបួនរូប ជាអតីតមេដឹកនាំខ្មែរក្រហម ដែលរួមមានៈ អៀង សារី, អៀង ធីរិទ្ធ, ខៀវ សំផន, និង នួន ជា ។ លោក វ៉ានថាន់ ពៅដារ៉ា បានរៀបរាប់ប្រាប់អ្នកភូមិដោយសង្ខេបអំពីជីវប្រវត្តិរូបរបស់ជនជាប់ចោទ និងផ្ដល់នូវព័ត៌មានចាំបាច់ដើម្បីឲ្យយល់ពីសំណុំរឿង ។ ព័ត៌មាននៅក្នុងសៀវភៅណែនាំពីអង្គជម្រះវិសាមញ្ញ បានជួយផ្ដល់នូវចំណេះដឹងមួយចំនួនទៅកាន់អ្នកភូមិអំពីជនជាប់ចោទ និងឧក្រិដ្ឋកម្មដែលបានអះអាងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឯកសារទាំងនេះមិនត្រឹមតែជួយផ្ដល់នូវចំណេះដឹងជាមូលដ្ឋាននៃសំណុំរឿងប៉ុណ្ណោះទេ វាថែមទាំងពន្យល់អំពីអត្ថន័យដល់អ្នកនៅរស់រានមានជីវិតនៃរបបខ្មែរក្រហមឲ្យអាចចូលរួម និងតាមដានដំណើរការនីតិវិធីសំខាន់នេះ ។ បន្ទាប់មកទៀត លោកពន្យល់ពីមួយទំព័រទៅមួយទំព័រនៅក្នុងសៀវភៅថ្មីដែលថា មេដឹកនាំនីមួយៗនឹងត្រូវបានចោទប្រកាន់ និងបានលើកយកគោលសំខាន់ៗនៃសវនាការអង្គបុរេជំនុំជម្រះដែលកោះហៅមនុស្សឡើងមកផ្ដល់សក្ខីកម្មនៅមុនពេលការកាត់ទោស ។ វាមានសារសំខាន់ខ្លាំងណាស់ក្នុងការបង្ហាញថា នៅក្នុងសម្ដីរបស់ជនជាប់ចោទទាំងបួនរូបនេះ គ្មាននរណាម្នាក់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។

តាមរយៈការបកស្រាយដោយសង្ខេបពីជីវប្រវត្តិរបស់មេដឹកនាំជាន់ខ្ពស់ទាំងបួនរូបដែលបានចោទប្រកាន់ លោក វ៉ាន់ថាន់ ពៅដារ៉ា បានសង្កត់ធ្ងន់ទៅលើការបដិសេធការទទួលខុសត្រូវរបស់ជនជាប់ចោទសម្រាប់ឧក្រិដ្ឋកម្មទាំងអស់ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពេលនោះមានការយកចិត្តទុកដាក់ស្ដាប់ពីអង្គប្រជុំទាំងមូល ។ ទោះបីជាយ៉ាងណាក៏ដោយ លោកពន្យល់អ្នកភូមិថា ការទទួលខុសត្រូវសម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ដែលបានស្លាប់នឹងត្រូវបានបង្ហាញ និងកំណត់ដោយកិច្ចខិតខំប្រឹងប្រែងរបស់តុលាការ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានបន្តទៀតថា ប្រសិនបើដំណើរការនេះប្រព្រឹត្តទៅបានយ៉ាងរលូននិងត្រឹមត្រូវ នោះទាំងចុងចោទ និង ជនរងគ្រោះនឹងត្រូវបានធានាថា យុត្តិធម៌បានផ្ដើររួចហើយ ។

តាមរយៈការបកស្រាយពីករណីឧក្រិដ្ឋកម្មរបស់អង្គជំនុំជម្រះ លោក វ៉ាន់ថាន់ ពោដារ៉ា បានណែនាំអំពីភាពយន្តខ្លីៗចំនួនពីរដែលបង្ហាញពីការសុំទោសរបស់ ឌុច និង សម្ដីរបស់ ខៀវ សំផន អំពីតួនាទីនិងទំនួលខុសត្រូវរបស់គាត់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភាពយន្តទីមួយបានបង្ហាញអំពីការសុំទោសជាសាធារណៈដែលធ្វើឡើងដោយ ឌុច ទៅកាន់ជនរងគ្រោះដែលត្រូវបានសម្លាប់ និងទទួលរងការឈឺចាប់នៅមន្ទីរស–២១ ហើយនិងអ្នកដែលជាសាច់ញាតិរបស់ជនរងគ្រោះ ។ ភាពយន្តទីពីរ បានបង្ហាញអំពីការនិយាយជាសាធារណៈដែលធ្វើឡើងដោយ ខៀវ សំផន នៅអំឡុងពេលសវនាការបឋមរបស់គាត់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីសប្ដាហ៍មុន ដោយបានរៀបរាប់អំពីតួនាទីនិងកាតព្វកិច្ចរបស់គាត់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានប្រកាសអំពីចិត្តបរិសុទ្ធរបស់គាត់ និងបដិសេធរឿងរ៉ាវស្លាប់របស់ជនរងគ្រោះ ។ បន្ថែមពីលើនេះទៀត ខៀវ សំផន បានបដិសេធថា គាត់គ្មានអំណាចពិតប្រាកដក្នុងការធ្វើការសម្រេចចិត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយបានប្រឆាំងថា គាត់ថែមទាំងគ្មានអ្នកធ្វើការឲ្យគាត់ ដែលអាចធ្វើឲ្យគាត់បញ្ជាគេបាននោះទេ ។

អ្នកភូមិ បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះពាក្យដែលបាននិយាយដោយមេដឹកនាំខ្មែរក្រហមនៅក្នុងខ្សែភាពយន្ត ។ ក្រោយមកទៀត អ្នកភូមិទាំងនោះត្រូវបានសុំឲ្យផ្ដល់យោបល់ចំពោះខ្សែភាពយន្តនោះ ។ អ្នកភូមិពីរបីនាក់បានសម្ដែងនូវប្រតិកម្មយ៉ាងខ្លាំង ចំពោះអ្វីដែល ឌុច បាននិយាយ ។ ភាគច្រើននៃអ្នកភូមិយល់ឃើញថា ការសុំទោសមិនអាចទទួលយកបាននោះទេ ទោះបីជាទទួលយកគំនិតរបស់ព្រះពុទ្ធនៅក្នុងការសម្រេចចិត្តក៏ដោយ ។ ស្ត្រីម្នាក់បាននិយាយថា វាមិនអាចទៅរួចនោះទេសម្រាប់រូបគាត់ក្នុងការលើកលែងទោសឲ្យ ឌុច ដោយសារតែឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលគាត់បានប្រព្រឹត្តនៅមន្ទីរស–២១ ។ បុរសម្នាក់ទៀតបានយល់ស្របជាមួយនឹងគាត់ ដោយនិយាយថា វាមិនអាចទៅរួចនោះទេសម្រាប់រូបគាត់ក្នុងការទទួលយកការសុំទោស ។ យោងទៅតាមដូនជីវ័យចំណាស់ម្នាក់ដែលបានរស់នៅនៅក្នុងវត្ត និងកាន់សាសនាព្រះពុទ្ធអស់រយៈពេលច្រើនឆ្នាំមកហើយបាននិយាយថា អត្ថន័យនៃកម្មបានបង្ហាញយ៉ាងច្បាស់និងត្រូវបានយកមកអនុវត្តសម្រាប់ករណីនេះដោយបានទាញហេតុផលថា "បុគ្គលណាក៏ដោយដែលបានប្រព្រឹត្តកម្មអាក្រក់ ត្រូវតែទទួលរងនូវលទ្ធផលដូចគ្នា" ។ ស្ត្រីម្នាក់នេះចង់សម្ដៅទៅលើទំហំនៃទុក្ខវេទនាដែល ឌុច បានទទួលយកត្រឡប់មកវិញ សម្រាប់សកម្មភាពអាក្រក់របស់គាត់នៅក្នុងពេលអតីតកាល ។ គាត់ក៏បានបន្ថែមទៀតថា យោងទៅតាមវិន័យរបស់ព្រះពុទ្ធ គ្មាននរណាម្នាក់អាចទទួលយកផលកម្មជំនួស ឌុច បាននោះទេ គាត់ត្រូវតែទទួលយកបាបកម្មនេះដោយខ្លួនឯង ។ នៅខណៈដែលអ្នកភូមិចាស់ៗនិយាយសំដៅទៅលើការបង្រៀនរបស់ព្រះពុទ្ធ ដែលជាយន្តការមួយសម្រាប់ធ្វើការកាត់ទោសដោយខ្លួនឯងនោះ អ្នកភូមិផ្សេងៗទៀតយល់ឃើញថា វាមានសារសំខាន់ខ្លាំងណាស់ដែលរដ្ឋមានកាតព្វកិច្ចដាក់ទោសអ្នកដែលត្រូវបានរកឃើញថាមានទោសកំហុសដោយ


លោក វ៉ាន់ថាន់ ពោដារ៉ា បង្ហាញអ្នកភូមិអំពីសៀវភៅណែនាំសំណុំរឿង០០២

ប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ ។

អ្នកចូលរួមម្នាក់ដែលរស់នៅជិតភូមិនេះបាននិយាយថា ពាក្យសម្តីរបស់ ខៀវ សំផន ហាក់ដូចជាមិនពិត ហើយព្យាយាមគេចវេះពីការពិត ។ គាត់បានស្នើថា តុលាការគួរតែស្វែងរកការពិត ទើបធ្វើឲ្យប្រជាជនកម្ពុជាឃើញថាពិតជាមានយុត្តិធម៌ ។ បុរសម្នាក់ដែលរស់នៅភូមិដដែលបានយល់ស្របដោយអះអាងថា គាត់មិនជឿ ខៀវ សំផន ។ គាត់បានបង្ហាញថា គាត់មិនជឿអ្វីដែល ខៀវ សំផន និយាយថាមិនដឹងពីផែនការ ឬសេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងរបបខ្មែរក្រហម ព្រោះគាត់ជាគណៈប្រធានរដ្ឋនៅពេលនោះទេ ។

លោក អ៊ួក សំយុល អាយុ៥៥ឆ្នាំ មកពីភូមិព្រៃស្វាយ ឃុំបឹងខ្នារ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅគុកត្រាចក្រោល ។ សំយុល ត្រូវបានឃុំខ្លួនអស់រយៈពេលជាងបីឆ្នាំ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៩ ពីបទរិះគន់អង្គការខ្មែរក្រហម ។ ទោះបីជា សំយុល ធ្លាប់ទទួលការឈឺចាប់ក៏ដោយ ក៏គាត់បានបន្ធូរអារម្មណ៍របស់ខ្លួនដោយជ្រើសរើសការអប់រំរបស់ព្រះពុទ្ធសាសនា ដើម្បីឆ្ពោះទៅរកសន្តិភាព ។ ឈរនៅលើគោលការណ៍របស់ព្រះពុទ្ធដែលគាត់បានរៀន សំយុល មិនចង់សងសឹកទេ ពីព្រោះវាធ្វើឲ្យគាត់មិនអាចស្វែងរកសន្តិភាពបានដែរ ។ ស្រដៀងគ្នាទៅនឹងទស្សនៈរបស់អ្នកចូលរួមផ្សេងៗទៀតដែរ សំយុល បានយកទ្រឹស្តី «កម្ម» ដើម្បីព្យាបាលការគិតរបស់ខ្លួនឯង ។ ដើម្បីរង់ចាំច្បាប់នេះ សំយុល បានជ្រើសរើសមិនយកការសងសឹកផ្ទាល់ខ្លួន ហើយទុកឲ្យតុលាការជាអ្នកស្វែងរកយុត្តិធម៌សម្រាប់រូបគាត់ ក៏ដូចជាជនរងគ្រោះដទៃទៀតដែលបានទទួលរងការឈឺចាប់ ។

សំយុល យល់ឃើញថា វាមិនអាចទៅរួចនោះទេក្នុងការលើកលែងទោសឲ្យ ឌុច ទោះបីជា ឌុច ខិតខំទទួលស្គាល់ការពិត និងសុំទោសជាសាធារណៈក៏ដោយ ។ បន្ថែមពីលើការពិតដែលថា គាត់បានទទួលរងគ្រោះយ៉ាងខ្លាំងពីការជាប់ឃុំឃាំង និងការធ្វើទារុណកម្មចំពោះរូបគាត់ ឌុច គឺជានិមិត្តរូបតំណាងឲ្យប្រធានគុកតំបន់នៅក្នុងប្រទេស ។ ដូច្នេះ គាត់យល់ឃើញថា ការសុំទោសគឺពិបាកនឹងអាចទទួលយកបានណាស់ ។ គាត់បានយល់ឃើញស្រដៀងគ្នាទៅនឹងវិធីដែលមេដឹកនាំជាន់ខ្ពស់បានបដិសេធការពិត និងមិនទទួលខុសត្រូវសម្រាប់អ្វីដែលបានកើតឡើង ។

ឆ្លងតាមការពិភាក្សាខ្លីនៃភាពយន្តទាំងនេះ លោក វ៉ាន់ថាន់ ពៅដារ៉ា បានបិទអង្គប្រជុំទាំងនេះ ដោយថ្លែងអំណរគុណទៅដល់អ្នកភូមិ សមាជិកក្រុមប្រឹក្សាឃុំ និងមេឃុំសាជាថ្មីម្តងទៀត ។ លោក បឹង បេន បានធ្វើការកត់សម្គាល់ជាចុងក្រោយរបស់គាត់ ដោយសង្កត់ធ្ងន់ទៅលើសារសំខាន់របស់តុលាការខ្មែរក្រហម និងលើកទឹកចិត្តអ្នកភូមិរបស់គាត់ឲ្យចូលរួមនៅក្នុងដំណើរការនីតិវិធី ។ គាត់បាននិយាយថា មានតែតាមរយៈការយល់ដឹងអំពីដំណើរការនីតិវិធីប៉ុណ្ណោះដែលអាចធ្វើឲ្យជនរងគ្រោះដឹងពីការកាត់ទោសថាតើយុត្តិធម៌ប្រព្រឹត្តទៅយ៉ាងដូចម្តេច ។

អ្នកចូលរួមបានយល់ឃើញថា ការប្រជុំនេះមានប្រសិទ្ធភាពក្នុងការរំឭកដល់ប្រជាជនក្នុងស្រុកឲ្យយកចិត្តទុកដាក់ចំពោះការងាររបស់តុលាការ ជាពិសេសសារសំខាន់នៃសំណុំរឿង ០០២ ។ ខៀវ ធួច អាយុ៨៤ឆ្នាំ ដែលអញ្ជើញមកពីភូមិមេទឹក មានអារម្មណ៍ថា ការប្រជុំនេះបានផ្តល់ដំណឹង និងមានប្រយោជន៍សម្រាប់ក្មេងជំនាន់ក្រោយឲ្យយល់ពីភាពឃោរឃៅពីអតីតកាល ដែលនឹងអាចជួយទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងសាជាថ្មីម្តងទៀត ។

**ស៊ីរ៉ិ សាវីណា**



អ្នកភូមិសួរសំណួរអំពីដំណើរការសវនាការ

# ការទទួលបាននូវយុត្តិធម៌ និងការផ្សះផ្សាជាតិ នៅកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍

***(តចប់)***

***គណៈកម្មការស៊ើបអង្កេត***

*ដោយសារតែគណៈកម្មការស្វែងរកការពិតអាចបង្កឲ្យមានផលប៉ះពាល់មួយចំនួន ឯកសារនេះសូមលើកសំណើជំនួសគណៈកម្មការខាងលើនេះដោយគណៈកម្មការស៊ើបអង្កេតដែលមានតួនាទីស៊ើបអង្កេតនិងកត់ត្រាភាពសាហាវព្រៃផ្សៃដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម ។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាចង់បង្កើតគណៈកម្មការបែបនេះ ប្រាកដជាទាមទារឲ្យមានការឧបត្ថម្ភ ការណែនាំ និង ជំនួយពីសហគមន៍អន្តរជាតិ រួមជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ។ គណៈកម្មការបែបនេះអាចសម្រេចបានយុត្តិធម៌តាមការផ្សះផ្សានិងបង្កើនការផ្សះផ្សាសង្គមតាមរយៈការដោះស្រាយលើទិដ្ឋភាពមួយចំនួនដែលស្រដៀងនឹងគោលបំណងរបស់គណៈកម្មការស្វែងរកការពិតដែរ តែមិនបានតម្រូវឲ្យជនរងគ្រោះនិងជនដៃដល់ប្រឈមមុខជាមួយគ្នានោះទេ ។*

*បញ្ហាទីមួយដែលគណៈកម្មការស៊ើបអង្កេតអាចដោះស្រាយបានគឺកង្វះខាតកំណត់ត្រាប្រវត្តិសាស្ត្រ ។ នេះមានសារសំខាន់ចំពោះការផ្សះផ្សា និង យុត្តិធម៌តាមការផ្សះផ្សាយ៉ាងខ្លាំង ព្រោះវាមានតួនាទីស្រដៀងនឹងគណៈកម្មការស្វែងរកការពិតក្នុងការទទួលស្គាល់ព័ត៌មាន សក្ខីកម្ម និងការគាំទ្រដល់ជនរងគ្រោះ ។ កញ្ញា លីនតុន បានពណ៌នាថា ស្ថានភាពដែលល្អប្រសើរបំផុតគឺគណៈកម្មការនេះអាចទទួលជំនួយពីធនធានដែលមានរួចមកហើយ ដូចជាទិន្នន័យជាច្រើនសន្ធឹកសន្ធាប់របស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា និងអ.វ.ត.ក. ក្នុងការបង្កើតជា «កំណត់ត្រាផ្លូវការមានភាពទូលំទូលាយ តុល្យភាព និងអាចជឿជាក់បានស្តីអំពីប្រវត្តិសាស្ត្របច្ចុប្បន្នដ៏សាហាវឃោរឃៅរបស់ប្រទេសកម្ពុជា» ។ ទោះបីជាដំណើរការធ្វើកំណត់ត្រាប្រវត្តិសាស្ត្រមិនប្រសើរដូចជាអ្វីដែល លីនតុន បានគិតទុកក៏ដោយ ក៏គណៈកម្មការស៊ើបអង្កេតនៅតែអាចសម្រេចគោលដៅទីពីររបស់ខ្លួនដែរ នោះគឺបំពេញតម្រូវការផ្សះផ្សាក្នុងលក្ខណៈជាបុគ្គលដូចដែលលោក ឆាំង យុ បានរំពឹកម្តងហើយម្តងទៀតថាជារឿងមួយដែលបុគ្គលគ្រប់រូប «ត្រូវធ្វើដោយខ្លួនឯង» ។ គណៈកម្មការស៊ើបអង្កេតអាចជួយដល់ការផ្សះផ្សាទាំងជនរងគ្រោះ និងជនដៃដល់ ដោយផ្តល់ឱកាសដល់អ្នកទាំងនោះឲ្យប្រឈមមុខដោះស្រាយជាមួយអតីតកាលរបស់ខ្លួន និងបង្កើនភាពស្និទ្ធស្នាលជាមួយគ្នា ។ នេះគាំទ្រដល់មតិរបស់ លីនតុន ដែលបានលើកឡើងថា «ប្រជាជនខ្មែរគ្រប់រូប...គួររួមចំណែកក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើតជាកំណត់ត្រាអំពីអតីតកាលរបស់ខ្លួនឯង ដើម្បីការផ្សះផ្សាក្រោយពីរឿងរ៉ាវទាំងនោះបានកើតឡើង» ។ ក្នុងដំណើរការធ្វើកំណត់ត្រាប្រវត្តិសាស្ត្រនេះផងដែរ គណៈកម្មការស៊ើបអង្កេតអាចផ្តល់ដំណោះស្រាយដល់បញ្ហាទីបីទៀត នោះគឺផ្តល់ចម្លើយជាក់លាក់មួយដល់ប្រជាជនកម្ពុជាថាតើហេតុអ្វីបានជារបបខ្មែរក្រហមមានលក្ខណៈបែបនេះ ។ គណៈកម្មការស៊ើបអង្កេតអាចបំពេញ «តម្រូវការក្នុងការស្វែងយល់ពីការពិតថាតើហេតុអ្វីបានជាអ្នកទាំងនោះប្រព្រឹត្តដូច្នេះ ហេតុអ្វីរឿងរ៉ាវទៅជាបែបនេះ ហើយចម្លើយទាំងនេះនឹងជំរុញឲ្យមានការស្វែងយល់អំពីសោកនាដកម្មនេះទាំងមូល» ។*

*ថ្វីដ្បិតតែគណៈកម្មការស៊ើបអង្កេតមិនប្រាកដជាអាចផ្តល់ចម្លើយទាំងនេះដល់មនុស្សគ្រប់គ្នា តែគណៈកម្មការស្វែងរកការពិតនេះអាចលើកស្ទួយការផ្សះផ្សាតាមរយៈកិច្ចប្រឹងប្រែងក្នុងការផ្តល់មូលដ្ឋាននៃយុត្តិធម៌តាមការផ្សះផ្សាដល់ជនរងគ្រោះក៏ដូចជាចូលរួមក្នុងដំណើរការផ្សះផ្សាក្នុងកម្រិតបុគ្គលដែរ ។ ការផ្សះផ្សាក្នុងកម្រិតបុគ្គលនេះកើតឡើងតាមរយៈការចូលរួមរបស់ជនរងគ្រោះដែលទទួលបានការគាំទ្រនិងលើកស្ទួយដោយគណៈកម្មការនេះ ហើយមានសារសំខាន់ក្នុងដំណើរការផ្សះផ្សានេះណាស់ ។*

កម្រិតដែលការផ្សះផ្សាក្នុងលក្ខណៈជាបុគ្គលអាចកើតឡើងក្នុងចំណោមប្រជាជនត្រូវមើលទៅលើប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងក្នុងការផ្សព្វផ្សាយក្នុងគោលបំណងបង្កើនការចូលរួមរបស់ជនរងគ្រោះក្នុងគណៈកម្មការនេះ ។ ការផ្សះផ្សាក្នុងកម្រិតបុគ្គលនេះនឹងជំរុញឲ្យមានការផ្សះផ្សាកម្រិតសហគមន៍និងជាតិបន្ថែមទៀត ជាពិសេសនៅពេលដែលសហការជាមួយនឹងផលប្រយោជន៍របស់គណៈកម្មការស៊ើបអង្កេតក្នុងដំណើរការឈានទៅរកការអភ័យទោសដល់គ្នា និងធាតុផ្សំទាំងប្រាំរបស់វា ។ គណៈកម្មការនេះអាចបង្កើតការទទួលស្គាល់អំពីការពិតដោយជនដៃដល់សារភាពពីទង្វើរបស់ខ្លួន រួមទាំងការបង្ហាញវិប្បដិសារីរបស់ជនដៃដល់ ព្រោះថាការចូលរួមដោយស្ម័គ្រចិត្តនេះនឹងធ្វើឲ្យជនដៃដល់ដែលព្រមចូលរួមមានការភ្ញាក់រឭកដោយខ្លួនឯង ។ យោងទៅតាមកម្រិតនៃការផ្សះផ្សាក្នុងកម្រិតបុគ្គលដែលគណៈកម្មការស៊ើបអង្កេតសម្រេចបាន គណៈកម្មការនេះក៏មានសក្តានុភាពក្នុងការនាំឲ្យជនរងគ្រោះបញ្ឈប់ការចងគំនុំជាមួយជនដៃដល់ តែបែរមកស្វែងយល់អារម្មណ៍ជនដៃដល់វិញ និងឈានទៅដល់ការសម្រាលទោសដល់ជនដៃដល់ ។ ទោះជាគណៈកម្មការស៊ើបអង្កេតមិនអាចសម្រេចបានធាតុផ្សំទាំងប្រាំនៃការអភ័យទោសក៏ដោយ ក៏គណៈកម្មការនេះយ៉ាងហោចណាស់អាចសម្រេចបានធាតុផ្សំមួយចំនួនដែរ ហើយនេះនឹងជំរុញឲ្យមានការផ្សះផ្សានិងការស្តារសង្គមសាជាថ្មី ហើយបង្កើនយុត្តិធម៌បែបផ្សះផ្សាយ៉ាងមានប្រសិទ្ធភាព ។

ក្នុងខណៈពេលដែលផលប្រយោជន៍របស់គណៈកម្មការស៊ើបអង្កេតដែលត្រូវបានរំឭកឡើងនេះកើតឡើងដោយសារសក្តានុភាពក្នុងការបង្កើនការផ្សះផ្សាក្នុងកម្រិតបុគ្គល គណៈកម្មការនេះអាចបង្កើនការពិភាក្សាជាសាធារណៈផងដែរ ហើយនេះអាចលើកស្ទួយការផ្សះផ្សាក្នុងកម្រិតជាតិ ។ តថភាពនេះបង្ហាញឲ្យឃើញថា គណៈកម្មការនេះអាចអនុវត្តដំណោះស្រាយពីលើចុះក្រោមនិងពីក្រោមឡើងលើរបស់ការផ្សះផ្សាច្រើនកម្រិតដែលជាផលប្រយោជន៍មួយផ្សេងទៀតរបស់យុត្តិធម៌តាមការផ្សះផ្សានិងការស្តារសង្គមសាជាថ្មី ។ ប្រសិទ្ធភាពក្នុងការផ្តល់ការផ្សះផ្សាច្រើនកម្រិតរបស់គណៈកម្មការស៊ើបអង្កេតនេះក៏ទទួលបានការគាំទ្រពីកញ្ញា លីនគុន ដែរ ដោយគាត់បានអះអាងថាយន្តការបែបនេះអាចជួយឲ្យបុគ្គលនិងសង្គមទទួលបានការផ្សះផ្សានិងស្តារឡើងវិញ ប្រសិនបើមានការគាំទ្រដោយកម្មវិធីព្យាបាលរបួសផ្លូវចិត្ត និងកម្មវិធីផ្លាស់ប្តូរទីលំនៅក្នុងថ្នាក់មូលដ្ឋាន ។

គណៈកម្មការស៊ើបអង្កេតនេះក៏អាចផ្តល់ផលប្រយោជន៍បន្ថែមដល់សហគមន៍អន្តរជាតិផងដែរ ប្រសិនបើវាមិនត្រឹមតែត្រួតពិនិត្យទៅលើស្ថានភាពក្នុងស្រុក តែបានរាប់បញ្ចូលនូវការរួមចំណែករបស់ប្រទេសទីបីដូចជា សហរដ្ឋអាមេរិក ប្រទេសវៀតណាម និងប្រទេសចិនជាដើម ។ ការរួមបញ្ចូលបែបនេះអាចប្រើប្រាស់ជាមេរៀនមួយដល់សហគមន៍អន្តរជាតិអំពីលក្ខខណ្ឌដែលគួរយកមកពិចារណាមុនពេលប្រទេសមួយសម្រេចចិត្តធ្វើអន្តរាគមន៍ដល់ប្រទេសមួយទៀតដែលមានអស្ថិរភាព និងវិធានការប្រសើរបំផុតដែលប្រទេសធ្វើអន្តរាគមន៍គួរអនុវត្តដើម្បីជួយស្តារ (ឬបង្កើត) ស្ថិរភាពដល់ប្រទេសដែលកំពុងមានវិបត្តិផ្ទៃក្នុង ។ នេះមានសារសំខាន់ជាខ្លាំងព្រោះថាដំណើរបំបាត់អាណានិគម និងការបញ្ចប់សង្គ្រាមត្រជាក់បណ្តាលឲ្យរដ្ឋឯករាជ្យថ្មីជាច្រើនកើតឡើងដោយសារតែមូលហេតុខុសៗគ្នា ដូចជាភាពមិនចុះសម្រុងគ្នារវាងវប្បធម៌និងអត្តសញ្ញាណ និងការគាបសង្កត់ទៅលើជនជាតិភាគតិចដែលមានភាពទន់ខ្សោយជាដើម ។

## រាជរដ្ឋាភិបាលកម្ពុជា

បញ្ហាដ៏ធំបំផុតដែលអាចកើតមានឡើងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន គឺវប្បធម៌និទ្ទណ្ឌភាពនិងអំពើពុករលួយដែលត្រូវបានកប់យ៉ាងជ្រៅក្នុងរដ្ឋាភិបាលនេះ ។ សេចក្តីណែនាំជាច្រើន ត្រូវបានលើកឡើងថាតើត្រូវដោះស្រាយបញ្ហានេះដោយរបៀបណា ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីណែនាំជាច្រើននេះអាចនឹងមានប្រសិទ្ធភាពនាពេលអនាគត ។ ដើម្បីពិចារណារៀបចំ «ការត្រួតពិនិត្យសាឡើងវិញដ៏សំខាន់មួយ និងការអភិវឌ្ឍប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិដែលរួមបញ្ចូលនូវកេរដំណែលរបស់អង្គជំនុំជម្រះ ការបញ្ឈប់អំពើពុករលួយ និងការចាប់ផ្តើមបង្កើតឲ្យមានតម្លាភាព ទំនួលខុសត្រូវ និងប្រសិទ្ធភាព» នៅក្នុងប្រទេសដែលប្រៀបបីដូចជាកែវដែលបែកជាបំណែកមួយ គឺហាក់បីដូចជាស្នើសុំដើម្បីភ្ជាប់កែវដែលបែកនេះ ដោយបុគ្គលម្នាក់គួរតែចាប់ផ្តើមផ្គុំបំណែកកែវដែលធំល្មមនឹងអាចរើសបានទាំងអស់នោះត្រឡប់

មកវិញ ហើយបន្ទាប់មកបិទភ្ជាប់ឲ្យជាប់ឡើងវិញ ។ ការលុបបំបាត់អំពើពុករលួយចេញពីរាជរដ្ឋាភិបាលក្នុងកាលៈទេសៈអន្តរកាលនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺមិនមានភាពប្រាកដប្រជាទេ ហើយវាអាចនឹងវាយបំបែកគ្រឹះដែលរឹងមាំដែលជាប្រព័ន្ធគួរឲ្យជឿជាក់និងស្អាតស្អំនេះបាន គឺប្រៀបបីដូចជាកំពុងតែសាកល្បងកម្លាំងរបស់កែវដែលប្រេះស្រាំជាមួយនឹងដុំឥដ្ឋ ។

មានហេតុផលជាច្រើនដែលថា កំណែទម្រង់ដ៏មានសារសំខាន់ដើម្បីលុបបំបាត់វប្បធម៌នៃនិទ្ទណ្ឌភាព និងអំពើពុករលួយ គឺមិនទាន់ដោះស្រាយបាននៅឡើយទេនៅក្នុងកាលៈទេសៈនេះ ។ ហេតុផលទីមួយ គឺថាអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនត្រូវបានផ្តល់ការងារឲ្យដោយរដ្ឋាភិបាល និងកំពុងកាន់តំណែងខ្ពស់ ។ វាអាចសន្មតបានថា បុគ្គលជាច្រើនទាំងអស់នេះអាចនឹងបំពេញតួនាទីដោយសារប្រយោជន៍ផ្ទាល់ខ្លួន ហើយនិងមិនគាំទ្រវិធានការដែលអាចដាក់ទោសអ្នកទាំងអស់នោះសម្រាប់ការចូលរួមរបស់គេនៅក្នុងរបបខ្មែរក្រហមឡើយ ។ បញ្ហានេះក៏បង្កឲ្យមានភាពស្មុគស្មាញបន្តទៀត ដោយសារតែភាពចម្រូងចម្រាសនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ពីព្រោះមនុស្សជាច្រើនអាចរស់រានមានជីវិតពីរបបខ្មែរក្រហមបាន ដោយសារតែការគោរពទៅតាមមេដឹកនាំជាន់ខ្ពស់របស់គេតែប៉ុណ្ណោះ ។ ការដកហូតតំណែងរបស់បុគ្គលដែលភ័ស្តុតាងបានអះអាងថា បានចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឲ្យទុកចិត្តពីបទរំលោភទាំងស្រុងលើសិទ្ធិមនុស្សនោះ គឺជាដំណើរការដ៏ស្មុគស្មាញរួចជាស្រេចទៅហើយ ហើយការធ្វើបែបនេះអាចនឹងធ្វើឲ្យមានភាពស្មុគស្មាញនាពេលខាងមុខ ដោយសារតែស្ថានភាពនយោបាយក្នុងស្រុក ។ ដូច្នេះ នៅក្នុងស្ថានភាពបែបនេះ វាមិនប្រាកដនៅឡើយទេ ថាតើបុគ្គលទាំងអស់នេះគួរតែត្រូវដកហូតតំណែងចេញពីមុខងារក្នុងការិយាល័យសាធារណៈ ពីព្រោះថាវាអាចប៉ះពាល់ដល់ស្ថិរភាពនៃដំណើរការផ្សះផ្សាដ៏ងាយនឹងរងគ្រោះថ្នាក់នេះ ដោយសារតែចំណោទសួរពីភាពចម្រូងចម្រាសនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងពីបញ្ហាថាតើនរណាគួរតែត្រូវបានកាត់ទោស និងឲ្យទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។

ទីពីរ ប្រព័ន្ធតុលាការខ្លួនឯងផ្ទាល់ក៏មានភាពពុករលួយដោយសារតែវប្បធម៌នៃនិទ្ទណ្ឌភាពដែរ ។ ថាយល័រ បានផ្តល់យោបល់ថា សហគមន៍អន្តរជាតិអាចនឹងសាកល្បងបន្តអនុវត្តក្រមនីតិវិធីតាមរយៈការផ្តល់នូវវគ្គបំពាក់បំប៉នដល់ប្រទេសនេះ ប៉ុន្តែរដ្ឋាភិបាលកម្ពុជាអាចនឹងយល់ឃើញថាការធ្វើបែបនេះ គឺជាការប៉ះពាល់ដល់អធិបតេយ្យភាពរបស់ខ្លួន ហើយការផ្តល់ជូនបែបនេះអាចនឹងបណ្តាលឲ្យមានភាពអន់ចិត្តសាជាថ្មីម្តងទៀតចំពោះសហគមន៍អន្តរជាតិ សម្រាប់ការពាក់ព័ន្ធរបស់ប្រទេសភាគីទីបីនៅក្នុងនយោបាយក្នុងស្រុករបស់កម្ពុជា ដែលយ៉ាងហោចណាស់នឹងបង្កឲ្យមានអស្ថិរភាពដូចមុនកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើដោះស្រាយតាមរយៈការវិលត្រឡប់មកវិញនូវរបបច្រើនបែបផ្សេងៗរបស់ប្រទេសភាគីទីបីនេះ ។ ហេតុផលមួយទៀតដែលសេចក្តីណែនាំនេះទំនងជាមិនអាចជួយអ្វីបាននាពេលនេះ គឺដោយសារតែភាពក្រីក្រដែលមិនអាចទប់ស្កាត់បានក្នុងទូទាំងប្រទេសកម្ពុជា ដូច្នេះវាមិនទំនងថា ការស៊ីសំណូកក្នុងផ្នែកតុលាការ ឬផ្នែកមន្ត្រីប៉ូលិសអាចនឹងបញ្ឈប់បានទេ ។

សម្រាប់អំពើពុករលួយដែលនឹងអាចត្រូវបានដោះស្រាយនោះ កិច្ចខិតខំប្រឹងប្រែងលុបបំបាត់ត្រូវតែដើរអមជាមួយគ្នានឹងការរីកចម្រើនលូតលាស់ និងកំណើនសេដ្ឋកិច្ចដែលទាមទារឲ្យមានការវិនិយោគទុនបរទេស ។ នាពេលនេះ មានចំណាប់អារម្មណ៍តិចតួចណាស់សម្រាប់ប្រទេសដទៃលើវិស័យវិនិយោគទុនក្នុងប្រទេសកម្ពុជា ស្របពេលដែលមានការចោទប្រកាន់ពីអំពើពុករលួយរបស់រដ្ឋាភិបាល ។ នាពេលអនាគត ជំហានដែលជានិមិត្តសញ្ញាមួយដើម្បីលុបបំបាត់អំពើពុករលួយ អាចនឹងត្រូវបានអនុវត្តដោយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើនការវិនិយោគទុនបរទេស ។ ប៉ុន្តែតម្រូវការអាទិភាពចម្បងបំផុតរបស់រដ្ឋាភិបាលនាពេលបច្ចុប្បន្ន គឺត្រូវ “បិទបំណែកកែវដែលបែកនោះរួមគ្នាសាឡើងវិញ” ប្រៀបបីដូចជាដំណើរការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការកសាងសង្គមជាតិសាជាថ្មី ។ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើគោលដៅទាំងនេះ ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនឹងក្លាយជាអាទិភាពចម្បងមួយផងដែរ ។ ហើយការបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋអាចនឹងជួយបង្កើននូវជំនឿទុកចិត្តរបស់អន្តរជាតិលើរដ្ឋាភិបាលកម្ពុជាវិញផង

ដែរ (មានព័ត៌មានបន្ថែមទៀតនៅខាងក្រោម) ។ ដូច្នេះ ដើម្បីឲ្យអំពើពុករលួយ និងវប្បធម៌និទ្ទណ្ឌភាពដែលនឹងត្រូវដោះស្រាយបាននោះ កិច្ចខិតខំប្រឹងប្រែងលុបបំបាត់ត្រូវតែដើរទន្ទឹមគ្នានឹងការរីកចម្រើនលូតលាស់វិស័យសេដ្ឋកិច្ច ។ កត្តាទាំងពីរនេះ ត្រូវតែទទួលការគាំទ្រដោយមូលដ្ឋានគ្រឹះនៃជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋដែលជាលទ្ធផលនឹងនាំឲ្យមានការកសាងសង្គមជាតិសាឡើងវិញនិងកិច្ចខិតខំប្រឹងប្រែងសម្រាប់យុត្តិធម៌តាមរយៈការផ្សះផ្សា ។

## ការកសាងសង្គមជាតិសាឡើងវិញ

ដើម្បីឲ្យការស្តាបនាសង្គមជាតិឡើងវិញអាចនឹងកើតឡើងនោះ យុត្តិធម៌តាមការផ្សះផ្សាត្រូវតែបានផ្តល់ឲ្យតាមរយៈការពង្រឹងការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ។ យ៉ាងណាមិញ មុននឹងយុត្តិធម៌តាមការផ្សះផ្សាអាចនឹងមានប្រសិទ្ធភាពនោះ បរិយាកាសនៃភាពភ័យខ្លាចត្រូវតែដោះស្រាយដើម្បីបង្កើតឲ្យមានស្ថានភាពនយោបាយបើកចំហមួយដែលមានការពិភាក្សាដោយភាពស្មោះត្រង់ និងការជជែកវែកញែកលើប្រធានបទថាតើមានអ្វីខ្លះបានកើតឡើង និងថាតើយន្តការពិតប្រាកដសម្រាប់អតីតកាលនេះអាចបំពេញតួនាទីបានដោយប្រសិទ្ធភាព ដើម្បីប្រឆាំងនឹងវប្បធម៌និទ្ទណ្ឌភាពបានដោយរបៀបណា ។ ប្រសិនបើមិនដោះស្រាយបរិយាកាសនៃភាពភ័យខ្លាចទេនោះ កម្មវិធីសម្រាប់សង្គមជាតិ និងគំនិតផ្តួចផ្តើមដែលបង្កើតឡើងដើម្បីពង្រឹងយុត្តិធម៌តាមការផ្សះផ្សា និងការផ្សះផ្សាប្រាកដជាមិនមានប្រសិទ្ធភាពឡើយ ។ ស្ថានភាពបែបនេះមិនចាំបាច់ត្រូវតែបង្កើតឡើងសម្រាប់កម្មវិធីសង្គមជាតិ ដើម្បីធ្វើឲ្យមានដំណើរការវិវត្តឆ្ពោះទៅមុខនោះទេ ពីព្រោះកម្មវិធីសង្គមជាតិអាចនឹងពង្រឹងដល់ភាពប្រាកដប្រជារបស់ស្ថានភាពនយោបាយបាន ។ បន្ទាប់មកការកកើតឡើងនូវស្ថានភាពនយោបាយនេះ ត្រូវតែណែនាំឲ្យស្គាល់ដោយរដ្ឋាភិបាល ដែលការធ្វើបែបនេះអាចតម្រូវឲ្យមានសេចក្តីថ្លែងការណ៍តិចតួចតាមតែអាចធ្វើបាន តាមរយៈមន្ត្រីរដ្ឋាភិបាលដើម្បីគាំទ្រស្ថានភាពនយោបាយបើកចំហនេះ និងធ្វើឲ្យសេចក្តីថ្លែងការណ៍ទាំងនេះផ្សព្វផ្សាយនៅក្នុងសារព័ត៌មានដើម្បីធ្វើឲ្យជ្រួតជ្រាបទៅក្នុងព្រលឹងជាតិ ។ សេចក្តីថ្លែងការណ៍នេះត្រូវបានធ្វើឡើងតាមរយៈការរិះគន់របស់សម្តេច ហ៊ុន សែន ពីរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មដែលខ្មែរក្រហមប្រព្រឹត្ត ប៉ុន្តែការយល់ដឹងនេះខ្វះខាតនូវភាពស្មោះត្រង់ និងភាពប្រាកដប្រជា បើពិចារណាទៅលើសេចក្តីអះអាងខាងលើរបស់លោកនាយករដ្ឋមន្ត្រីទាក់ទងនឹងការពន្យារដំណើរការរបស់តុលាការ ។ ដូច្នេះ កិច្ចខិតខំប្រឹងប្រែងបន្ថែមត្រូវតែធ្វើឡើងដើម្បីបង្ហាញពីបញ្ញត្តិរបស់រដ្ឋាភិបាលទាក់ទងនឹងស្ថានភាពនយោបាយបើកចំហបែបនេះ និងដើម្បីបង្ហាញនូវការយកចិត្តទុកដាក់ដ៏ស្មោះត្រង់ និងពិតប្រាកក្នុងការផ្តល់នូវយុត្តិធម៌ដល់ជនរងគ្រោះរបស់កម្ពុជាប្រជាធិបតេយ្យ ។ ការបង្កបង្កើតបេសកកម្មស៊ើបអង្កេត គឺជាកម្មវិធីមួយធ្វើឡើងក្នុងគោលបំណងជំរុញយុត្តិធម៌តាមការផ្សះផ្សាឲ្យទៅមុខជាមួយនឹងប្រយោជន៍នៃការទទួលស្គាល់ទុក្ខវេទនារបស់ជនរងគ្រោះ និងការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ដូចដែលបានលើកឡើងខាងលើ ។ បេសកកម្មបែបនេះត្រូវការកម្មវិធីដែលជាប់ពាក់ព័ន្ធដោយមានការគាំទ្រពីមេដឹកនាំកម្ពុជា ដែលអ្នកទាំងនោះអាច “រៀបចំសិក្ខាសាលាដើម្បីស្វែងយល់ថាតើទំនៀមទម្លាប់ប្រជាជនកម្ពុជានិងសាសនាព្រះពុទ្ធអាចនឹងមានដំណើរការក្នុងយុទ្ធសាស្ត្ររួមមួយដើម្បីលើកកម្ពស់ការផ្សះផ្សាបានដែរឬយ៉ាងណា” ។ បន្ថែមលើនេះ លីនតុន បានកត់សម្គាល់ពី “ភាពចាំបាច់ដើម្បីអភិវឌ្ឍយន្តការស្វែងរកការពិតមួយ ដែលយន្តការខ្លួនឯងផ្ទាល់នេះក៏មិនបានសាកល្បងនៅក្នុងការពិសោធន៍ផ្នែកនយោបាយ និងសង្គមផងទេ ផ្ទុយទៅវិញបែរជាត្រូវបានរាំងស្ទះដោយបញ្ហាសតិអារម្មណ៍ និងកម្មវិធីស្តាបនាសង្គមដែលត្រូវប្រើប្រាស់សក្តានុពលភាពយ៉ាងធំធេងរបស់សាសនាព្រះពុទ្ធ” ។

ដូច្នេះ កម្មវិធីសង្គមដែលផ្អែកលើអ្នកគោរពសាសនាព្រះពុទ្ធ គួរតែត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដើម្បីទាញយកប្រយោជន៍ពីគោលការណ៍សាសនាព្រះពុទ្ធដែលមិនអាចផ្លាស់ប្តូរបានឡើយនៅក្នុងវប្បធម៌ខ្មែរ ។ ជាមួយគ្នានេះ គោលការណ៍ជាច្រើននេះបានផ្តល់នូវការលួងលោមចិត្តដល់ជនរស់រាន់មានជីវិតពីរបបខ្មែរក្រហម ។ ដូចដែល លីនតុន បានរៀបរាប់ វប្បធម៌កម្ពុជា និងទំនៀមទម្លាប់សាសនាព្រះពុទ្ធ គឺជាម្ចាស់ការលើលទ្ធភាពនៃការផ្សះផ្សារបស់

បុគ្គល និងរបស់សហគមន៍បានយ៉ាងធំធេង ។ ដូចដែលអ្នកឆ្លើយតបម្នាក់បាននិយាយសង្កត់ធ្ងន់ថា "គ្មានអ្វីប្រសើរជាងការប្រើប្រាស់ការបង្ហាត់បង្រៀនរបស់ព្រះពុទ្ធជាមូលដ្ឋានគ្រឹះមួយសម្រាប់ផ្សះផ្សាជាតិនោះទេ" ។ តាមរយៈការប្រើប្រាស់ការបង្ហាត់បង្រៀនរបស់ព្រះពុទ្ធជាមូលដ្ឋានមួយសម្រាប់ការផ្សះផ្សា និងគំនិតផ្តួចផ្តើមយុត្តិធម៌តាមការផ្សះផ្សា នោះកម្មវិធីសម្រាប់សង្គមនឹងពិចារណាលើវប្បធម៌របស់កម្ពុជាក្នុងនាមជាសង្គមមិនអាស្រ័យលើប្រទេសលោកខាងលិច ហើយនឹងអាចធ្វើឲ្យប៉ះពាល់ដល់ជីវិតរស់នៅរបស់ប្រជាជនកម្ពុជា ជាពិសេស "ក្បួនច្បាប់ក្នុងតំបន់នៃការគ្រប់គ្រង ការកាត់បន្ថយ និងដោះស្រាយជម្លោះ" ។ កម្មវិធីទាំងអស់នេះ គួរតែរួមបញ្ចូលមេដឹកនាំសាសនាព្រះពុទ្ធ ពីព្រោះថាការគាំទ្ររបស់មេដឹកនាំទាំងនោះអាចនឹងដាក់បន្ថែមនូវធម្មានុរូបទៅកាន់សំឡេងដ៏ស្ងប់ស្ងាត់របស់អ្នកផ្តួចផ្តើមគំនិតសាសនាព្រះពុទ្ធ ។ លីនតុន បានបង្ហាញសេចក្តីណែនាំប្រហាក់ប្រហែលគ្នាទៅកាន់សេចក្តីបញ្ចប់នេះ ដោយណែនាំថា "សហគមន៍ដែលចាប់អារម្មណ៍អាចត្រូវបាន ផ្តល់ជំនួយដើម្បីរៀបចំដំណើរការកសាងជំនឿទុកចិត្ត និងការដោះស្រាយជម្លោះមួយដែលប្រើប្រាស់គោលការណ៍របស់ព្រះពុទ្ធដែលត្រូវបានផ្តោតការយកចិត្តទុកដាក់លើព្រះវិហារ និងត្រូវដឹកនាំដោយ មនុស្សចាស់ក្នុងភូមិ ។

ដោយសារតែសាសនាព្រះពុទ្ធ គឺជាវត្ថុមានដ៏បិតបេរមួយនៅក្នុងវប្បធម៌ខ្មែរ នោះការគាំទ្ររបស់មេដឹកនាំសាសនាព្រះពុទ្ធអាចនឹងមានប្រយោជន៍យ៉ាងច្រើនដើម្បីនាំយកនូវការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការកសាងសង្គមជាតិឡើងវិញនៅក្នុងប្រទេសកម្ពុជា ។ ហេតុដូច្នេះ អង្គការក្រៅរដ្ឋាភិបាលគួរតែអំពាវនាវឲ្យមេដឹកនាំសាសនាព្រះពុទ្ធនៅក្នុងសង្គមកម្ពុជាលើកកម្ពស់ការព្យាបាលរបួស និងការកសាងសង្គមនៅក្នុងថ្នាក់សហគមន៍ និងបុគ្គល និងជាលទ្ធផលក្នុងថ្នាក់ជាតិ ។

ជាមួយគ្នានេះដែរ រដ្ឋាភិបាលកម្ពុជា គួរតែសំណូមពរសុំជំនួយពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីពិភាក្សាវែកញែក និងត្រួតពិនិត្យថាតើបែបបទនៃសំណងខូចខាតអ្វីដែលនឹងមានប្រយោជន៍ និងពិតប្រាកដបំផុតក្នុងការលើកកម្ពស់យុត្តិធម៌អន្តរកាល និងការកសាងសង្គមជាតិឡើងវិញ ។ ជាមួយគ្នានេះ សំណងខូចខាតជាទឹកប្រាក់គឺមិនមានភាពពិតប្រាកដ ឬមិនត្រូវបានស្នើឲ្យធ្វើឡើងដោយសារហេតុផលពីរយ៉ាងទេ ។ ហេតុផលទីមួយគឺថា សំណងខូចខាតជាទឹកប្រាក់មិនត្រូវបានទទួលស្គាល់ដោយវប្បធម៌ ហើយប្រជាជនកម្ពុជាមិនត្រូវការសំណងខូចខាតជាទឹកប្រាក់នេះទេ ។ ហេតុផលទីពីរ ទោះបីជាសំណងខូចខាតជាទឹកប្រាក់គឺជាគោលបំណងធំក៏ដោយ ក៏វាមិនអាចធ្វើទៅរួចឡើយសម្រាប់រដ្ឋាភិបាលដែរ ។ ដើម្បីផ្តល់សំណងទាំងនោះ អ្វីដែលរដ្ឋាភិបាលអាចនឹងផ្តល់ឲ្យបាននោះ ទំនងជាមិនអាចផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះឡើយ ពីព្រោះថាសំណងខូចខាតបែបនេះ ត្រូវបានបែងចែកទៅឲ្យជនរស់រានមានជីវិតទាំងអស់ ដោយមិនចាំបាច់និយាយអំពីការផ្តល់ជាសំណងខូចខាតជាទឹកប្រាក់សម្រាប់អ្នកដែលស្លាប់នោះទេ ។ ទោះបីជាសំណងខូចខាតដោយហិរញ្ញវត្ថុជាលទ្ធភាពមួយដែលអាចនឹងកើតឡើងក៏ដោយ ក៏បញ្ហានៃសំណងខូចខាតជាទឹកប្រាក់សម្រាប់អ្នកដែលបានបាត់បង់ជីវិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទំនងជាបង្កឲ្យមានចលាចលក្នុងសង្គមស៊ីវិល និងបង្កឲ្យមានការខឹងសម្បាចំពោះរដ្ឋាភិបាល ពីព្រោះថាការផ្តល់សំណងឲ្យសមាជិកគ្រួសារជំនួសមុខឲ្យអ្នកដែលបានបាត់បង់ជីវិតនោះ អាចនឹងចាត់ទុកថាជាការប្រមាថមួយលើជនរស់រានមានជីវិត ។ ពួកគេទំនងអាចនឹងមានអារម្មណ៍ថា នេះគឺជាការប្រមាថដ៏ពិតប្រាកដមួយដែលមានន័យថារដ្ឋាភិបាលដេញថ្លៃលើអាយុជីវិតរបស់មនុស្សជាទីស្រឡាញ់ដែលជាសមាជិកគ្រួសាររបស់គេ ។ ដូច្នេះ សំណងខូចខាតក្នុងប្រទេសកម្ពុជា គួរតែមានចរិតលក្ខណៈជាដំណើរការផ្សះផ្សា និមិត្តសញ្ញា ឬបែបសីលធម៌ ដែលមានគោលដៅដើម្បីបន្តការកសាងសង្គមជាតិឡើងវិញ និងនាំយកនូវយុត្តិធម៌អន្តរកាលដល់ជនរងគ្រោះរបស់របបខ្មែរក្រហម ។

យោងតាមសៀវភៅស្តីពីសំណងខូចខាត ពាក្យថា "សំណងខូចខាត" តាមន័យតុលាការបានដាក់បញ្ចូលបែបបទនៃការជួសជុលជាច្រើនសម្រាប់ជនរងគ្រោះនៃបទល្មើស រួមមានការស្តារឡើងវិញ សំណង នីតិសម្បទា និងសេចក្តីពេញចិត្ត និងការធានាទប់ស្កាត់មិនឲ្យមានការកើតឡើងនៃបទល្មើសនេះម្តងទៀតឡើយ ។ ដាប្ល ឌី ហ្រ្គីហ្វ ជំទាស់ថា ដំណោះស្រាយយុត្តាធិការចំពោះយុត្តិធម៌នេះ គឺជាបញ្ហាលំបាក ពីព្រោះវាមានគោលដៅ

ដោះស្រាយតែករណីដាច់ដោយឡែកមិនប្រាកដតែប៉ុណ្ណោះ ។ ដោយឡែក លោកក៏បានគាំទ្រថា យុត្តិធម៌គួរតែពិចារណាពីការសម្រេចឲ្យបាននូវគោលដៅបីគឺៈ ការទទួលស្គាល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ និងសាមគ្គីភាពរបស់សង្គម ។ កម្មវិធីកសាងឡើងវិញ និងសំណងខូចខាតក្នុងប្រទេសកម្ពុជា គួរតែដើរតួដោយរួមជាមួយនឹងគោលបំណងនៃការសម្រេចនូវគោលដៅទាំងបីនេះ ពីព្រោះជោគជ័យរបស់គោលបំណងទាំងនេះនឹងជួយគាំទ្រយ៉ាងសំខាន់ដល់បញ្ញត្តិរបស់យុត្តិធម៌តាមបែបផ្សះផ្សាដល់ជនរងគ្រោះ ក៏ដូចជាលើក កម្ពស់ដល់ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ការស្ថាបនាសង្គមជាតិទាំងស្រុង និងយុត្តិធម៌អន្តរកាល ។ តាមរយៈការបង្កើតគោលដៅនៃកម្មវិធីសំណងខូចខាតទាំងអស់នេះ សំណងខូចខាតគឺទំនងជានាំមកនូវយុត្តិធម៌អន្តរកាល និងការស្ថាបនាសង្គមជាតិឡើងវិញដល់សង្គមកម្ពុជាដ៏ទ្រុឌទ្រោម ។

ឌី ហ្គ្រីហ្វ អះអាងថា សំណងខូចខាត ត្រូវតែទទួលស្គាល់ឋានៈរបស់ជនល្មើសថាជាប្រជាពលរដ្ឋ ពីព្រោះថាគោលដៅរបស់យុត្តិធម៌អន្តរកាល គឺប្រគល់ ឬបង្កើតឋានៈជាប្រជាពលរដ្ឋដល់ជនល្មើស ។ ចំណែកឯគោលដៅរបស់កម្មវិធីសំណងខូចខាតវិញ គឺដើម្បីបន្តស្វែងរកយុត្តិធម៌អន្តរកាល ។ យ៉ាងណាមិញ មុននឹងជនល្មើសអាចនឹងត្រូវទទួលស្គាល់ជាប្រជាពលរដ្ឋ អ្នកទាំងអស់នេះត្រូវតែបានទទួលស្គាល់ជា "មនុស្សដែលមិនអាចជំនួស និង-ផ្លាស់ប្តូរ" បាន ។ ដូច្នេះ រដ្ឋាភិបាលគួរតែទទួលស្គាល់ មិនត្រឹមតែអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ដោយរបបខ្មែរក្រហមថាជាប្រជាពលរដ្ឋ និងផ្តល់ឲ្យគាត់នូវសិទ្ធិនេះតែប៉ុណ្ណោះទេ ប៉ុន្តែរដ្ឋាភិបាលគួរតែទទួលស្គាល់ និងគោរពប្រជាជនកម្ពុជាគ្រប់រូបទាំងអស់ថាជាឯកត្តបុគ្គល និងមានប្រយោជន៍ដល់សង្គមកម្ពុជា ។ នេះក៏ត្រូវបានគាំទ្រដោយការទទួលស្គាល់ និងការរិះគន់របស់សម្តេច ហ៊ុន សែន ពីរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្ត ដោយទទួលស្គាល់នូវទុក្ខវេទនារបស់ជនរងគ្រោះ ទោះបីជាមានបញ្ហាចោទឡើងដូចដែលបានលើកឡើងពីមុនទាក់ទងនឹងសេចក្តីថ្លែងការណ៍នេះក៏ដោយ ។ ការទទួលស្គាល់នេះអាចនឹងត្រូវបានបន្តជ្រួតជ្រាបបន្ថែមទៀត តាមរយៈការជំរុញឲ្យមានកិច្ចខិតខំប្រឹងប្រែងដែលរដ្ឋាភិបាល និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងតែព្យាយាមនាំយកនូវយុត្តិធម៌ឲ្យប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍ ។

ដោយសារតែសំណងខូចខាតស្ថិតនៅក្នុងបែបបទនៃការទទួលស្គាល់បែបនេះរួចស្រេចទៅហើយនោះ វាមានន័យថា កម្មវិធីសំណងខូចខាតប្រកបដោយជោគជ័យ និងប្រសិទ្ធភាពនឹងទទួលស្គាល់ជនល្មើសថាជាប្រជាពលរដ្ឋ និងមនុស្សដែលមិនអាចជំនួសបាន ។ ដូច្នេះ រដ្ឋាភិបាលកម្ពុជាគួរតែបង្កើតកម្មវិធីសង្គមដែលអនុញ្ញាតឲ្យអ្នករាល់គ្នាដែលចង់ចូលរួមទទួលបានឱកាសនេះ ។ ការធ្វើបែបនេះ អាចធ្វើបានតាមរយៈគំនិតផ្តួចផ្តើមដែលត្រូវបានរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល តាមរយៈការធ្វើជាដៃគូរបស់អង្គការក្រៅរដ្ឋាភិបាល ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរៀបចំគំនិតផ្តួចផ្តើមថ្មីមួយ ។ ជាមួយគ្នាដែរ ការធ្វើបែបនេះអាចធ្វើឡើងបានដោយរដ្ឋាភិបាលតែឯកឯង ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលពីរបៀបដែលត្រូវបន្តដំណើរការនេះ ។ គំនិតផ្តួចផ្តើមទាំងនេះគួរតែមានចែងនូវអ្វីដែល លោក ឆាំង យុ បានចាត់ទុកថាជាតម្រូវការចាំបាច់សម្រាប់ជនរងគ្រោះក្នុងគោលបំណងស្វែងរក "នរណាម្នាក់ដែលពិតជាអាចស្តាប់នូវរឿងរ៉ាវរបស់ជនរងគ្រោះទាំងអស់នោះ" បាន ពីព្រោះថានៅពេលដែលអ្នកស្តាប់រឿងរ៉ាវរបស់គេ វាពិតជាមានប្រយោជន៍ ។ នេះអាចផ្តល់ឲ្យជនរងគ្រោះនូវការទទួលស្គាល់ និងការគាំទ្រ ដែលជាតម្រូវការចាំបាច់ពីរបស់ជនរងគ្រោះ សម្រាប់យុត្តិធម៌អន្តរកាល ។ លើសពីនេះទៅទៀត ការផ្តល់នូវការទទួលស្គាល់នេះ ក៏នឹងបន្តដំណើរការយុត្តិធម៌តាមបែបអន្តរកាល ។ ជាមួយគ្នានេះដែរ បេសកកម្មស៊ើបអង្កេតមួយអាចនឹងផ្តល់នូវការទទួលស្គាល់ និងការគាំទ្រនេះ ហើយនឹងជួយពង្រឹងស្មារតីនៃភាពមានតម្លៃរបស់ជនល្មើស តាមរយៈការទទួលស្គាល់ពីទុក្ខលំបាកវេទនាដែលគេបានឆ្លងកាត់ បណ្តាលមកពីសកម្មភាពដែលប្រឆាំងលើខ្លួនគេក្នុងនាមជាមនុស្សដែលមិនអាចជំនួសបាន ។ ការទទួលស្គាល់នេះត្រូវបានពង្រឹងបន្ថែមដោយការធានាឲ្យមានស្ថានភាពនយោបាយបើកចំហមួយដែលបានលើកឡើងខាងលើ ដែលនេះអាចនឹងពង្រឹងស្មារតីនៃភាពមានតម្លៃរបស់ជនល្មើសតាមរយៈការទទួលស្គាល់ពីទុក្ខលំបាកវេទនារបស់គេ ។ សញ្ញាណនៃភាពមានតម្លៃរបស់ខ្លួន

ដែលបណ្តាលមកពីជនល្មើសត្រូវបានទទួលស្គាល់ដោយប្រទេសខ្លួនថាជាមនុស្សដែលមិនអាចជំនួសបាន និងជាប្រជាពលរដ្ឋនោះអាចនឹងត្រូវបានពង្រឹងតាមរយៈសំណងខូចខាតដូចជាការធ្វើឲ្យចងចាំដោយផ្តល់នូវការទទួលស្គាល់របស់ជាតិចំពោះទុក្ខលំបាកវេទនាបែបនោះ ។

ជាមួយគ្នានេះ សំណងខូចខាតត្រូវតែព្យាយាមផ្សះផ្សាប្តូបង្កើតជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋដែលលោក ឌី ហ្គ្រីហ្វ ចាត់ទុកថាជាជំនឿទុកចិត្តក្នុងចំណោមប្រជាពលរដ្ឋដែលជាសមាជិករបស់សហគមន៍នយោបាយដូចគ្នា ។ ហេតុដូច្នេះ សំណងខូចខាតនេះសន្មតថា សមាជិកដ៏ស្និទ្ធស្នាលនេះ នឹងចែករំលែកគោលការណ៍ដូចគ្នា និងចំណាប់អារម្មណ៍នៃការអនុវត្តរបស់គោលការណ៍ទាំងនេះ ។ ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ គឺជាកត្តាបំលាស់ប្តូរ និងជាមុខសញ្ញានៃជំនឿទុកចិត្តលើស្ថាប័នច្បាប់ដែលគាំទ្រពីសារសំខាន់នៃការយកចិត្តទុកដាក់ចម្បងបំផុតរបស់រដ្ឋាភិបាលកម្ពុជា និងផ្តោតការយកចិត្តទុកដាក់ទៅលើការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការស្តាបនាសង្គមជាតិឡើងវិញ ដោយចាត់ទុកជំនឿទុកចិត្តនេះថាជាដំណាក់កាលដំបូងក្នុងការផ្តល់នូវយុត្តិធម៌អន្តរកាល មុននឹងលុបបំបាត់អំពើពុករលួយ និងវប្បធម៌និទ្ទណ្ឌភាព ពីព្រោះថាប្រជាពលរដ្ឋត្រូវតែជឿជាក់ថា នៅពេលដែលគេទាំងអស់គ្នារាយការណ៍ពីបទឧក្រិដ្ឋកម្ម នោះប្រព័ន្ធច្បាប់នឹងផ្តល់នូវលទ្ធផលដ៏ស៊ីសង្វាក់គ្នាមួយ ដើម្បីដោះស្រាយអាកប្បកិរិយារំលោភបទដ្ឋានដែលត្រូវបានរាយការណ៍នោះ ។ យ៉ាងណាមិញ បញ្ញត្តិរបស់យុត្តិធម៌អន្តរកាលនឹងពង្រីកជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនេះ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការលុបបំបាត់អំពើពុករលួយ និងវប្បធម៌និទ្ទណ្ឌភាព តាមរយៈការបង្កើត និងបង្ហាញការធ្វើឡើងមុនដំបូងគេបង្អស់ថា ឧក្រិដ្ឋកម្មត្រូវតែផ្តន្ទាទោស ។ ការធ្វើបែបនេះ ត្រូវតែសម្រេចបានមួយផ្នែកតាមរយៈការឆ្លើយតបរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ហើយសំណងខូចខាតគួរតែត្រូវបានប្រើប្រាស់ ដើម្បីជំរុញឲ្យមានចរិតលក្ខណៈនៃជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ និងដើម្បីលើកកម្ពស់ការស្តាបនាសង្គមជាតិឡើងវិញ និងយុត្តិធម៌អន្តរកាល ។

ដោយសារតែសំណងខូចខាតនេះ គឺជាការឆ្លុះបង្ហាញមួយឲ្យឃើញថា ប្រទេសជាតិ និងប្រជាពលរដ្ឋដ៏ស្និទ្ធស្នាលរបស់គេពិតជាមានភាពប្រាកដប្រជាចំពោះកិច្ចខិតខំប្រឹងប្រែងដើម្បីផ្តល់នូវភាពស្មើគ្នា និងការគោរពជនរងគ្រោះនោះ សំណងខូចខាតអាចនឹងបង្កើនឲ្យមានជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ ក៏ដូចជាជំរុញឲ្យមានការផ្សះផ្សា និងយុត្តិធម៌អន្តរកាលបាន ។ រដ្ឋាភិបាលគួរតែធានាឲ្យបានថា គំនិតនៃភាពប្រាកដប្រជានេះ ត្រូវបានយល់ដឹង និងជ្រួតជ្រាបដោយប្រជាជន ។ ជាមួយគ្នាដែរ រដ្ឋាភិបាលគួរតែចូលរួម (ប្រសិនបើត្រូវបានស្នើសុំ) ក្នុងក្រុមទំនាក់ទំនងសាធារណៈដើម្បីបង្កើតយុទ្ធនាការសារព័ត៌មានរួមមួយដែលអាចផ្សព្វផ្សាយគំនិតនេះប្រកបដោយប្រសិទ្ធភាព ។ បន្ថែមលើនេះ ប្រសិនបើសំណងខូចខាតបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ នោះវាក៏អាចនឹងជំរុញឲ្យមានភាពរួបរួមគ្នាជាមួយនឹងរដ្ឋាភិបាល តាមរយៈមធ្យោបាយរបស់បញ្ញត្តិនៃភាពស្មើគ្នាសម្រាប់ប្រជាពលរដ្ឋទាំងអស់ ។ ភាពរួបរួមនេះមិនត្រឹមតែពង្រឹងការផ្សះផ្សាជាតិ និងការស្តាបនាសង្គមជាតិឡើងវិញប៉ុណ្ណោះទេ តែវាថែមទាំងផ្តល់នូវយុត្តិធម៌អន្តរកាល ដោយការលើកកម្ពស់ឲ្យមានលទ្ធភាពលទ្ធិប្រជាធិបតេយ្យដែលអាចកើតឡើងបាន ។

ដូច្នេះ កម្មវិធីសំណងខូចខាតនៅប្រទេសកម្ពុជា គួរតែជំរុញឲ្យមានស្មារតីនៃជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋដែលអាចធ្វើទៅបានតាមរយៈសេចក្តីណែនាំរបស់កម្មវិធីសង្គមផ្អែកលើព្រះពុទ្ធសាសនាដែលបានលើកឡើងរួចហើយខាងលើ ដោយសារការគូសបញ្ជាក់លើគោលការណ៍ព្រះពុទ្ធ ដែលគាំទ្រការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការស្តាបនាសង្គមជាតិឡើងវិញ ។ ជាមួយគ្នានេះ ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋអាចនឹងត្រូវបានពង្រឹងដោយសេចក្តីណែនាំរបស់បេសកកម្មស៊ើបអង្កេតដែលបានលើកឡើងខាងលើ ពីព្រោះថាគំនិតផ្តួចផ្តើមបែបនេះអាចនឹងបង្ហាញឲ្យឃើញថា រដ្ឋាភិបាលពិតជាមានភាពប្រាកដប្រជាក្នុងការគោរពដល់ទុក្ខលំបាកវេទនារបស់ប្រជាពលរដ្ឋទាំងអស់ដោយស្មើភាពគ្នា និងក៏ដោយសារតែគំនិតផ្តួចផ្តើមនេះអាចនឹងធ្វើឲ្យមានការចាប់ផ្តើមដំបូងបង្អស់ដែលបានលើកឡើងខាងលើថា រដ្ឋាភិបាលនឹងឆ្លើយតបទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តលើប្រជាពលរដ្ឋ

ទាំងនេះ ។ បញ្ញត្តិទាំងនេះអាចនឹងបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋចំពោះប្រព័ន្ធរដ្ឋាភិបាល ហើយនឹងពង្រឹងៈ

- យុត្តិធម៌តាមបែបផ្សះផ្សាដោយផ្តល់នូវការទទួលស្គាល់ការធ្វើសក្កម្ម និងការឧបត្ថម្ភដល់អ្នកទាំងឡាយដែលរងគ្រោះដោយរបបខ្មែរក្រហម ។
- ការកសាងសង្គមជាតិឡើងវិញ តាមរយៈការទទួលស្គាល់តម្លៃស្មើគ្នារបស់បុគ្គលគ្រប់រូប និងផ្តល់នូវវេទិកាពិភាក្សាសម្រាប់ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ។
- យុត្តិធម៌តាមបែបអន្តរកាលទាំងស្រុងតាមរយៈការពង្រឹងទស្សនៈនៃលទ្ធិប្រជាធិបតេយ្យ និងដំណើរការប្រជាធិបតេយ្យមួយ ។

សាមគ្គីភាពរបស់សង្គមត្រូវបានចាត់ទុកថាជា "ចរិតលក្ខណៈនៃភាពយោគយល់គ្នាមួយប្រភេទរបស់អ្នកទាំងឡាយណាដែលមានអត្តចរិត និងឆន្ទៈពីកំណើតដែលអាចដឹងពីអារម្មណ៍អ្នកដទៃ" ។ សាមគ្គីភាពនេះ គឺបណ្តាលមកពីសមត្ថភាពដែលអាចមានទស្សនៈមិនលម្អៀងមួយ នៅពេលវិនិច្ឆ័យពីសកម្មភាពរបស់អ្នកដទៃ ។ សាមគ្គីភាពនេះ ក៏ត្រូវបានចាត់ទុកថាមានសារសំខាន់សម្រាប់យុត្តិធម៌អន្តរកាល ពីព្រោះថាភាពមិនលម្អៀង គឺជាលក្ខខណ្ឌមួយយ៉ាងសំខាន់សម្រាប់ភាពយុត្តិធម៌ ។ នៅក្នុងកិរិយាបថដូចគ្នាដែលថា ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនឹងអនុវត្តទៅតាមការទទួលស្គាល់ នោះសាមគ្គីភាពរបស់សង្គមនឹងអនុវត្តទៅតាមជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ ។ ដោយសារតែហេតុផលនេះហើយ ទើបសាមគ្គីភាពរបស់សង្គមមិនមែនជាគោលដៅដ៏សមហេតុផលមួយសម្រាប់សំណងខូចខាត ដើម្បីសម្រេចឲ្យបាននៅក្នុងបរិបទនេះទេ ដោយសារតែកង្វះខាតនៃភាពជឿទុកចិត្តរបស់ប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។ សំណងខូចខាតអាចនឹងផ្តល់នូវសាមគ្គីភាពរបស់សង្គម និងគួរតែពិចារណាដើម្បីធ្វើដូច្នេះ ខណៈពេលដែលជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋត្រូវបានពង្រឹង ។

យ៉ាងណាមិញ ភាពខុសប្រក្រតីមួយគឺកំពុងតែកើតមានឡើងនៅក្នុងដំណើរការវិវត្តទៅមុខរបស់គោលដៅទាំងបីនេះ ជាពិសេសគឺថា សាមគ្គីភាពរបស់សង្គមហាក់បីដូចជាមានវត្តមាននៅក្នុងប្រទេសកម្ពុជា ទោះបីជាមានកង្វះខាតនៃជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋដ៏គួរឲ្យព្រួយបារម្ភក៏ដោយ ។ ភាពខុសប្រក្រតីនេះត្រូវបានបង្ហាញដោយអ្នកផ្តល់បទសម្ភាសន៍ដែលជាជនរងគ្រោះរបស់របបខ្មែរក្រហម ជាជាងជនដៃដល់ដែលជាជនរងគ្រោះដែរនោះ ។ គ្មានអតីតជនរងគ្រោះណាម្នាក់ជឿថា ជនដៃដល់ដែលកំពុងរស់នៅក្នុងភូមិរបស់គេសមនឹងត្រូវបានផ្តន្ទាទោសនោះទេ ។ ឧទាហរណ៍ តាំ តែ (អ្នកជិតខាងរបស់ ហ៊ឹម ហ៊ុយ) បាននិយាយ-ថា ហ៊ឹម ហ៊ុយ មិនគួរត្រូវបានផ្តន្ទាទោសទេ ពីព្រោះ ហ៊ឹម ហ៊ុយ គ្រាន់តែធ្វើតាមបញ្ជាប៉ុណ្ណោះ ។ ក្នុងទិដ្ឋភាពបែបនេះ ការវិនិច្ឆ័យរបស់ តាំ តែ ចំពោះអាកប្បកិរិយារបស់ ហ៊ឹម ហ៊ុយ បានធ្វើជាឧទាហរណ៍នៃវត្តមានសាមគ្គីភាពរបស់សង្គម ពីព្រោះថា តាំ តែ អាចនឹងយល់ពីមុខងាររបស់ ហ៊ឹម ហ៊ុយ និងយល់ពីឧក្រិដ្ឋកម្មដែល ហ៊ឹម ហ៊ុយ ប្រព្រឹត្ត ដោយសារតែមុខងារដែល ហ៊ឹម ហ៊ុយ ត្រូវបំពេញ ។ យ៉ាងណាមិញ វាគួរតែត្រូវបានកត់សម្គាល់ថាមិនមែនជនរងគ្រោះទាំងអស់ទេដែលគិតថា ជនដៃដល់មិនគួរត្រូវផ្តន្ទាទោសដោយសារហេតុផលនេះនោះឡើយ ។ ជាងនេះ អ្នកផ្តល់បទសម្ភាសន៍ជាច្រើនក្នុងចំណោមអ្នកទាំងនេះបាននិយាយជាសាធារណៈថា ទុកឲ្យទណ្ឌកម្មរបស់ជនដៃដល់ទាំងនេះអាស្រ័យលើផលកម្មរបស់គេចុះ ។ ឧទាហរណ៍ មុំ សារឿន បាននិយាយថា ប្រសិនបើនរណាម្នាក់នៅក្នុងភូមិរបស់នាងសមនឹងត្រូវទទួលទណ្ឌកម្មនោះ នាងនឹងដាក់ទណ្ឌកម្មពួកគេដោយខ្លួនឯងយូរណាស់មកហើយ ។ ហេតុដូច្នេះហើយ ជនល្មើសដែលរស់នៅក្នុងភូមិរបស់នាងនឹងប្រឈមមុខនឹងការដាក់ទណ្ឌកម្មរបស់ខ្លួន ។

ការធ្វើឲ្យចងចាំ គឺត្រូវបានផ្តល់ឲ្យដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល (ICTJ) ដែលជាគំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមទាំងប្រាំ ដើម្បីជួយផ្គត់ផ្គង់ក្នុងដំណើរការសម្រេចនូវយុត្តិធម៌អន្តរកាល ។ ការធ្វើឲ្យចងចាំនេះក៏ជាគម្រោងមួយដ៏មានភាពស្មុគស្មាញដែលអាចជួយផ្គត់ផ្គង់ដល់ការកសាងសង្គមជាតិឡើងវិញផងដែរ ។ ការចងចាំគួរតែត្រូវបានបង្កើតឡើងដើម្បីជំរុញដល់ការទទួលស្គាល់របស់រដ្ឋាភិបាលថាប្រជាជនកម្ពុជាជាឯកត្តបុគ្គលនិងជាប្រជាពលរដ្ឋ ។ ជាមួយគ្នានេះដែរ ការចងចាំនេះគួរតែត្រូវបានបង្កើតឡើងដើម្បីពង្រីកជំនឿ

ទុកចិត្តរបស់ប្រជាពលរដ្ឋ ដោយបង្ហាញពីភាពប្រាកដប្រជារបស់រដ្ឋាភិបាលកម្ពុជាតាំងពីការប្រព្រឹត្តចំពោះប្រជាពលរដ្ឋរបស់ខ្លួនដោយស្មើភាព និងសេចក្តីគោរព ។ ហើយវាក៏នឹងបង្ហាញពីការដោះស្រាយ អាកប្បកិរិយារំលោភលើបទដ្ឋាន និងឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាពលរដ្ឋទាំងនេះផងដែរ ។ តាមរយៈការឲ្យឈ្មោះថ្មីដល់ផងវិថី ការបង្កើតការចងចាំ និងការបំពេញគំនិតផ្តួចផ្តើមនៃការចងចាំផ្សេងទៀត នោះសង្គមកម្ពុជានឹងផ្តល់ការទទួលស្គាល់ដល់អ្នកទាំងឡាយណាដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមផ្តល់កិត្តិយសដល់អ្នកដែលបានបាត់បង់ជីវិតក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ និងជួយបង្កើតនូវកំណត់ត្រាប្រវត្តិសាស្ត្រ និងការយល់ដឹងសម្រាប់សហគមន៍អន្តរជាតិ តាមរយៈការផ្សព្វផ្សាយព័ត៌មានជូនភ្ញៀវទេសចរណ៍ពីការចងចាំនេះ ។ រដ្ឋាភិបាលកម្ពុជាគួរតែសហការជាមួយនឹងសារព័ត៌មានដើម្បីជំរុញឲ្យមានចំណាប់អារម្មណ៍ក្នុងវិស័យទេសចរណ៍ពីការចងចាំ ដែលវាអាចជំរុញឲ្យមានការវិនិយោគទុនបរទេស និងការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច ។ នេះបង្ហាញឲ្យឃើញសាជាថ្មីម្តងទៀតថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋត្រូវតែដើរមុនការលុបបំបាត់អំពើពុករលួយ និងភាពទាក់ទងគ្នានឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចរបស់រដ្ឋាភិបាលនេះ ពីព្រោះថាកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ (ដូចជាការធ្វើឲ្យចងចាំ) នឹងជំរុញឲ្យមានដំណើរការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ។ ហើយក្នុងរយៈពេលនោះ ការលុបបំបាត់អំពើពុករលួយអាចនឹងកើតឡើងស្របគ្នាដែរ ។ ផលប្រយោជន៍វិស័យអប់រំនៃការចងចាំបែបនេះមិនគួរធ្វើឡើងដោយមិនមានការកត់ត្រាទុកនោះទេ ។ ហើយការចងចាំនេះ គួរតែត្រូវបានប្រើប្រាស់ក្នុងកម្មវិធីសិក្សាតាមវិទ្យាល័យ ដើម្បីពង្រីកបទពិសោធន៍នៃការសិក្សាពីរបបខ្មែរក្រហមរបស់យុវជនកម្ពុជា ។

ទោះបីជាពិបាក និងមិនមានប្រសិទ្ធភាពដោយសារតែកង្វះខាតការផ្សព្វផ្សាយពីការកកើតឡើង និងសារសំខាន់ពីការចងចាំនេះឲ្យទូលំទូលាយក៏ដោយ ក៏បច្ចុប្បន្ននេះ មានកិច្ចខិតខំប្រឹងប្រែងការបង្កើតការចងចាំក្នុងប្រទេសកម្ពុជាដែរ ។ ការចងចាំមួយក្នុងចំណោមការចងចាំទាំងអស់នេះគឺនៅថ្ងៃទី២០ ឧសភា ដែលជា «ទិវាចងកំហឹង» ប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា ។ ក្នុងឆ្នាំ២០០៨ ប្រជាជនកម្ពុជាប្រមាណពីពាន់នាក់ បានចូលរួមការប្រារព្ធរំឭកខួបនៃថ្ងៃនេះនៅបូជនីយដ្ឋានជើងឯក ដែលជាសារមន្ទីរប្រល័យពូជសាសន៍និងជាអតីតវាលពិឃាតរបស់ខ្មែរក្រហម ។ នៅទីនោះសិស្សានុសិស្សបានរៀបចំការសម្តែងឡើងវិញនៃឧក្រិដ្ឋកម្មសាហាវយង់ឃ្នងដែលប្រព្រឹត្តដោយរបបខ្មែរក្រហម ដើម្បីរំឭកពីជីវិតដែលបានបាត់បង់ក្នុងរបបនោះ ។ យ៉ាងណាមិញ អេចឆេសុនកត់សម្គាល់ថា "ជាច្រើនឆ្នាំកន្លងមកនេះ ប្រជាជនបានទទួលស្គាល់យ៉ាងច្បាស់ពីចរិតលក្ខណៈក្នុងផ្នែកនយោបាយនៃការប្រតិបត្តិតាមបញ្ញត្តិសាសនារបស់មន្ត្រីរដ្ឋាភិបាល ហើយការចូលរួមកាន់តែមានចំនួនតិចតួចដើម្បីបញ្ចុះលជំនឿទុកចិត្តលើគណបក្សដឹកនាំភាគច្រើន និងក៏ដូចជាជំនឿទុកចិត្តទៅលើអ្នកដែលចូលរួមការប្រារព្ធពិធីនេះក្នុងគោលបំណងរៀបចំទម្លាប់នៃការគោរពដូនតាតាមបែបសាសនាជាឯកជនមួយ ។ ដូច្នេះ រដ្ឋាភិបាលត្រូវតែផ្តល់នូវកិច្ចខិតខំប្រឹងប្រែងនៃការធ្វើឲ្យចងចាំដែលលើកឡើងខាងលើ ដោយឥរិយាបថប្រាកដប្រជា និងស្មោះត្រង់ដើម្បីផ្តល់កិត្តិយសដល់ជនរងគ្រោះជំនួសឲ្យការបន្តរបៀបវារៈបែបនយោបាយរបស់ខ្លួន ។ កិច្ចខិតខំប្រឹងប្រែងនៃការធ្វើឲ្យមានការចងចាំទាំងនេះគឺពិតជាមានសារសំខាន់ក្នុងការបន្តដំណើរការផ្សះផ្សាជាតិ ពីព្រោះវានឹងជួយធ្វើឲ្យជនរងគ្រោះក៏ដូចជាជនដៃដល់ទទួលស្គាល់អតីតកាល ។ ប្រសិនបើការចងចាំត្រូវបានរៀបចំធ្វើឡើងដោយរបៀបរៀបរយ នោះវានឹងអាចគាំទ្រដល់បញ្ញត្តិរបស់យុត្តិធម៌តាមបែបផ្សះផ្សាក្នុងប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍បាន ។

ការបង្កើនការចូលរួមរបស់ជនរងគ្រោះ គួរតែត្រូវចាត់ទុកថាជាអាទិភាពចម្បងបំផុត ពីព្រោះថាប្រសិនបើគ្មានការចូលរួមរបស់ជនរងគ្រោះរបស់ខ្មែរក្រហម (ទាំងជនរងគ្រោះតែឯកឯងឬជនដៃដល់របស់ជនរងគ្រោះ) នោះយុត្តិធម៌តាមបែបផ្សះផ្សាមិនអាចត្រូវបានផ្តល់ឲ្យពួកគេឡើយ ដែលជាកត្តានាំឲ្យរារាំងដល់ដំណើរការផ្សះផ្សាច្រើនកម្រិតផងដែរ ។ ការចូលរួមរបស់ជនរងគ្រោះត្រូវតែបានជំរុញបង្កើនឡើង តាមរយៈសំណងខូចខាតជាពិសេសកម្មវិធីសង្គមដែលលើកកម្ពស់ដល់ការព្យាបាលរបួស និងការផ្សះផ្សាជាច្រើនលំដាប់ថ្នាក់ គំនិតផ្តួចផ្តើមនៃការធ្វើឲ្យមាន

ការបង់ចាំ ដោយផ្តល់កិត្តិយសឲ្យជនរងគ្រោះ ការទទួលស្គាល់ភាពឈឺចាប់របស់ជនរងគ្រោះ និងសេចក្តីសម្រេចដែលត្រូវបានបង្កើនឡើងដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងរដ្ឋាភិបាលដោយមានជំនួយពីអង្គការក្រៅរដ្ឋាភិបាលដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជាជាដើម ដើម្បីឲ្យជនរងគ្រោះចូលរួមក្នុងដំណើរការផ្នែកច្បាប់ និងយ៉ាងហោចណាស់បង្ហាញប្រជាជនកម្ពុជាថារដ្ឋាភិបាលពិតជាមានភាពប្រាកដប្រជាពីការផ្តល់នូវយុត្តិធម៌តាមតុលាការ ដែលជាកិច្ចឆ្លើយតបនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តប្រឆាំងលើគេទាំងអស់គ្នា ។ យោងតាមសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អ្នកទាំងឡាយណាដែលកើតក្រោយឆ្នាំ១៩៧៩ "នៅតែទទួលបន្ទុកធ្ងន់ធ្ងរ...ចែករំលែក ។ ដោយមានផលលំបាកក្នុងការកសាងសង្គមសាឡើងវិញពីឆ្នាំសូន្យ ដោយគ្មានទទួលប្រយោជន៍ពីឧត្តមគតិ និងបទពិសោធន៍របស់អ្នកដែលត្រូវបាត់បង់ជីវិត" ជនរងគ្រោះរបស់របបខ្មែរក្រហមទាំងអស់គួរតែត្រូវចូលរួមក្នុងគំនិតផ្តួចផ្តើមទាំងនេះដើម្បីជំរុញការចូលរួមរបស់ជនរងគ្រោះ ។ ចំណែកឯប្រជាជនដែលមានវ័យក្មេងល្មមគួរតែទទួលបានគំនិតផ្តួចផ្តើមបែបនេះ ដើម្បីរួមបញ្ចូលទៅក្នុងកម្មវិធីសិក្សាប្រចាំឆ្នាំរបស់គេ ។ ដោយឡែក គំនិតផ្តួចផ្តើមតូចជាងនេះក្នុងការជំរុញឲ្យមានការចូលរួមរបស់ជនរងគ្រោះដែលត្រូវបានណែនាំដោយ ថាយល័រ គឺថារដ្ឋាភិបាលកម្ពុជាគួរតែ "អនុញ្ញាតឲ្យបុគ្គលធម្មតាអាចទទួលបានសំណុំឯកសាររបស់រដ្ឋាភិបាលបាន" ។ ជាសរុប ការចូលរួមរបស់ជនរងគ្រោះត្រូវតែបានបង្កើតឡើងដើម្បីអនុញ្ញាតបុគ្គលអាចព្យាបាលរបួសបាន ដែលនេះជួយលើកកម្ពស់ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការស្តាបនាសង្គមជាតិឡើងវិញ ។ ហើយការចូលរួមរបស់ជនរងគ្រោះនេះក៏ធ្វើឡើងដើម្បីផ្សព្វផ្សាយព័ត៌មានដល់ជនរងគ្រោះថា បទល្មើសដែលប្រព្រឹត្តមកលើគេកំពុងត្រូវបានដោះស្រាយ ដើម្បីលើកកម្ពស់ដល់ការពិតនៃយុត្តិធម៌ តាមបែបផ្សះផ្សា និងយុត្តិធម៌តាមការដាក់ទណ្ឌកម្ម ។

សង្គមស៊ីវិលដែលមានការចូលរួមពីអន្តរជាតិគួរតែមានចលនាទៅមុខដើម្បីអភិវឌ្ឍសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ដែលអាចនឹងជួយពង្រឹងដល់ការស្តាបនាសង្គមជាតិឡើងវិញ តាមរយៈការជំរុញស្មារតីនៃភាពមានតម្លៃរបស់បុគ្គល ដោយទទួលស្គាល់ឋានៈរបស់គេក្នុងនាមជាមនុស្សដែលមិនអាចជំនួសបាន និងដោយសេចក្តីគោរព និងភាពស្មើគ្នាដែលគេអាចទទួលយកបានដូច្នោះដែរ ។ ជាមួយគ្នានេះ ការធ្វើបែបនេះក៏នឹងអាចពង្រឹងយុត្តិធម៌អន្តរកាលតាមរយៈការលើកកម្ពស់គោលការណ៍លទ្ធិប្រជាធិបតេយ្យដូចជាមូលដ្ឋានសិទ្ធិមនុស្ស សេរីភាព និងយុត្តិធម៌ ។ ទាក់ទងនឹងការសរសេររបស់ អាន ហ្វ៊ីនី ក្នុងសៀវភៅដែលមានចំណងជើងថា "*The Third Force*" បាននិយាយថា ការរីកលូតលាស់របស់សង្គមស៊ីវិលដែលមានការចូលរួមពីអន្តរជាតិ ដោយផ្អែកលើតួនាទីរបស់សង្គមស៊ីវិលដែលឆ្លងកាត់ប្រទេសក្នុងការពង្រឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅក្នុងប្រទេស ជាមួយនឹងបទដ្ឋានរំលោភភាពជាអ្នកដឹកនាំនោះ សង្គមស៊ីវិលដែលមានប្រទេសច្រើនគួរតែមានចលនាទៅមុខដើម្បីអភិវឌ្ឍសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ។ ដូច្នេះ សង្គមស៊ីវិលដែលមានការចូលរួមពីអន្តរជាតិគួរតែបង្កើនការយល់ដឹងផ្នែកសីលធម៌របស់សហគមន៍អន្តរជាតិ ជាជាងសហគមន៍នយោបាយអន្តរជាតិ ដែលទាក់ទងនឹងអ្វីដែលបានកើតឡើងក្នុងប្រទេសកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធសារព័ត៌មានដើម្បីធ្វើឲ្យឧក្រិដ្ឋកម្មខ្មែរក្រហមរីកសុសសាយ និងធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងកើតមានឡើងដើម្បីនាំយកនូវយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហមនិងជូនប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍ ។ ការយល់ដឹងផ្នែកសីលធម៌របស់សហគមន៍អន្តរជាតិនេះធ្វើឡើងក៏ដើម្បីរៃអង្គាសជំនួយជាទឹកប្រាក់សម្រាប់គំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះវិសាមញ្ញ និងរបស់អង្គការក្រៅរដ្ឋាភិបាល ។ ការជំរុញបង្កើនការយល់ដឹងផ្នែកសីលធម៌នេះនឹងជួយបង្កើនការគាំទ្រក្នុងប្រទេស និងជួយដាក់គំនាបលើរដ្ឋាភិបាលដើម្បីជួយឧបត្ថម្ភដល់ដំណើរយុត្តិធម៌ផ្លូវច្បាប់របស់កម្ពុជា ដោយជ្រោមជ្រែងរកជំនួយពីអន្តរជាតិនិងមូលនិធិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកម្មវិធីជួយសង្គ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការយល់ដឹងផ្នែកសីលធម៌ និងការឧបត្ថម្ភក្នុងស្រុកតាមលំដាប់ថ្នាក់ក្នុងវិសាលភាពអន្តរជាតិក៏គួរតែបង្កើនជំនួយឧបត្ថម្ភឯកជន និងកិច្ចខិតខំប្រឹងប្រែងក្នុងការរៃអង្គាសមូលនិធិសម្រាប់អង្គការក្រៅរដ្ឋាភិបាល ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងទិដ្ឋភាពបែបនេះ សង្គមស៊ីវិលដែល

ឆ្លងកាត់ប្រទេសច្រើន អាចប្រើប្រាស់ឬជំនួសជនល្បីល្បាញដែលអាចទាក់ទាញចំណាប់អារម្មណ៍ជាធម្មតាសម្រាប់វិបត្តិសិទ្ធិមនុស្សបែបនេះមួយ និងអាចបង្កើតនូវការគាំទ្រយ៉ាងមានប្រជាប្រិយភាពតាមបណ្តាប្រទេសដទៃទៀតសម្រាប់កិច្ចខិតខំប្រឹងប្រែងដ៏ធូរស្បើយនេះ ។

សារព័ត៌មានបានលេចឡើងនៅក្នុងគោលការណ៍បញ្ញត្តិនេះថាជាអ្នកដើរតួដ៏មានសារសំខាន់ក្នុងការប្រកាសផ្សព្វផ្សាយអ្វីៗទាំងអស់ ចាប់ពីសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលដល់គំនិតផ្តួចផ្តើមរបស់អង្គការក្រៅរដ្ឋាភិបាល ។ ការប្រើប្រាស់ដ៏មានប្រសិទ្ធភាពតាមរយៈកម្មវិធីសំណាងខ្ទង់ខាត ការផ្តួចផ្តើម ការសង្គ្រោះ និងយុទ្ធនាការទំនាក់ទំនងសាធារណៈរបស់រដ្ឋាភិបាលគួរតែត្រូវបានចាត់ទុកថាជាឧបករណ៍ដ៏មានឥទ្ធិពលក្នុងការនាំមកនូវលទ្ធផលសម្រេចរបស់គោលដៅនៃសកម្មភាពបែបនេះ ការសម្រេចយុត្តិធម៌អន្តរកាល ដោយរួមទាំងយុត្តិធម៌តាមការផ្សះផ្សា និងយុត្តិធម៌តាមការដាក់ទណ្ឌកម្ម ហើយទាំងស្រុងគឺការស្តាបនាសង្គមជាតិឡើងវិញតាមរយៈការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ។ រាជរដ្ឋាភិបាលកម្ពុជាគួរតែសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលដើម្បីផ្សារភ្ជាប់សារព័ត៌មានទៅក្នុងមូលហេតុដែលពាក់ព័ន្ធគ្នារបស់អង្គភាពទាំងពីរ ទាក់ទងនឹងការផ្សព្វផ្សាយកិច្ចខិតខំប្រឹងប្រែងដែលត្រូវព្យាយាមធ្វើឡើង និងគំនិតផ្តួចផ្តើមដែលកំពុងធ្វើឲ្យកើតឡើង ដើម្បីជំរុញការចូលរួមរបស់ជនរងគ្រោះ និងដើម្បីនាំយកនូវយុត្តិធម៌តាមការផ្សះផ្សា និងដាក់ទណ្ឌកម្មជូនដល់ប្រទេសកម្ពុជា ។ ការផ្សព្វផ្សាយពីកិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងដឹកនាំទៅរកការផ្សព្វផ្សាយដ៏ទូលំទូលាយមួយពីការទទួលស្គាល់របស់រដ្ឋាភិបាលថាប្រជាជនកម្ពុជាទាំងអស់គឺជាឯកត្តជន និងប្រជាពលរដ្ឋ ហើយនឹងផ្សព្វផ្សាយពីកិច្ចខិតខំប្រឹងប្រែងដ៏ពិតប្រាកដ ជាក់ស្តែង ដើម្បីជាការឆ្លើយតបនឹងឧក្រិដ្ឋកម្មខ្មែរក្រហមដោយជំរុញបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋ ។

សារព័ត៌មានទាំងអស់ គួរតែឧបត្ថម្ភគាំទ្រដល់កម្មវិធីបន្ថែមទៀតដែលមានមូលដ្ឋានទាំងនៅអង្គជំនុំជម្រះវិសាមញ្ញ ឬដែលបំពេញតួនាទីដើម្បីគោលដៅនៃការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ។ ការបង្ហាញពីការជំរុញចុងក្រោយដែលអាចកើតឡើងបានមួយនោះ គឺដើម្បីផលិតជារឿងល្ខោនដែលទទួលស្គាល់ភាពស្មុគស្មាញដែលកំពុងកើតមានឡើងក្នុងសង្គមដោយសាររបបខ្មែរក្រហម ។ ដូចគ្នានឹងល្ខោនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានចំណងជើងថា ទម្ងាយភាពស្ងប់ស្ងាត់ ការផលិតល្ខោននេះក៏មានគោលបំណងដូច្នេះដែរ ។ ដូចការស្រាវជ្រាវរបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ារកឃើញថា បន្ទាប់ពីសារ-ព័ត៌មានផ្សព្វផ្សាយ ដោយកម្មវិធីទូរទស្សន៍ជាក់លាក់មួយចំនួន រឿងល្ខោនគឺជាប្រភពចំណេះដឹងទីពីរទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អង្គការក្រៅរដ្ឋាភិបាលគួរតែសហការជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន ដើម្បីបង្កើតកម្មវិធីពិសេសដែលមានទីតាំងនៅអង្គជំនុំជម្រះវិសាមញ្ញ ។ បើអាចធ្វើទៅបានគឺអាស្រ័យលើបណ្តាញដែលបង្កើតឡើងដោយរដ្ឋាភិបាលសម្រាប់កម្មវិធីបែបនេះ ដូចដែលបានណែនាំខាងលើ ។ ដោយមានអង្គការក្រៅរដ្ឋាភិបាលសហការជាមួយនឹងប្រព័ន្ធសារព័ត៌មានដោយគ្មានការចូលរួមពាក់ព័ន្ធពីរដ្ឋាភិបាល នោះមិនមែនត្រឹមតែអាចការពារមិនឲ្យការចោទប្រកាន់អំពើពុករលួយកើតមានប៉ុណ្ណោះទេ ប៉ុន្តែគុណភាពនៃកម្មវិធីនឹងមានគុណភាពកាន់តែខ្ពស់ឡើងថែមទៀតផង ពីព្រោះថាវានឹងជួយឆ្លុះបញ្ចាំងឲ្យឃើញកាន់តែប្រសើរឡើងពីអត្តចរិតនិងមនោសញ្ចេតនារបស់ប្រជាជនកម្ពុជា ។ ដូច្នេះ វាអាចដោះស្រាយការចោទប្រកាន់អំពើពុករលួយកាន់តែមានប្រសិទ្ធភាពឡើង ដោយមានទំនាក់ទំនងជាមួយនឹងគោលបំណងនៃការជួយឧបត្ថម្ភដល់ការស្តាបនាសង្គមជាតិឡើងវិញ ។ កម្មវិធី “៦០ នាទី” បង្ហាញពីលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមានបទសម្ភាសន៍ជាមួយចៅក្រម និងអ្នកគោរពសាសនា ឬអ្នកជំនាញផ្នែកសារព័ត៌មានដែលតែងតាំងជាតំណាងឲ្យចៅក្រម និងអ្នកដឹកនាំសាសនាទាំងនេះដែលនឹងផ្សព្វផ្សាយព័ត៌មានទាក់ទិននឹងដំណើរការទៅមុខរបស់តុលាការ និងតួនាទីរបស់សក្ខីកម្មជាក់លាក់ណាមួយអាចនឹងមានប្រយោជន៍យ៉ាងខ្លាំងក្នុងការជំរុញឲ្យដំណើរការទៅមុខដែលតុលាការបានធ្វើឡើងបន្តកែតម្រូវភាពយល់ឃើញខុសគ្នាពីទស្សនៈនៃភាពយុត្តិធម៌របស់សហគមន៍អន្តរជាតិនិងរបស់កម្ពុជា និងការពន្យារពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ទាំងព័ត៌មាន

និងសារព័ត៌មានកម្សាន្តគឺពិតជាមានតម្លៃចំពោះសេចក្តីសម្រេចរបស់យុត្តិធម៌អន្តរកាល និងការស្តាបនាសង្គមជាតិឡើងវិញ ។ ជាមួយគ្នានេះ កម្មវិធីសារព័ត៌មាននេះគួរតែត្រូវបានចូលរួមដោយរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលខ្លាចក្រែងតម្លៃដ៏សំខាន់របស់កម្មវិធីបែបនេះទទួលបរាជ័យ ដោយសារតែកង្វះខាតដែលអាចក្លាយជាគ្រោះថ្នាក់ជាជាងផលប្រយោជន៍មួយ ដើម្បីធ្វើឲ្យគោលដៅទាំងនេះមានភាពប្រាកដប្រជា ។

ជាលក្ខណៈអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានដើរតួយ៉ាងសំខាន់ប្រហាក់ប្រហែលគ្នានេះដែរ តាមរយៈការជំរុញឲ្យមានការឧបត្ថម្ភយ៉ាងពេញទំហឹងពីសំណាក់មូលនិធិអន្តរជាតិសម្រាប់អ្វីៗដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនឡើងរបស់ជនភៀសខ្លួនដែលមានចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សារព័ត៌មានគឺជាកូនសោគន្លឹះមួយក្នុងការជំរុញឲ្យសង្គមស៊ីវិលអន្តរកាលមានចលនាទៅមុខ ដើម្បីគាំទ្រយុទ្ធសាស្ត្រក្នុងប្រទេសដោយរួមមានការចូលរួមពីប្រទេសឧស្សាហកម្មផ្សេងៗ ដែលមានសមត្ថភាពក្នុងការផ្តល់មូលនិធិដល់ការផ្តួចផ្តើមគំនិតរបស់អង្គការក្រៅរដ្ឋាភិបាល សម្រាប់ការស្តាបនាសង្គមជាតិឡើងវិញ និងសម្រាប់ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ ។ ទាំងរដ្ឋាភិបាលកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាលគួរតែទាញយកប្រយោជន៍ពីតុលាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីធ្វើជាមធ្យោបាយមួយសម្រាប់ទាញយកចំណាប់អារម្មណ៍អន្តរជាតិចំពោះគោលដៅទាំងនេះ ។ ដូចដែលបានឃើញដោយកង្វះខាតនូវអត្ថបទសារព័ត៌មានស្តីពីដំណើរការរបស់តុលាការ នៅក្នុងកាសែត (The New York Times) មានកង្វះខាតគួរឲ្យកត់សម្គាល់មួយទាក់ទងនឹងសារព័ត៌មានអន្តរជាតិ ដែលគ្របដណ្តប់លើដំណើរការរបស់តុលាការ ចុះទម្រាំកិច្ចខិតខំប្រឹងប្រែងសម្រាប់ការផ្សះផ្សា ឬគោលនយោបាយក្នុងប្រទេសរបស់កម្ពុជា ដែលរារាំងដល់ការចូលរួមរបស់សង្គមស៊ីវិលដែលមានប្រទេសច្រើនបានឆ្លងកាត់ និងសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់ជំនួយដល់ភាពប្រាកដប្រជាឲ្យមានយុត្តិធម៌អន្តរកាល និងការស្តាបនាសង្គមជាតិឡើងវិញក្នុងប្រទេសកម្ពុជាយ៉ាងណា ។ ជាមួយគ្នានេះផងដែរ ការកើនឡើងនៃចំណាប់អារម្មណ៍អន្តរជាតិ និងការចូលរួមក្នុងការផ្តួចផ្តើមគំនិតរបស់អង្គការក្រៅរដ្ឋាភិបាល ដោយបែងចែកឲ្យដាច់ដោយឡែកពីគោលនយោបាយដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិ អាចនឹងមានផលប៉ះពាល់ទីពីរដល់ការធ្វើឲ្យប្រជាជនកម្ពុជាមានអារម្មណ៍ហាក់បីដូចជាថា ពួកគេត្រូវបានឧបត្ថម្ភគាំទ្រដោយសហគមន៍អន្តរជាតិទៅវិញ ។ ហេតុដូច្នេះ មិនមែនត្រឹមតែអយុត្តិ-ធម៌ដែលពួកគេទទួលរងគ្រោះទទួលស្គាល់ប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែសហគមន៍អន្តរជាតិក៏ចង់ជួយប្រជាជនកម្ពុជាទទួលបាននូវភាពមានតម្លៃផ្ទាល់ខ្លួនរបស់គេដែរ ។

## សេចក្តីសន្និដ្ឋាន

ដោយពិចារណាលើការវិភាគរបស់យើងលើការផ្តួចផ្តើមគំនិតផ្សេងៗដែលអាចនាំយកយុត្តិធម៌អន្តរកាលជូនដល់ប្រទេសកម្ពុជា រួមមានភាពស្មុគស្មាញផ្សេងៗ និងកត្តាសម្រាលទោសដែលមានទាក់ទងនឹងគោលបំណងនេះនោះ អត្ថបទនេះយល់ឃើញថា ក្នុងចំណោមគំរូ (ICTJ) ទាំងប្រាំដែលបានលើកឡើងខាងលើដើម្បីនាំយកយុត្តិធម៌អន្តរកាលនេះ ការដាក់រួមបញ្ចូលគ្នារវាងការកាត់ទោសព្រហ្មទណ្ឌ កម្មវិធីសំណងខូចខាត និងកិច្ចខិតខំប្រឹងប្រែងធ្វើឲ្យមានការចងចាំអាចនឹងមានប្រសិទ្ធភាព និងជាវិធីដែលមានភាពជាក់លាក់ និងដែលនាំមកនូវលទ្ធផលល្អតែមួយគត់ដែលដើរតួដើម្បីផ្តល់នូវយុត្តិធម៌ដល់ជនរងគ្រោះកម្ពុជារបស់របបខ្មែរក្រហម និងជួយសម្រួលដល់ការផ្សះផ្សាថ្នាក់ជាតិ សហគមន៍និងបុគ្គលក្នុងប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍ ។ ការពិភាក្សានេះ គឺផ្អែកលើសេចក្តីសន្និដ្ឋានដែលថាៈ ការកាត់ទោសព្រហ្មទណ្ឌក្នុងទម្រង់បែបបទរបស់អង្គជំនុំជម្រះវិសាមញ្ញអាចនឹងនាំយកយុត្តិធម៌តាមការដាក់ទណ្ឌកម្ម ប្រសិនបើត្រូវបានរៀបចំដោយស្មើភាព និងរួមជាមួយនឹងកម្មវិធីដែលត្រូវបានបង្កើតឡើងដើម្បីគូសបញ្ជាក់ទៅលើការទទួលស្គាល់របស់រដ្ឋាភិបាលលើប្រជាជននីមួយៗថា ជាឯកត្តបុគ្គលម្នាក់ និងជាប្រជាពលរដ្ឋដោយពង្រឹងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋលើប្រព័ន្ធច្បាប់របស់ប្រទេស ។ ការបង្កើតឡើងនៃបេសកកម្មស៊ើបអង្កេតដែលមានភាពពាក់ព័ន្ធជាមួយនឹងកម្មវិធីសំណងខូចខាត អាចនឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការផ្តល់នូវយុត្តិធម៌តាមបែបផ្សះផ្សាដល់ជនរងគ្រោះកម្ពុជារបស់របបខ្មែរក្រហម និងជួយសម្រួលដល់ការផ្សះផ្សាដែលមាន

ច្រើនលំដាប់ថ្នាក់ និងការស្តាបនាសង្គមជាតិឡើងវិញ ។ កិច្ចខិតខំប្រឹងប្រែងធ្វើឲ្យមានការចងចាំ អាចទទួលស្គាល់ទាំងភាពឈឺចាប់របស់ជនរស់រានមានជីវិតក្នុងរបបខ្មែរក្រហម និងផ្តល់ជាឱកាសបន្ថែមទៀតសម្រាប់ការផ្តួចផ្តើមវិស័យអប់រំ ។ ទាំងគំរូបែបយុត្តិធម៌តាមបែបផ្សះផ្សា និងយុត្តិធម៌តាមការដាក់ទណ្ឌកម្ម គឺពិតជាមានសារសំខាន់ និងត្រូវបានរួមបញ្ចូលគ្នា ពីព្រោះគំរូយុត្តិធម៌ទាំងពីរនេះដើរតួនាទីបំពេញគោលបំណងខុសប្លែកគ្នាដោយស្ថិតនៅក្នុងប្រព័ន្ធយុត្តិធម៌អន្តរកាលដែលផ្តល់ជាទំនួលខុសត្រូវផ្នែកច្បាប់ និងភាពធូរស្បើយផ្លូវអារម្មណ៍ ។

ដោយយោងតាមអត្ថបទស្រាវជ្រាវនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលឧបត្ថម្ភគាំទ្រដោយអង្គការសហប្រជាជាតិ គឺពិតជាមានសមត្ថភាពក្នុងការផ្តល់ជូនយុត្តិធម៌តាមការដាក់ទណ្ឌកម្ម និងទិដ្ឋភាពរបស់យុត្តិធម៌អន្តរកាល ។ យ៉ាងណាមិញ សក្តានុពលភាពមួយនេះ គឺមានភាពទន់ខ្សោយដ៏គួរឲ្យកត់សម្គាល់ ដោយសារតែកង្វះខាតនៃកម្មវិធីសង្គ្រោះ និងការយកចិត្តទុកដាក់ពីក្នុងប្រទេសទាក់ទងនឹងដំណើរការរបស់តុលាការ ហើយចាំបាច់ត្រូវតែជំរុញ និងបង្កើនឲ្យមានកិច្ចខិតខំប្រឹងប្រែងរបស់កម្មវិធីសង្គ្រោះ ការចូលរួមរបស់ជនរងគ្រោះ និងការផ្តួចផ្តើមវិស័យអប់រំដើម្បីពង្រឹងក្រមនីតិវិធីក្នុងប្រទេសកម្ពុជា សម្រាប់ភាពរីកចម្រើនលូតលាស់ និងដើម្បីធានាឲ្យមានការផ្សព្វផ្សាយនៃដំណើរការទៅមុខរបស់តុលាការ និងពីគោលបំណងក្នុងការផ្តល់នូវយុត្តិធម៌ដល់ជនរងគ្រោះរបស់របបខ្មែរក្រហម ។ អង្គជំនុំជម្រះវិសាមញ្ញពិតជាអសមត្ថភាពយ៉ាងធំធេងក្នុងការផ្តល់នូវយុត្តិធម៌ ប៉ុន្តែ អាចមើលឃើញថា មានសារប្រយោជន៍ដល់ការស្តាបនាសង្គមជាតិឡើងវិញទាំងស្រុង ប្រសិនបើកម្មវិធីសង្គមដែលជាប់ពាក់ព័ន្ធត្រូវបានបង្កើតឡើង ដើម្បីជួយដល់ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ក្នុងការឆ្លើយតបនឹងដំណើរការរបស់តុលាការ ។ ជាមួយគ្នានេះផងដែរ ការកាត់ទោសរបស់អង្គជំនុំជម្រះវិសាមញ្ញមានប្រយោជន៍ជាច្រើនសម្រាប់យុត្តិធម៌តាមបែបផ្សះផ្សា ។ ទីមួយ ដំណើរការនីតិវិធីគឺជាការទទួលស្គាល់ដោយរដ្ឋាភិបាលពីឋានៈរបស់ប្រជាជនកម្ពុជាថាជាឯកត្តបុគ្គល និងជាប្រជាពលរដ្ឋដែលជាលទ្ធផលនាំមកនូវជំនឿទុកចិត្តកាន់តែកើនឡើង ។ ទីពីរ ការទទួលស្គាល់នេះ ជួយបង្កើនភាពមានតម្លៃរបស់បុគ្គល ដែលជាលទ្ធផលនឹងជួយគាំទ្រដល់សាមគ្គីភាពក្នុងសង្គម ការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការស្តាបនាសង្គមជាតិឡើងវិញ ។ ក្នុងករណីខ្លះ តុលាការកាត់ទោស អាចធ្វើឲ្យប្រជាពលរដ្ឋព្យាបាលរបួស និងផ្សះផ្សាដែលទំនងជាអាចជួយបានមួយផ្នែកដល់ការផ្សះផ្សាថ្នាក់ជាតិ និងសហគមន៍ ក្នុងយុទ្ធសាស្ត្រដែលសម្រេចដោយមនុស្សមួយចំនួនតូចនេះ ។ យ៉ាងណាមិញ ការផ្សះផ្សាជាលក្ខណៈបុគ្គល និងការព្យាបាលរបួស ត្រូវបានបន្សល់ទុកទៅក្នុងកិច្ចខិតខំប្រឹងប្រែងនៃយុត្តិធម៌បែបផ្សះផ្សា ដូចជាការបង្កើតឡើងនៃបេសកកម្មស៊ើបអង្កេតកម្មវិធីសំណងខូចខាត រួមមានកម្មវិធីសង្គមដែលអាស្រ័យជាចម្បងលើគោលការណ៍ព្រះពុទ្ធ ឬក៏ត្រូវបានរៀបចំឡើង ឬគាំទ្រដោយអ្នកដឹកនាំសាសនាព្រះពុទ្ធ ការផ្តួចផ្តើមគំនិតធ្វើឲ្យមានការចងចាំដើម្បីទទួលស្គាល់ទុក្ខលំបាកវេទនារបស់ជនរងគ្រោះ និងផ្តល់កិត្តិយសដល់អ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម កម្មវិធីអប់រំសម្រាប់ក្មេងជំនាន់ក្រោយដែលមិនបានរស់នៅឆ្លងកាត់របបខ្មែរក្រហម និងសម្រាប់អ្នកដែលធ្លាប់រស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ និងក៏ដូចជាសម្រាប់អ្នកដែលចាំបាច់ស្វែងយល់ថាតើហេតុអ្វីបានជាអំពើសាហាវឃោរឃៅបែបនេះកើតមានឡើង ដើម្បីឲ្យអ្នកទាំងអស់នេះទទួលស្គាល់នូវបទពិសោធន៍ជូរចត់របស់គេ ។ ការធ្វើបែបនេះត្រូវការចម្លើយ ហើយចំណែកឯការផ្សះផ្សាបុគ្គលវិញ ក៏ត្រូវតែដាក់រួមបញ្ចូលទៅក្នុងកម្មវិធីផ្សព្វផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលចាត់ទុកថាជាសារសំខាន់បំផុតមួយ ដើម្បីសម្រេចឲ្យបាននូវយុត្តិធម៌បែបផ្សះផ្សា និងយុត្តិធម៌អន្តរកាល ក៏ដូចជាការផ្សះផ្សា ដែលមានច្រើនលំដាប់ និងការស្តាបនាសង្គមជាតិឡើងវិញក្នុងប្រទេសកម្ពុជាផងដែរ ។ ទាក់ទងជាមួយនឹងការផ្សះផ្សាបីលំដាប់ថ្នាក់ដោយយោងតាមអត្ថបទវិភាគនេះ វាទំនងជាថា គំរូនៃយុត្តិធម៌បែបផ្សះផ្សាផ្តោតលើអារម្មណ៍ផ្លូវចិត្តរបស់បុគ្គល ចំណែកឯយុត្តិធម៌តាមតុលាការវិញ ផ្តោតលើថ្នាក់ជាតិច្រើនជាង ។ យ៉ាងណាមិញ ការផ្សះផ្សាទាំងបីលំដាប់ថ្នាក់នេះពិតជាមានសារសំខាន់ទាំងអស់ក្នុងការនាំយកនូវយុត្តិធម៌ជូនដល់ជនរងគ្រោះរបស់របបខ្មែរក្រហម ។

អត្ថបទនេះយល់ឃើញថា កិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយ ជាពិសេសគឺកិច្ចខិតខំប្រឹងប្រែងដែលផ្តោតការយកចិត្តទុកដាក់ សំខាន់លើការលើកកម្ពស់ និងអភិវឌ្ឍវិស័យអប់រំ និងការចូលរួមរបស់ជនរងគ្រោះ គឺពិតជាមានសារសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចឲ្យបាននូវយុត្តិធម៌អន្តរកាល និងការកសាងសង្គមជាតិឡើងវិញក្នុងប្រទេសកម្ពុជា ។ ប្រសិនបើគ្មានការលើកកម្ពស់ចំណេះដឹង និងការយល់ដឹងពីអ្វីដែលកើតមានឡើងទាក់ទងនឹងការនាំយកនូវយុត្តិធម៌ដល់ប្រទេសកម្ពុជាក្រោយអំពើប្រល័យពូជសាសន៍ទេ នោះយុត្តិធម៌នឹងត្រូវបានយល់ឃើញថាជាអ្វីដែលពិបាកនឹងសម្រេចបាននិងជាអ្វីដែលត្រូវបានពន្យារពេលរហូត ។ ជាមួយគ្នានេះដែរ អត្ថបទនេះក៏យល់ឃើញថា ដើម្បីធ្វើឲ្យគោលបំណងនៃការផ្តល់យុត្តិធម៌អន្តរកាល និងការកសាងសង្គមឡើងវិញសម្រេចបានកិច្ចខិតខំប្រឹងប្រែង និងការផ្តួចផ្តើមគំនិតទាំងអស់នេះ ត្រូវការការឧបត្ថម្ភគាំទ្រយ៉ាងចាំបាច់ពីអង្គការក្រៅរដ្ឋាភិបាល ដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអ្នកសរសេរអត្ថបទនេះយល់ឃើញថាជាការបង្ហាញជាឧទាហរណ៍ដ៏គំរូមួយពីអត្ថប្រយោជន៍ដ៏សំខាន់នៃគំនិតផ្តួចផ្តើមអង្គការក្រៅរដ្ឋាភិបាល សារព័ត៌មាន ជាពិសេសព័ត៌មានកម្សាន្តក្នុងប្រទេស ការផ្សព្វផ្សាយសារព័ត៌មានអន្តរជាតិនិងសង្គមស៊ីវិលដែលឆ្លងកាត់ច្រើនប្រទេស ។

ខណៈពេលដែលការសិក្សាស្រាវជ្រាវផ្សេងទៀតយល់ឃើញថា សក្តានុពលភាពរបស់តុលាការអាចនឹងបន្តបែងចែកសហគមន៍ក្រោយពីសង្គ្រាមដែលមិនទាន់បានផ្សះផ្សានៅឡើយ នោះអត្ថបទវិភាគស្តីពីការព្យាបាលរបួស ការអត់ឱនទោស និងការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់នេះមិនបានស្វែងរកឃើញថា នេះគឺជាកត្តាសម្រាលមួយរបស់ការកសាងសង្គមជាតិឡើងវិញក្នុងប្រទេសកម្ពុជាឡើយ ។ ដូចដែល លោក ឆាំង យុ បានពន្យល់យ៉ាងច្បាស់ពីសារសំខាន់នៃគំរូយុត្តិធម៌តាមតុលាការនិងយុត្តិធម៌តាមការផ្សះផ្សាដើម្បីនាំមកនូវការផ្សះផ្សាដែលមានច្រើនលំដាប់ថ្នាក់ និងការកសាងសង្គមជាតិឡើងវិញក្នុងប្រទេសកម្ពុជានោះ “មានតែការកាត់ទោសតាមផ្លូវច្បាប់និងមានតែការអប់រំទេដែលអាចសម្រេចនូវដំណើរការផ្សះផ្សាទាំងនេះបាន” ។ ប្រទេសកម្ពុជាត្រូវធ្វើដំណើរលើផ្លូវដ៏វែងឆ្ងាយទៅទៀត ហើយខណៈដែលគោលដៅទាំងអស់នេះត្រូវសម្រេចបាន នោះនឹងមានបញ្ហាដែលត្រូវបានបន្សល់ទុកឲ្យដោះស្រាយជាបន្តទៀត (ឧ. វប្បធម៌និទ្ទណ្ឌភាព និងអំពើពុករលួយ) ។ ប៉ុន្តែ អត្ថបទនេះអះអាងថា ការផ្តួចផ្តើមគំនិតគោលការណ៍ដែលបានលើកឡើងខាងលើអាចជួយសម្រេចនូវយុត្តិធម៌អន្តរកាល និងការកសាងសង្គមជាតិឡើងវិញ ប្រសិនបើគោលការណ៍នេះត្រូវបានអនុវត្តត្រឹមត្រូវដោយមានការឧបត្ថម្ភគ្រប់គ្រាន់ ជាពិសេសគឺការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសហគមន៍អន្តរជាតិ ។

**ម៉ារីឌីត ឌីន និង ណាតាហ្សា បាច**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ!**

## ឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមគេហទំព័រ

ដើម្បីឲ្យសាធារណជនទូទៅមានលទ្ធភាពក្នុងការតាមដានមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គេហទំព័រ *www.cambodiatribunal.org* ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាច្បាប់នៃសាកលវិទ្យាល័យណតវេស្ទើន សហរដ្ឋអាមេរិក និងក្រោមសហប្រត្តិបត្តិការជាមួយ *Illinois Holocaust Museum and Educational* Center ។ មុននិងផ្សព្វផ្សាយគេហទំព័រនេះ ត្រូវបានត្រួតពិនិត្យដោយសាស្ត្រាចារ្យច្បាប់ *David Scheffer* អតីតឯកអគ្គរដ្ឋទូតគោចរណ៍របស់សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមកាលពីជំនាន់រដ្ឋការប្រធានាធិបតី ប៊ីល គ្លីនតុន និងលោក ឆាំង យុ នាយក មជ្ឈមណ្ឌលឯកសារកម្ពុជា ។

# ការជួបជុំរបស់អ្នកយកព័ត៌មានក្នុងសម័យសង្គ្រាមនៅកម្ពុជា(១៩៧០-១៩៧៥)

កាលពីអំឡុងសង្គ្រាមនៅវៀតណាមនិងកម្ពុជានាទសវត្សរ៍៧០ អ្នកសារព័ត៌មានជាតិនិងអន្តរជាតិជាច្រើននាក់បានឈានជើងចូលក្នុងសង្គ្រាមនេះដើម្បីយកព័ត៌មានទាក់ទងទៅនឹងសង្គ្រាមដែលមានសហរដ្ឋអាមេរិកពាក់ព័ន្ធផងដែរ ។ សង្គ្រាមនេះបានបង្កឲ្យអ្នកសារព័ត៌មានបាត់បង់ជីវិតជាច្រើននាក់ ។

ខែមេសាជាពេលដែលសង្គ្រាមនៅកម្ពុជានិងវៀតណាមបានបញ្ចប់ក្នុងឆ្នាំ១៩៧៥ ។ អ្នកសារព័ត៌មានដដែលនោះប្រហែលជាតិចតួចប៉ុណ្ណោះដែលមានឱកាសចូលក្នុងប្រទេសទាំងពីរនេះបានក្រោយសង្គ្រាមបញ្ចប់ក្នុងឆ្នាំ១៩៧៥ ។ ៣៥ឆ្នាំក្រោយមកនៅក្នុងខែមេសានេះដដែល អ្នកសារព័ត៌មានទាំងនោះបានចូលនិវត្តន៍ពីការងាររៀងៗខ្លួន ហើយបានជួបជុំគ្នាឡើងវិញទៅប្រទេសកម្ពុជា ។ អ្នកសារព័ត៌មានដែលចូលនិវត្តន៍ប្រមាណជា៤០នាក់បានជួបប្រជុំគ្នាដើម្បីរំឭកដល់សាច់ញាតិនិងសហការីដែលបានស្លាប់ក្នុងពេលកំពុងបំពេញការងារក្នុងសម័យសង្គ្រាមពីឆ្នាំ១៩៧០-១៩៧៥ ។ ជំនួបនេះត្រូវបានរៀបចំឡើងដោយលោក ឆាំង សុង អតីតរដ្ឋមន្ត្រី ក្រសួងព័ត៌មានរបស់របបសាធារណរដ្ឋខ្មែរ និងលោក ខាល រ៉ូប៊ីនសាន់ ដែលជាអតីតអ្នកសារព័ត៌មានរបស់កាសែតអេភី ។

នៅក្នុងជំនួបនេះ អ្នកសារព័ត៌មានទាំងអស់បានទៅចូលរួមពិធីសូត្រមន្តតាមបែបពុទ្ធសាសនានៅវត្តពោធិ៍ ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដែលជាកន្លែងដែលអ្នកសារព័ត៌មានចំនួន៦នាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ដោយខ្មែរក្រហមកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧០ ។ នៅក្នុងពិធីនេះ អតីតអ្នកសារព័ត៌មានរបស់កាសែតវ៉ាស៊ីនតុនប៉ុស្តិ៍ លោកស្រី អេលីហ្សាប៊ែត បេកឃើ បានអានឈ្មោះអ្នកដែលបានស្លាប់ដោយការវាយប្រហាររបស់ខ្មែរក្រហមដោយក្តីខ្សឹកខ្សួល ។ អតីតអ្នកសារព័ត៌មានរបស់កាសែតក្យូដូជប៉ុនលោកស្រី យូកូ អ៊ីហ្សីយ៉ាម៉ា បាននឹកឃើញឡើងនូវប្តីរបស់ខ្លួនដែលជាអតីតអ្នកសារព័ត៌មានរបស់កាសែតក្យូដូដូចគ្នាដែលបានស្លាប់នៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៤ ។ លោកស្រី យូកូ អ៊ីហ្សីយ៉ាម៉ា បានស្រក់ទឹកភ្នែកពេលដែលលោកស្រី អេលីហ្សាប៊ែត បេកឃើ អានឈ្មោះអ្នកដែលបានស្លាប់ក្នុងសម័យសង្គ្រាម ។

ក្រោយមក អ្នកសារព័ត៌មានទាំងអស់បានមកចូលរួមដាំដើមពោធិ៍ដែលជានិមិត្តរូបនៅទីតាំងដែលអ្នកសារព័ត៌មានត្រូវបានសម្លាប់ ។ ចប់កម្មវិធីនេះ អ្នកសារព័ត៌បានទៅទស្សនាព្រះបរមរាជវាំង សារមន្ទីរជាតិ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតជើងឯក ។



អ្នកសារព័ត៌មានក្នុងសម័យសង្គ្រាមនៅកម្ពុជាឆ្នាំ១៩៧០ -

ខាងក្រោមនេះគឺជាអ្នកសារព័ត៌មានមួយចំនួនដែលបាន មកចូលរួមក្នុងជំនួបនេះ ៖

◆ ឆាំង សុងៈ ជាអ្នករៀបចំជំនួបនេះ ។ នៅពេលសង្គ្រាម ចាប់ផ្ដើមក្នុងឆ្នាំ ១៩៧០ លោក ឆាំង សុង គឺជាអនុសេនីយឯក កងទ័ពមួយរូបដែលធ្វើការជាមួយនឹងអ្នកនាំពាក្យលោក អាំ រ៉ុង ។ នៅក្នុងឆ្នាំ១៩៧៤ ឆាំង សុង ត្រូវបានតែងតាំងជារដ្ឋមន្ត្រី ក្រសួងព័ត៌មាននៅក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរដែលបាន បរាជ័យ នៅក្នុងការដឹកនាំរបស់ខ្លួននៅក្នុងឆ្នាំ១៩៧៥ ។

◆ ខាល រ៉ូប៊ីនសាន់ សហអ្នករៀបចំជំនួបជាមួយលោក ឆាំង សុង។ លោក រ៉ូប៊ីនសាន់ បានធ្វើការជាមួយសមាគមអ្នក កាសែតនៅទីក្រុងសៃហ្គន វៀតណាមខាងត្បូងក្នុងនាមជាអ្នក ថតរូប និងក្រោយមកក្លាយទៅជាអ្នកសារព័ត៌មានពេញម៉ោង នៅរវាងឆ្នាំ១៩៦៨ និង ឆ្នាំ១៩៧៥ ហើយជារឿយៗគាត់តាម ដានសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ។ ក្រោយសង្គ្រាមបានបញ្ចប់ លោកបានប្ដូរទៅនៅប្រទេសអូស្ត្រាលី ។


-១៩៧៥ នៅព្រះបរមរាជវាំង-

◆ លោក ដេម ព្រីងហ្គល និងលោកស្រី មីលី ព្រីងហ្គល ជាអ្នកឆ្លើយឆ្លងសារព័ត៌មានវ៉យទើ ។ ក្រោយមក គាត់ទាំងពីរ ធ្វើនៅ Newsweek និង The time នៅទីក្រុងឡុនដុន ដែលជាអ្នក តាមដានសង្គ្រាមវៀតណាម និងកម្ពុជា ក្នុងអំឡុងពេលសង្គ្រាម រហូតដល់បច្ចុប្បន្ន ។ សព្វថ្ងៃនេះ គាត់ទាំងពីររស់នៅទីក្រុង ភ្នំពេញ ។

◆ លោក ភីតធើ សារ៉ក់ គឺជាអតីតអ្នកសារព័ត៌មាន វ៉យទើ ហើយបច្ចុប្បន្នជាបុរាណវត្ថុវិទូ នៅសាកលវិទ្យាល័យ ឡុនដុនដែលសិក្សាពីប្រទេសអាស៊ីនិងអាហ្វ្រិក និងជាអ្នកជំនាញ លើវត្ថុបុរាណខ្មែរ ។

◆ លោក ដេហ្វ វីល្យាម ជាគតីតអ្នកយកព័ត៌មានអេភី ហើយក្រោយមកធ្វើការនៅសារព័ត៌មាន CBS ។ លោក វីល្យាម បានចូលមកក្នុងប្រទេសកម្ពុជាបីថ្ងៃមុនរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្នុងនាមជាសាស្ត្រាចារ្យ ពីព្រោះអ្នកកាសែតជនជាតិ អាមេរិកត្រូវបានហាមឃាត់ ។

◆ យើត វ៉ុលគើត ជាអតីតអ្នកយកព័ត៌មានឲ្យ CBS ។ គាត់បានមកដល់ទីក្រុងភ្នំពេញនៅពាក់កណ្ដាលខែឧសភា ឆ្នាំ ១៩៧០ ជាមួយនឹងក្រុមការងារ CSB មកពីទីក្រុងតូក្យូ ។

◆ អេលីហ្សាប៊ែត បេកឃើ ជាអ្នកតាមដានសង្គ្រាមកម្ពុជា ឲ្យសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ Newsweek និង NBC ។ គាត់គឺ ជាអ្នកនិពន្ធសៀវភៅដែលមានចំណងជើងថា «ពេលសង្គ្រាមរលត់ ទៅ» និង «ប្រវត្តិសាស្ត្រកម្ពុជាទំនើបនិងខ្មែរក្រហម» ។ សៀវភៅថ្មី មួយទៀតរបស់គាត់ ដែលមានចំណងជើងថា «បូផាណា» ដែលជា ប្រវត្តិស្នេហាមួយក្នុងអំឡុងរបបខ្មែរក្រហមនិងត្រូវចេញផ្សាយ នៅក្នុងប្រទេសកម្ពុជា ជាភាសាខ្មែរ បារាំង និងអង់គ្លេស ក្នុង អំឡុងពេលជួបជុំគ្នានេះ ។ ថ្មីៗនេះគាត់បានចូលនិវត្តន៍ពីសារព័ត៌ មានញូយ៉កថែម ។

◆ ដុន គើក បានមកធ្វើទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជា លើកដំបូងនៅឆ្នាំ១៩៦៦ ។ ក្រោយមកគាត់បានតាមដាននូវ ព្រឹត្តិការណ៍ទម្លាក់សម្ដេច សីហនុ និងការឈ្លានពានរបស់អាមេរិក ។

ក្នុងអំឡុងពេលកំពុងធ្វើការឲ្យសារព័ត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ស្តារនៅក្នុងខែមេសា ឆ្នាំ១៩៧០ គាត់និងសហការីរបស់គាត់ឈ្មោះ ប៊ីល ខាន់នីងហេម ដែលជាសមាជិកនៃគណៈកម្មាធិការផ្សព្វផ្សាយការណាដា ស្ទើរតែត្រូវបានចាប់ខ្លួនដោយខ្មែរក្រហមនៅក្បែរស្រុកគិរីវង្ស ភាគខាងត្បូងទីក្រុងភ្នំពេញ ប៉ុន្តែត្រូវបានដោះឲ្យរួច ។ ក្រោយមក ដុន គើក បានសរសេរអត្ថបទឲ្យសារព័ត៌មាន ញូយ៉កថែម និង ឈីកាហ្គោត្រាយប្យូន ដោយបង្ហាញពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហម ។ លោក ដុន គើក គាត់បានវិលត្រឡប់មកប្រទេសកម្ពុជាជាលើកដំបូងនៅក្នុងឆ្នាំ១៩៨៥ ក្នុងនាមជាអ្នកកាសែតឲ្យព័ត៌មាន *USA Today* និងចុងក្រោយនៅក្នុងឆ្នាំ ២០០២ សម្រាប់សារព័ត៌មាន *International Herald Tribune* ។

◆ អាល់ រ៉ក់ខហ្វ ជាអ្នកថតរូបឯករាជ្យ ដែលតាមដានសង្គ្រាមក្នុងប្រទេសកម្ពុជាសម្រាប់សារព័ត៌មាន អេភី និងភ្នាក់ងារដទៃទៀត ។ គាត់បានបង្ហាញអំពីការដួលរលំនៃទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ និងនៅស្ថានទូតបារាំង ។ អាល់ រ៉ក់ខហ្វ មានវត្តមានក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥


អាល់ រ៉ក់ខហ្វ


ខាល រ៉ូប៊ីនសាន់


ដេវីដ ប្រេដប៊ឺរី


មីលី ព្រីនហ្គល


ស៊ីលវ៉ាណា ហ្វូអា


តាក់ស៊ូ កានិកុ

ក្រោយមក គាត់តែងតែមកលេងប្រទេសកម្ពុជារៀងរាល់ឆ្នាំ ។

◆ ដេន សៅឌើលេន គឺជាអ្នកឆ្លងឆ្លើយសារព័ត៌មានចុងក្រោយ ដែលបានជួបជាមួយ *Sean Flynn* និង *Dana Stone* នៅមុនពេលការបាត់ខ្លួននៅភាគខាងកើតឃុំជីភូ ក្នុងខែមេសា ឆ្នាំ ១៩៧០ ។ ឥឡូវនេះគាត់ធ្វើការឲ្យវិទ្យុសំឡេងសហរដ្ឋអាមេរិក ។

◆ ស៊ីលវ៉ាណា ហ្វូអា ជាអ្នកតាមដានពីសង្គ្រាមកម្ពុជាឲ្យសារព័ត៌មាន *Newsweek* និង *United Press International (UPI)* នៅទីក្រុងហុងកុង និងបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹង សម្តេចនរោត្តម សីហនុ នៅទីក្រុងប៉េកាំង ក្នុងខែតុលា ។ នៅក្នុងឆ្នាំ១៩៧៣ អ្នករាយការណ៍ម្នាក់ក្នុងចំណោមអ្នករាយការណ៍ជនជាតិអាមេរិកាំងជាច្រើននាក់ត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងប្រទេសចិន ក្នុងអំឡុងពេលបដិវត្តន៍វប្បធម៌ ។ គាត់គឺជាស្ត្រីដំបូងបំផុតដែលបានធ្វើជាអ្នកត្រួតពិនិត្យការបរទេសនៃអង្គភាពសារព័ត៌មានអន្តរជាតិសំខាន់មួយនិងជានាយកសារព័ត៌មានស្រីដំបូងបំផុតនៃប្រព័ន្ធទូរទស្សន៍របស់សហរដ្ឋអាមេរិក និងជាស្ត្រីដំបូងបំផុតដែលធ្វើការជាអ្នកនាំពាក្យឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ គាត់


អេលីហ្សាប៊ែត បេកឃើ


ដែម ព្រីងហ្គល


ប៊ូន ស្មេន


ជីម ផេច


យុកុ អ៊ីស៊ីយ៉ាម៉ា


ឃើត វ៉ុលគើត

ទទួលពានរង្វាន់ Pulitzer ចំនួនពីរដង ។

◆ ចូន ស្វេន គឺជាអតីតអ្នកយកព័ត៌មាន AFP ដែលតាមដានប្រទេសវៀតណាម និងកម្ពុជា ហើយក្រោយមក គាត់បានធ្វើការជាមួយកាសែត Times of London ។ គាត់បានស្នាក់នៅទីនោះរហូត បន្ទាប់ពីខ្មែរក្រហមដណ្តើមបានស្ថានទូតបារាំង ។ គាត់ក៏ជាអ្នកនិពន្ធសៀវភៅមួយដែលមានចំណងជើងថា River of Time ។

◆ ធើរី និង ស៊ូសាន វ៉ុលគើស្តហ្វើ ជាអតីតអ្នកយកព័ត៌មានអេភី ដែលមានទីស្នាក់ការនៅក្នុងទីក្រុងសៃហ្គុន ។

◆ គ្រេន ម៉េកដូណល ជាអតីតអ្នកយកព័ត៌មានវិទ្យុ ABC ដែលតាមដានសង្គ្រាមនៅកម្ពុជា (នៅរវាងឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ អាមេរិក) ។

◆ ស៊ីវ ណគថាប់ ជាអតីតអ្នកថតរូបឲ្យសារព័ត៌មាន UPI ហើយក្រោយមកក្លាយជាអ្នកថតរូបឲ្យកាសែតថាម ។

◆ ធីម ភេច ជាអតីតអ្នកថតរូបឲ្យ Time-Life ។ គាត់បានរងរបួសយ៉ាងធ្ងន់ធ្ងរនៅក្នុងឆ្នាំ១៩៦៩ និងត្រូវបានបញ្ជូនទៅកាន់សហរដ្ឋអាមេរិក ។ គាត់មិនធ្លាប់រាយការណ៍អំពីសង្គ្រាមនៅកម្ពុជានោះទេ ប៉ុន្តែគាត់នៅទីនោះជាមួយនឹងអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ១៩៨៩ គឺជាឆ្នាំដែលគាត់បានលះបង់នូវអ្វីៗទាំងអស់ដើម្បីស្វែងរកដំណឹងបាត់ខ្លួនមិត្តភក្តិដ៏ល្អរបស់គាត់នៅសម័យសង្គ្រាម ។

◆ ដេវីឌ ធើរី ជាអ្នកថតរូបឯករាជ្យដែលរាយការណ៍អំពីសង្គ្រាមកម្ពុជា និងវៀតណាម ។

◆ អាត់ស៊ូ កាណេកុ គឺជាប្រធានការិយាល័យសៃហ្គុនសម្រាប់ទីភ្នាក់ងារសារព័ត៌មានក្យូដូ នៅអំឡុងសង្គ្រាមនៅវៀតណាម ។

◆ យូកុ អ៊ីស៊ីយ៉ាម៉ា ជាប្រពន្ធរបស់ កូគី អ៊ីស៊ីយ៉ាម៉ា អ្នកយកព័ត៌មានក្យូដូ ត្រូវបានចាប់ខ្លួននិងសម្លាប់ដោយខ្មែរក្រហមនៅដើមឆ្នាំ១៩៧៤ ។

**ញាណ សុជាតិ**



# អ្នកសារព័ត៌មានដែលស្លាប់ក្នុងសម័យសង្គ្រាមនៅកម្ពុជា (១៩៧០-១៩៧៥)

*ចងក្រងដោយលោក រីឆាដ ភីល អ្នកយកព័ត៌មានកាសែត អេភី និងត្រួតពិនិត្យបន្ថែមដោយលោក ខាល រ៉ូប៊ីនសាន់ ។*

មានអ្នកកាសែត អ្នកថតរូប អ្នកថតវីដេអូជាតិនិងអន្តរជាតិ សរុបទាំងអស់៣៧នាក់ត្រូវបានសម្លាប់និងបាត់ខ្លួនអំឡុងពេល កំពុងបំពេញការងារនៅក្នុងប្រទេសកម្ពុជាចន្លោះខែមេសាឆ្នាំ ១៩៧០ ដល់ខែមេសា ឆ្នាំ១៩៧៥ ។

ចំនួនអ្នកកាសែតស្លាប់ច្រើនបំផុតគឺមកពីប្រទេសជប៉ុន (១០នាក់), បារាំង (៨នាក់), អាមេរិក (៧នាក់) ។ អ្នកកាសែតកម្ពុជា៥នាក់បានបាត់ខ្លួននៅក្នុងពេលសង្គ្រាម ។ អ្នកកាសែតដទៀត មានជនជាតិស្វីស២នាក់, អាឡឺម៉ង់ខាងលិចម្នាក់, អូទ្រីសម្នាក់, ហូឡង់ម្នាក់, ឥណ្ឌាម្នាក់, ឡាវម្នាក់ និងអូស្ត្រាលីម្នាក់ ។

## ឆ្នាំ១៩៧០

◆ ហ្គីល ការ៉ុន ជាជនជាតិបារាំង ។ អ្នកថតរូបឲ្យសារព័ត៌មាន ហ្គាម៉ា បាត់ខ្លួនក្នុងអំឡុងពេលប្រតិបត្តិការ នៅផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៤ ខែមេសា ។

◆ ក្លូដ អារពីន ជនជាតិបារាំង អ្នកថតរូបឲ្យសារព័ត៌មាន ញូវវីក ចាប់ខ្លួនដោយកងទ័ពវៀតកុង នៅផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៥ ខែមេសា ។

◆ ហ្គុយ ហាន់ណូតូ ជនជាតិស្វីស ធ្វើការឲ្យកាសែតឡិចប្រេស របស់ស្វីស ចាប់ខ្លួនដោយកងទ័ពវៀតកុង ផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៥ ខែមេសា ។

◆ អាគីរ៉ា គីសាកា ជនជាតិជប៉ុន អ្នកយកព័ត៌មានឲ្យទូរទស្សន៍ហ្វូជិ បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៦ ខែមេសា ។

◆ យឺជីរូ តាកាហ្គិ ជនជាតិជប៉ុន អ្នកយកព័ត៌មានឲ្យទូរទស្សន៍ហ្វូជី បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៦ ខែមេសា ។

◆ សៀន ភ្លីន ជនជាតិអាមេរិក ធ្វើការឲ្យកាសែតអែហ្វអិល និងថែម បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ ផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៦ ខែមេសា ។

◆ដាណា ស្តូន ជនជាតិអាមេរិក ធ្វើការឲ្យកាសែត ស៊ីប៊ីអេស បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ ផ្លូវជាតិលេខ១ នៅជីភូ ថ្ងៃទី៦ ខែមេសា ។ សៀន ភ្លីន និង ដាណា ស្តូន ត្រូវបានជឿថាត្រូវសម្លាប់ដោយខ្មែរក្រហមក្រោយពេលចាប់ខ្លួន ។

◆ ដែតទឺ បេឡែនដូស ជនជាតិអាល្លឺម៉ង់ (ខាងលិច) ជាអ្នកថតរូបឲ្យសារព័ត៌មាន អិនប៊ីស៊ី ចាប់ខ្លួនដោយកងទ័ពខ្មែរក្រហម នៅខេត្តស្វាយរៀង ថ្ងៃទី៨ ខែមេសា ។

◆ ចច ហ្វែនស្វាក់ន័រ ជនជាតិអូទ្រីស ធ្វើការឲ្យកាសែត អែហ្វអិល ចាប់ខ្លួននៅខេត្តស្វាយរៀង ថ្ងៃទី៨ ខែមេសា ។

◆វីលី មែតល័រ ជនជាតិស្វីស ធ្វើការឲ្យកាសែត អែហ្វអិល បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ នៅខេត្តកំពត ថ្ងៃទី៦ ខែមេសា ។

◆ តាក់កិស៊ី យ៉ាណាហ្គិសាវ៉ា ជនជាតិជប៉ុន អ្នកឆ្លើយឆ្លងព័ត៌មានឲ្យសារព័ត៌មាន និហុន ដែនប៉ា បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ នៅខេត្តកំពត ថ្ងៃទី១០ ខែឧសភា ។

◆តិរូ ណាកាជិម៉ា ជនជាតិជប៉ុន ធ្វើការនៅវិទ្យុស្ថាន អូម៉ូរិ បាត់ខ្លួននៅក្នុងអំឡុងប្រតិបត្តិការ (មិនដឹងទីតាំង) នៅប្រទេសកម្ពុជា ថ្ងៃទី២៩ ខែឧសភា ។

◆ តូម៉ូហារុ លីស៊ី ជនជាតិជប៉ុន អ្នកថតភាពយន្តឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងទ័ពខ្មែរក្រហមនិងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆គូជិរ៉ូ សាកៃ ជនជាតិជប៉ុន អ្នកថតសម្លេងឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងខ្មែរក្រហម និងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆រំនិក លិកខី ជនជាតិឥណ្ឌា អ្នកថតភាពយន្តឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងទ័ពខ្មែរក្រហមនិងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆ ជីរ៉ល មីល័រ ជនជាតិអាមេរិក អ្នកផលិតភាពយន្តឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងទ័ពខ្មែរក្រហមនិងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆ចច ស៊ីរីតសែន ជនជាតិអាមេរិក អ្នកឆ្លើយឆ្លងព័ត៌មាន

ឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងទ័ពខ្មែរក្រហមនិងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆ យ៉េង សំឡេង ជនជាតិកម្ពុជា អ្នកបើកបរថយន្តឲ្យសារព័ត៌មាន ស៊ីប៊ីអេស កងទ័ពខ្មែរក្រហម និងវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។ យ៉េង សំឡេង គឺជាមនុស្សតែម្នាក់គត់នៅក្នុងបញ្ជីនេះដែលមិនមែនជាអ្នកសារព័ត៌មាន ។

◆ វែល ហានដែន ជនជាតិអាមេរិក អ្នកឆ្លើយឆ្លងព័ត៌មានឲ្យសារព័ត៌មាន អិនប៊ីស៊ី កងទ័ពវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆ រ៉ូជឺ កូល ជនជាតិបារាំង អ្នកថតភាពយន្តឲ្យសារព័ត៌មាន អិនប៊ីស៊ី កងទ័ពវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ប្រទេសកម្ពុជា ថ្ងៃទី៣១ ខែឧសភា ។

◆ យូស៊ីហិកុ វ៉ាគុ ជនជាតិជប៉ុន អ្នកថតសម្លេងឲ្យសារព័ត៌មាន អិនប៊ីស៊ី កងទ័ពវៀតកុង ស្ទាក់ចាប់ខ្លួននៅវត្តពោធិ៍ ផ្លូវជាតិលេខ៣ ថ្ងៃទី៣១ ខែឧសភា ។

◆ វ៉ាយមុន មេយ័រ ជនជាតិបារាំង ធ្វើការឲ្យកាសែតអូអាធីអែហ្វ បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ នៅខេត្តសៀមរាប ថ្ងៃទី៧ ខែកក្កដា ។

◆ រេន ពីសេសសូ ជនជាតិបារាំង ធ្វើការឲ្យកាសែតអូអាធីអែហ្វ បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ នៅខេត្តសៀមរាប ថ្ងៃទី៧ ខែកក្កដា ។

◆ ដេ ហ្វ្រាំង ហ្វ្រូស ជនជាតិអាមេរិក អ្នកឆ្លើយឆ្លងព័ត៌មានឲ្យសារព័ត៌មាន យូភីអាយ ត្រូវបានសម្លាប់ក្នុងខេត្តតាកែវ ថ្ងៃទី២៨ ខែតុលា ។

◆ គីយូអិឈិ សាវ៉ាដា ជនជាតិជប៉ុន អ្នកថតរូបឲ្យសារព័ត៌មាន យូភីអាយ ត្រូវបានសម្លាប់នៅតាមបណ្តោយផ្លូវជាតិលេខ២ ក្នុងខេត្តតាកែវ ថ្ងៃទី២៨ ខែតុលា ។

◆ ដូហាន់ ឌុយនីស្វែល ជនជាតិហូឡង់ ធ្វើការឲ្យកាសែតអែហ្វអិល អេអារីអិន ត្រូវបានសម្លាប់ នៅចំណុចជិតពុះសេក ថ្ងៃទី២៦ ខែធ្នូ ។

## ឆ្នាំ១៩៧១

◆ ហ្វ្រង់ស៊ីស បៃលី ជនជាតិបារាំង ធ្វើការឲ្យកាសែតអែហ្វអិល ត្រូវបានសម្លាប់តាមបណ្តោយផ្លូវជាតិលេខ៤ ថ្ងៃទី១៩ ខែកុម្ភៈ ។

## ឆ្នាំ១៩៧២

◆ អាឡាំង ហ៊ីរុន ជនជាតិអូស្ត្រាលី ធ្វើការឲ្យកាសែតអែហ្វអិល ចាប់ខ្លួនដោយកងទ័ពខ្មែរក្រហម នៅអ្នកលឿង ថ្ងៃទី២៥ ខែមេសា ។

◆ តែរី អិល រេណុល ជនជាតិអាមេរិក ធ្វើការឲ្យកាសែតអែហ្វអិល និងយូភីអាយ ចាប់ខ្លួនដោយកងទ័ពខ្មែរក្រហមនៅអ្នកលឿង ថ្ងៃទី២៥ ខែមេសា ។

◆ ជឹម សាវ៉ាត់ ជនជាតិកម្ពុជា ធ្វើការឲ្យកាសែត អែហ្វអិល ចាប់ខ្លួនដោយកងទ័ពខ្មែរក្រហមនៅអ្នកលឿង ថ្ងៃទី២៥ ខែមេសា ។

## ឆ្នាំ១៩៧៣

◆ ហាស់ ប្រាក់ ជនជាតិកម្ពុជា ធ្វើការឲ្យកាសែត ហាស់សន្តិភាពបាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការនៅប្រទេសកម្ពុជា ។

◆ តៃហ្សូ អិឈិនូសេ ជនជាតិជប៉ុន ធ្វើការឲ្យកាសែតអែហ្វអិល បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការនៅអង្គរវត្ត ថ្ងៃទី២៣ ខែវិច្ឆិកា ។

◆ លឹម សាវឿន ជនជាតិកម្ពុជា ធ្វើការឲ្យកាសែតនគរធំ បាត់ខ្លួនក្នុងអំឡុងប្រតិបត្តិការ (មិនដឹងថ្ងៃខែ) ។

## ឆ្នាំ១៩៧៤

◆ កូគី អ៊ីស៊ីយ៉ាម៉ា ជនជាតិជប៉ុន ធ្វើការឲ្យកាសែត ក្យូដូ ចាប់ខ្លួនដោយកងទ័ពខ្មែរក្រហម នៅខែតុលា ប្រហែលស្លាប់ថ្ងៃទី២០ ខែមករា ។

◆ ម៉ាក ហ៊ីឡូ ជនជាតិបារាំង ធ្វើការឲ្យកាសែត អាអែហ្វប៉េ និងឡាវ ប្រចាំនៅប្រទេសត្រូវបានសម្លាប់ដោយកងទ័ពខ្មែរក្រហម ថ្ងៃទី១៥ ខែមេសា ។

◆ ម៉ានីវ៉ាន់ ជនជាតិឡាវ អ្នកបកប្រែឲ្យកាសែត អាអែហ្វប៉េ ត្រូវបានសម្លាប់ដោយកងទ័ពខ្មែរក្រហម ថ្ងៃទី១៥ ខែមេសា ។ ម៉ានីវ៉ាន់ គឺជាអ្នកបកប្រែរបស់លោក ម៉ាក ហ៊ីឡូ ។ អ្នកទាំងពីរបានចាកចេញពីទីក្រុងវៀងចាន់ ហើយឆ្លងចូលព្រំដែនកម្ពុជាដើម្បីសុំកម្មាភិបាលខ្មែរក្រហមសម្ភាសន៍ ។ ចាប់តាំងពីពេលនោះមកអ្នកទាំងពីរបាត់ខ្លួនរហូត ។ ភស្តុតាងដែលអាចរកបានបានបញ្ជាក់ថាអ្នកទាំងពីរត្រូវចាប់ចាប់ខ្លួននិងសម្លាប់ដោយខ្មែរក្រហម តែសាក

សពមិនត្រូវបានរកឃើញទេ ។ ប្រធានសារព័ត៌មាន អាអែហ្វប៉េ ប្រចាំនៅឡាវឈ្មោះ ជីន ហ្សាក់ខាហ្វូ បាននិយាយថា លោក ហ៊ីឡូ គឺជាបុគ្គលិកនៅដែលត្រូវបានដួលនៅក្នុងស្រុកដើម្បីបញ្ជូនព័ត៌មាន ទៅកាន់ទីក្រុងប៉ារីស ។ ម៉ានីវ៉ាន់ គឺជាអ្នកបកប្រែឯករាជ្យ ហើយ គឺជាជនជាតិឡាវតែម្នាក់គត់នៅក្នុងបញ្ជីនេះ ។

◆ លឹម សាវ៉ាត ជនជាតិកម្ពុជា ធ្វើការឲ្យកាសែត អែហ្វអិល និងអេភី ស្លាប់ពេលប្រតិបត្តិការ នៅខេត្តកំពង់ឆ្នាំង ថ្ងៃទី១ តុលា ។

## ឆ្នាំ១៩៧៥

◆ លី អេ ជនជាតិកម្ពុជា ធ្វើការឲ្យកាសែតដំណឹងពេលព្រឹក ត្រូវបានសម្លាប់ដោយកងទ័ពខ្មែរក្រហម នៅភ្នំពេញ ។ ក្រោយ ពេលខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា លី អេង បានលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញអស់រយៈពេលពីរបីសប្តាហ៍ ។ ក្រោយមកគាត់បានលបចេញមកក្រៅពីកន្លែងលាក់ខ្លួន ។ ភ្លាម នោះគាត់បានឃើញឡានបើកដំបូលរបស់គាត់ ហើយបានបើក យ៉ាងលឿនចេញពីផ្លូវមុនីវង្សឆ្ពោះទៅស្ពានមុនីវង្ស ហើយបើក កាត់រនាំងរបស់ខ្មែរក្រហមជាច្រើន ។ ពេលគាត់មកដល់ស្ពាន ខ្មែរក្រហមបានបាញ់រះមកលើគាត់ហើយគាត់ក៏បើករថយន្ត ទម្លាក់ទឹក ។

## ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ៈ គុកឥតជញ្ជាំង

បន្ទាប់ពីឆ្នាំ១៩៧៥ ចំនួនតួរលេខពិតប្រាកដនៃជនជាតិ កម្ពុជាដែលបានសម្លាប់ និងបាត់ខ្លួននៅក្នុងអំឡុងពេលប្រតិបត្តិការ នៅមានភាពមិនច្បាស់លាស់ ដោយសារខ្វះខាតព័ត៌មាន និងបាត់ ដំណឹងរបស់ជនរងគ្រោះទាំងនោះ ។ បញ្ជីខាងក្រោមនៅមិនទាន់ ច្បាស់លាស់ទេ ទើបតម្រូវឲ្យមានព័ត៌មានបន្ថែមទៀតទាក់ទងនឹង ព្រឹត្តិការណ៍នៃការស្លាប់ ។ ប្រជាជនកម្ពុជាជាច្រើនបានឈរនៅ ខ្សែត្រៀមជួរមុខនៃការវាយប្រយុទ្ធ នៅពេលដែលពួកគេធ្វើ ការងារជាអ្នកសរសេរអត្ថបទឲ្យកាសែតបរទេស ក៏ដូចជាកាសែត ក្នុងស្រុក ហើយបានក្លាយជាគោលដៅសំខាន់របស់ខ្មែរក្រហម ។ ខណៈពេលដែលពួកគេបាត់ខ្លួន បន្ទាប់ពីសង្គ្រាមបានបញ្ចប់នៅថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមទទួលជ័យ ជម្នះ ពួកគេត្រូវបានបំបែកចេញជាក្រុមដាច់ដោយឡែកនៅទីនេះ ។

◆ ឈរ វុទ្ធី កាសែត អេភី

◆ ហុង ហូ កាសែត យូភីអាយ

◆ ស៊ិន ហៀង អ្នកសរសេរអត្ថបទ និងធ្វើការឲ្យកាសែតអេភី

◆ ទៀ គីម ហៀង អ្នកថតរូបឲ្យកាសែត អេភី

◆ មៀន លៀង ធ្វើការឲ្យកាសែត អេភី

◆ ពុត សូផាន ធ្វើការឲ្យសារព័ត៌មាន ស៊ីប៊ីអេស

◆ សូ វិចិត្រ អ្នកថតរូបឲ្យកាសែត ហ្គាម៉ា

◆ សុក ធួន ធ្វើការឲ្យសារព័ត៌មាន រ៉យទ័រ

◆ អ៊ិត ឈុន អ្នកសរសេរអត្ថបទឲ្យកាសែត យូភីអាយ

◆ ជា ហូ ធ្វើការឲ្យកាសែត យូភីអាយ

◆ ឡាញ់ ដួញ វ៉ា ធ្វើការឲ្យកាសែត អេភី

◆ លេក

◆ ឡេង

◆ លឹង ញាណ ធ្វើការឲ្យការសែត អេភី

◆ ទី ម៉ានី

◆ ហេង ហុក ធ្វើការឲ្យការសែត យូភីអាយ

◆ វ៉ាន់ថា ធ្វើការឲ្យការសែត អេភី

◆ អ៊ុង គីម សេង ហៅ ចៀវ ស្លាប់នៅស-២១

◆ សាំង ហែល និពន្ធនាយកសារព័ត៌មានអរិយធម៌ ស្លាប់ នៅមន្ទីរស-២១

◆ យ៉ុន ហួរ ធ្វើការឲ្យសារព័ត៌មាននីហុន ដែនប៉ា ស្លាប់នៅ ស-២១

◆ កែវ យ៉ុន អ្នកថតភាពយន្តឲ្យស្ថានីយ៍ទូរទស្សន៍ ស្លាប់នៅ ស-២១

◆ សឿង គៀក និពន្ធនាយកសារព័ត៌មានមាតុភូមិ ឬនិពន្ធនាយកកាសែត ស្លាប់នៅស-២១

◆ អ៊ូ ង៉ែត អ្នកថតរូបឲ្យក្រសួងព័ត៌មាន ស្លាប់នៅស-២១

◆ ហាក់ ខេង អ្នកថតខ្សែភាពយន្ត ស្លាប់នៅស-២១

◆ បួយ ស្រេងនិពន្ធនាយកកាសែតសង្គ្រោះ ស្លាប់នៅ ស-២១

◆ សួន ឆេង ស្លាប់នៅស-២១

◆ ជ័យ ជុំ ស្លាប់នៅស-២១

◆ អ៊ី អិត ស្លាប់នៅស-២១

◆ ម៉ែន ម៉ានិល ស្លាប់នៅស-២១

◆ លី ខួន ស្លាប់នៅស-២១

# ការជួបសំណេះសំណាលរវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកភូមិ

ភូមិព្រែកទាល់ជាភូមិមួយស្ថិតនៅក្នុងឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ។ មុនរបបកម្ពុជាប្រជាធិបតេយ្យ ភូមិនេះមានបងប្អូនខ្មែរអ៊ីស្លាមរស់នៅចំនួន៧០គ្រួសារ ។ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ភូមិនេះទាំងស្រុង ជនជាតិអ៊ីស្លាមទាំងអស់ត្រូវបានជម្លៀសចេញពីភូមិនេះទៅរស់នៅស្រុកទូកមាសខេត្តកំពត ។ ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ មានខ្មែរអ៊ីស្លាមចំនួន១៧គ្រួសារប៉ុណ្ណោះ ដែលបានវិលត្រឡប់មករស់នៅក្នុងភូមិនេះវិញ ។

ភូមិនេះមានចម្ងាយ៦០គីឡូម៉ែត្រពីទីរួមខេត្តព្រះសីហនុ ហើយស្ថិតនៅតំបន់ដាច់ស្រយាលដែលប្រជាជនមួយចំនួនធំមិនបានដឹងពត៌មានអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។ ហេតុដូច្នេះហើយ នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១០ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឈ្មោះ អែនឌ្រូ ខាលេ ចុះទៅជួបបងប្អូនខ្មែរ-អ៊ីស្លាម នៅភូមិព្រែកទាល់ដែលមានចំនួនជិត២០០នាក់ចូលរួម ។ នៅក្នុងជំនួបនេះដែរ លោកសហព្រះរាជអាជ្ញាបានរៀបរាប់ប្រាប់អ្នកភូមិអំពីដំណើរការវិវឌ្ឍរបស់តុលាការការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីឲ្យអ្នកភូមិបានយល់ដឹងកាន់តែច្បាស់អំពីដំណើរការរបស់តុលាការនេះ ។

បន្ទាប់ពីបានស្តាប់ការពន្យល់របស់លោកសហព្រះរាជអាជ្ញារួចមក បងប្អូនខ្មែរ-អ៊ីស្លាមទាំងអស់បានសម្តែងការគាំទ្រចំពោះដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះទាំងស្រុង ព្រមទាំងមិនទាមទារសំណងអ្វីពីតុលាការនេះទេដោយគ្រាន់តែចង់ឲ្យសហគមន៍អន្តរជាតិដឹងពត៌មានពីទុក្ខវេទនារបស់ប្រជាជនខ្មែរដែលធ្លាប់បានឆ្លងនៅក្នុងរបបខ្មែរក្រហមតែប៉ុណ្ណោះ ។ ក្នុងនោះមាន ម៉ុទូន (គ្រូបង្រៀនស្រី) ម្នាក់បាននិយាយទាំងទឹកមុខក្រៀមក្រំប្រាប់សហព្រះរាជអាជ្ញាថា មុនរបបខ្មែរក្រហមចូលមកកាន់កាប់ក្នុងភូមិនេះ គ្រួសាររបស់គាត់មានសមាជិក៦នាក់រស់នៅដោយជីវភាពសមរម្យ ។ ពេលដែលខ្មែរក្រហមចូលមកកាន់កាប់ក្នុងភូមិ ក្រុមគ្រួសាររបស់គាត់ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅស្រុកទូកមាស ខេត្តកំពត ហើយបង្ខំឲ្យគាត់ធ្វើការជាទម្ងន់ និងហូបចុកមិនគ្រប់គ្រាន់ ។ លើសពីនេះទៅទៀត ខ្មែរក្រហមបានយកគ្រួសាររបស់គាត់ទាំង៥នាក់ទៅសម្លាប់ ។ ដូច្នេះហើយ ទោះបីជាមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏គាត់មិនសប្បាយចិត្តចំពោះការបង្កើតតុលាការនេះដែរ ពីព្រោះតុលាការនេះមិនអាចធ្វើឲ្យក្រុមគ្រួសាររបស់គាត់ដែលបាត់បង់ជីវិតទៅមានជីវិតរស់ឡើងវិញដែរ ។ ចំណែកហាគិម (មេភូមិ) វិញ ទោះបីជាគាត់មិនបានរៀបរាប់ពីទុក្ខវេទនារបស់គាត់ក៏ដោយ ក៏គាត់បានបង្ហាញពីចំណាប់អារម្មណ៍ មួយចំនួនដែលសហព្រះរាជអាជ្ញាមានវត្តមាននៅក្នុងភូមិរបស់គាត់ ។ ហាគិមបាននិយាយថា «ខ្ញុំមានការសប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលលោកសហព្រះរាជអាជ្ញាបានអញ្ជើញមកក្នុងភូមិរបស់ខ្ញុំដើម្បីប្រាប់អ្នកភូមិឲ្យបានដឹងពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម» ។


លោក ឆាំង យុ និងលោក អែនឌ្រូ ខាលេ សំណេះសំណាលជាមួយបងប្អូនជនជាតិចាម

បន្ទាប់ពីបានស្តាប់រឿងរ៉ាវរបស់អ្នកភូមិរួចមក លោកសហព្រះរាជអាជ្ញាមានការរន្ធត់ចិត្តយ៉ាងខ្លាំងចំពោះហេតុការណ៍ដែលបានកើតឡើងចំពោះប្រជាជននៅក្នុងភូមិនេះ ជាពិសេសទៅទៀតនោះ លោកសហព្រះរាជអាជ្ញាបានមានប្រសាសន៍ថា គាត់នឹងខិតខំប្រឹងប្រែងឲ្យតុលាការនេះមានការកាត់សេចក្តីឲ្យបានឆាប់រហ័សតាមដែលគាត់អាចធ្វើទៅបាននិងខិតខំស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនខ្មែរគ្រប់រូប ។ **ស៊ីម សុភ័ក្រ្ត និង គិត សេរី**

# ទស្សនៈទូទៅចំពោះការស្នើសុំឱ្យមានការផ្លាស់ប្តូរសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## *សេចក្តីផ្តើម*

*គម្រោងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការចូលរួមរបស់អ្នករស់រានមានជីវិតត្រូវបានចាត់ទុកជារឿងមួយថ្មីបំផុត និងពុំធ្លាប់មានពីមុនមក ដោយសារតែមួយភាគធំនៃអ្នករស់រានមានជីវិតត្រូវបានចាត់ទុកជា «ដើមបណ្តឹងរដ្ឋប្បវេណី» ។*

*គម្រោងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់ការចូលរួមរបស់អ្នករស់រានមានជីវិតត្រូវបានចាត់ទុកជារឿងមួយថ្មីបំផុត និងពុំធ្លាប់មានពីមុនមក ដោយសារតែមួយភាគធំនៃអ្នករស់រានមានជីវិតត្រូវបានចាត់ទុកជា «ដើមបណ្តឹងរដ្ឋប្បវេណី» ដែលត្រូវបានគេទទួលស្គាល់ជាភាគីពេញលេញនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ។ ប៉ុន្តែ គម្រោងនេះមិនត្រូវបានគេគោរពទេ សូម្បីតែនៅក្នុងសំណុំរឿងទីមួយក៏ដោយ ។ ប្រសិនបើក្រឡេកមើលទៅលើសំណុំរឿងទីពីរ ដែលអង្គបុរេជំនុំជម្រះបានត្រៀមនឹងដំណើរការហើយ អង្គជំនុំជម្រះកំពុងស្វែងរកលក្ខខណ្ឌបន្ថែមទៀតដើម្បីកំណត់តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គេ ជាពិសេសអ្នកនៅរស់រានមានជីវិតមួយចំនួនធំកំពុងស្វែងរកមុខងារជាដើមបណ្តឹងរដ្ឋប្បវេណី ។ ឥឡូវនេះ អ្នកទាំងនោះកំពុងរៀបចំវា តាមរយៈការកែប្រែវិធានផ្ទៃក្នុងឡើងវិញ ដើម្បីគ្រប់គ្រងដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ គណៈកម្មការច្បាប់និងនីតិវិធីត្រូវបានបង្កើតឡើងដើម្បីពិភាក្សាអំពីសេចក្តីព្រាងច្បាប់នៅសប្តាហ៍ទីមួយនៃខែធ្នូ ហើយប្រសិនបើច្បាប់នេះត្រូវបានគេទទួលយកកិច្ចប្រជុំពេញអង្គនឹងសម្រេចប្រើច្បាប់នេះនៅលើកក្រោយ ។*

*យោងទៅតាមកិច្ចប្រជុំពេញអង្គរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការផ្លាស់ប្តូរផ្នែកច្បាប់ដែលបានលើកឡើងនិងផ្តោតទៅលើ «ការជំរុញការគ្រប់គ្រងនៅក្នុងតុលាការឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន» ។ ទោះបីជាអ្នកអង្កេតការណ៍ស្ទើរតែទាំងអស់យល់ឃើញថា ការរៀបចំនិងការគ្រប់គ្រងដើមបណ្តឹងរដ្ឋប្បវេណីឲ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងមានសារសំខាន់សម្រាប់សំណុំរឿង០០២ក៏ដោយ ក៏ច្បាប់ដែលត្រូវបានគេត្រួតពិនិត្យសាឡើងវិញមិនគួរត្រូវយកមកប្រើប្រាស់ដោយមានតែនាមទេ គឺថាក្នុងការគ្រប់គ្រងរបស់តុលាការ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេដាក់កំហិតរហូតស្ទើរតែមិនមែនជា «ភាគីមួយ» នៅក្នុងដំណើរការនីតិវិធី ។ នៅក្នុងឧទាហរណ៍បែបនេះ ការផ្លាស់ប្តូរតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីរបស់គេនឹងធ្វើឲ្យតុលាការនេះកាន់តែមិនទទួលបាននូវការជឿជាក់ពីសំណាក់អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ ។*

*ស្ថិតនៅក្រោមច្បាប់កម្ពុជា និងនៅក្នុងយុត្តាធិការច្បាប់ស៊ីវិលផ្សេងទៀត មនុស្សម្នាក់ៗអាចធ្វើជា «ដើមបណ្តឹងរដ្ឋប្បវេណី» ដែលត្រូវបានផ្តល់ឲ្យនូវសិទ្ធិជាក់លាក់មួយ ជាសិទ្ធិដែលទាំងអ្នកនៅរស់រានមានជីវិត និងមេធាវីរបស់គេចាំបាច់ត្រូវតែមានមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បើសិនជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានរក្សាសិទ្ធិទាំងនេះឲ្យស្ថិតនៅក្រោមច្បាប់ដែលត្រូវបានត្រួតពិនិត្យ នោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមិនត្រឹមតែធ្វើឲ្យផ្លាស់ប្តូរតម្លៃដែលមានពីមុនៗរបស់គម្រោងចូលរួមរបស់ជនរងគ្រោះសម្រាប់តុលាការអន្តរជាតិនាពេលខាងមុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យមានការយល់ច្រឡំចំពោះអ្នកនៅរស់រានមានជីវិតអំពីតួនាទីរបស់ពួកគេនៅក្នុងដំណើរការនីតិវិធីរបស់តុលាការទៀតផង ។ ការប្រែប្រួលយ៉ាងឆាប់រហ័សនៃច្បាប់នេះនឹងមិនមានភាពហ្មត់ចត់ទេ ដោយសារតែអ្នកដែលចូលរួមទាំងនេះ គឺជាអ្នកដែលនៅរស់រានមានជីវិតពីឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិដ៏សាហាវបំផុត ។*

## *សិទ្ធិស្របច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការ*

អន្តរជាតិលើកទីមួយដែលផ្តល់ឲ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ «ដើមបណ្តឹងរដ្ឋប្បវេណី» គឺជានិយមន័យមួយរបស់សិល្បៈ ។ បើទោះបីជាបណ្តុំនៃច្បាប់រួមមានយុត្តាធិការខុសៗគ្នាក៏ដោយ ក៏តុលាការនេះមិនមែនគ្រាន់តែបង្ហាញថា ជនរងគ្រោះមួយចំនួនជា «ដើមបណ្តឹងរដ្ឋប្បវេណី» នៅក្នុងដំណើរការនីតិវិធីនោះឡើយ ប្រសិនបើមិនបានផ្តល់ឲ្យពួកគេនូវសិទ្ធិមួយដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកដែលនៅអមជាមួយនឹងតួនាទីនេះ ។ គួរឲ្យកត់សម្គាល់ នៅខណៈដែលតុលាការព្រហ្មទណ្ឌអន្តរជាតិផ្តល់ឲ្យនូវការចូលរួមរបស់ជនរងគ្រោះកាន់តែច្រើនឡើង គម្រោងនេះមិនបានធ្វើឲ្យមានការកើនឡើងនូវកម្រិតនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ពីព្រោះជនរងគ្រោះនៅមុនតុលាការឧក្រិដ្ឋកម្មអន្តរជាតិមិនត្រូវបានគេទទួលស្គាល់ជាដើមបណ្តឹងនៅក្នុងដំណើរការនីតិវិធីទេ ។ បន្ថែមពីលើនេះទៀត តុលាការពិសេសសម្រាប់ប្រទេសលីបង់ដែលទទួលឥទ្ធិពលពីច្បាប់ស៊ីវិល ដែលចែងថា «ទោះបីជាជនរងគ្រោះមិនមានសិទ្ធិដូចគ្នា ក្នុងការធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ប្រព័ន្ធច្បាប់ស៊ីវិលយ៉ាងណាក៏ដោយ ដូចជាទាមទារសំណងជាដើម ពួកគេប្រហែលជាអនុវត្តសិទ្ធិតាមនីតិវិធីមួយចំនួន ឧទាហរណ៍ ការទទួលឯកសារដែលបានដាក់ដោយភាគីនីមួយៗ ហៅសាក្សីដោយយោងតាមការអនុញ្ញាតរបស់អង្គជំនុំជម្រះត្រួតពិនិត្យនិងតាមដានសាក្សី បំពេញញត្តិនិងសេចក្តីសង្ខេប» ។ ទាំងនេះអាចបង្ហាញថា តុលាការអន្តរជាតិទាំងនេះបានផ្តល់ឲ្យមាននូវការចូលរួមរបស់ជនរងគ្រោះដែលមិនបានលើកកម្ពស់ ឲ្យមាននូវកម្រិតនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាអន្តរជាតិ ដោយហាក់ដូចជាច្បាប់មួយដែលថា គម្រោងនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យ៉ាងហោចណាស់ត្រូវតែផ្តល់ឲ្យអ្នកនៅរស់រានមានជីវិតនូវសិទ្ធិដែលមាននៅក្នុងគម្រោងនៃការចូលរួមរបស់អ្នកនៅរស់រានមានជីវិត ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់ដូចខាងក្រោម មានការព្រួយបារម្ភថា ដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាតាមការពិតទៅមានសិទ្ធិតែមួយចំនួនតូចប៉ុណ្ណោះ ។

សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមមិនបានកើតឡើងដោយមិនមានឥទ្ធិពលពីផ្នែកខាងក្រៅទេ ។ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ តុលាការត្រូវតែធ្វើឲ្យមានសមភាពរវាងសិទ្ធិរបស់អ្នកនៅរស់និងសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ ។ បន្ថែមពីលើនេះទៀត ដំណើរការនីតិវិធីនេះគួរតែដំណើរការឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ។ ផលប្រយោជន៍ទាំងបីនេះតែងតែមានឥទ្ធិពលទៅលើគ្នា គឺថានៅពេលដែលភាគីណាមួយទទួលបានផលប្រយោជន៍ នោះភាគីមួយទៀតនឹងបាត់បង់ផលប្រយោជន៍ ។ នេះជាការពិតសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសារវាពិនិត្យមើលទៅលើដំណើរការនីតិវិធីសំខាន់ៗដែលចូលរួមដោយដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ ។ ឥទ្ធិពលនៃផលប្រយោជន៍ទាំងនេះបានធ្វើឲ្យចៅក្រម ឡាវើញ ចោទជាសំណួរថា «តើយើងអាចធ្វើអ្វីបានដោយមិនរំលោភច្បាប់ ឬដោយមិនផ្លាស់ប្តូរអត្ថន័យនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងគោលបំណងរបស់តុលាការទាំងមូលដែលបង្កើតឡើងដោយសកម្មភាពដែលមានទំនាក់ទំនងគ្នាគឺសកម្មភាពស៊ីវិល និងសកម្មភាពឧក្រិដ្ឋកម្ម» ។

ការធ្វើវិសោធនកម្មវិធានដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានលក្ខណៈតឹងរ៉ឹងជាងមុន ធ្វើឲ្យមានការព្រួយបារម្ភមួយថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងមើលរំលងចំណុចនេះ ។ ដើម្បីបញ្ឈប់នូវការព្រួយបារម្ភនេះ ច្បាប់ដែលត្រូវបានសើរើត្រូវតែរក្សាទំនាក់ទំនងរវាងមេធាវីនិងកូនក្តីគឺសិទ្ធិក្នុងការចូលរួមរបស់អ្នកទាំងពីរខណៈពេលដែលកំពុងបន្តធានានូវសិទ្ធិចូលរួមនៅក្នុងដំណើរការនីតិវិធីក្នុងនាមជា «ភាគី» មួយរបស់អ្នកនៅរស់រានមានជីវិត ។ អ្នកដែលមិនបានធ្វើវាផង នឹងត្រូវកាត់បន្ថយសិទ្ធិនៃការចូលរួមរបស់អ្នកនៅរស់រានមានជីវិត ដែលពួកគេនឹងមិនត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណីតទៅទៀតឡើយ ។

## ទំនាក់ទំនងរវាងមេធាវីនិងកូនក្តី

ក្នុងនាមជាភាគីនៅក្នុងដំណើរការនីតិវិធី ក្រោមវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលការតំណាងដោយមេធាវី ។ ដើម្បីឲ្យសិទ្ធិមួយនេះមានលក្ខណៈកាន់តែរឹងមាំ និងមានអត្ថន័យ វាត្រូវតែបន្តដាក់បញ្ចូលធាតុផ្សំសំខាន់ៗនៃទំនាក់ទំនងរវាងមេធាវី

និងកូនក្តី ៖ សិទ្ធិរបស់កូនក្តីក្នុងការជួលមេធាវីម្នាក់ទៅតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិកំណត់គោលបំណងដែលខ្លួនចង់បានការតំណាងពីមេធាវីនិងចូលរួមសម្រេចចិត្តការអនុវត្ត ។ ការមិនបានដាក់បញ្ចូលធាតុសំខាន់ៗទាំងនេះនៅក្នុងច្បាប់ដែលត្រូវបានត្រួតពិនិត្យនឹងត្រូវកាត់បន្ថយសិទ្ធិទទួលបានការប្រឹក្សាដែលធ្វើឲ្យមានចម្ងល់ថាតើអង្គជំនុំជម្រះកំពុងយកចិត្តទុកដាក់ទៅលើមូលដ្ឋានគ្រឹះរបស់វិធានច្បាប់នេះទេ? ។

យោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅដំណាក់ការចាប់ផ្តើម ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវដាក់បញ្ចូលគ្នាជាក្រុមមួយ ហើយក្រុមនោះនឹងត្រូវតំណាងដោយសហមេធាវីតំណាង ។ វាក៏បានលើកឡើងបន្ថែមទៀតថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវផ្តល់ការគាំទ្រចំពោះសហមេធាវីតំណាង ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថិតនៅក្រោមគម្រោងនេះ វាមិនទាន់ច្បាស់លាស់នៅឡើយទេថាអ្នកណានឹងតំណាងឲ្យចំណាប់អារម្មណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ។ វាមានសារសំខាន់ខ្លាំងណាស់ដែលថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនស្ថិតនៅឆ្ងាយពីជំនួយមេធាវីដែលបានលើកកម្ពស់កំណត់ថាវាមិនមែនជាតួនាទីអ្វីដែលសំខាន់ និងចៀសឆ្ងាយពីការជួយគាំទ្រតុលាការជំនួសឲ្យកូនក្តីរបស់គេឡើយ ។ ប្រសិនបើនេះបង្ហាញនៅក្នុងករណីនេះ ទោះបីជាយ៉ាងណាក៏ដោយ នឹងមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមកយ៉ាងពិតប្រាកដរវាងមេធាវីនាំមុខជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗជាមួយនឹងភាសាមួយច្បាស់លាស់ដើម្បីបំពេញកាតព្វកិច្ចរបស់សហមេធាវីតំណាងចំពោះដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ហើយមិនមែនគ្រាន់តែបង្រួមក្រុមចូលគ្នាទាំងអស់នោះទេ ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិបានចែងយ៉ាងច្បាស់លាស់ថា “អ្នកតំណាងផ្នែកច្បាប់ទូទៅ គួរតែទទួលខុសត្រូវក្នុងការតំណាងឲ្យជនរងគ្រោះដែលមានគោលបំណងដូចគ្នានៅក្នុងអំឡុងពេលដំណើរការនីតិវិធីនិងតំណាងឲ្យជនរងគ្រោះជាក់លាក់នៅពេលដែលផលប្រយោជន៍របស់បុគ្គលម្នាក់ៗអាចនឹងបាត់បង់” ។ ភាសាបែបនេះនៅក្នុងច្បាប់វិសោធនកម្មនឹងជួយកាត់បន្ថយនូវការព្រួយបារម្ភដែលថា ចំណាប់អារម្មណ៍នៃបុគ្គលម្នាក់ៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺកំពុងស្ថិតនៅក្រោមចំណាប់អារម្មណ៍ទាំងមូលរបស់ក្រុមបង្រួបបង្រួមមួយ ។

ច្បាប់ដែលត្រូវបានត្រួតពិនិត្យចាំបាច់ត្រូវតែមានយន្តការមួយផងដែរសម្រាប់ដោះស្រាយជម្លោះរវាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាង ។ ជម្លោះបែបនេះ នឹងកើតឡើងមិនអាចចៀសវាងបានរវាងមេធាវីទាំងនោះ ជាពិសេសនៅពេលមេធាវីតំណាងឲ្យកូនក្តីសម្រាប់គោលបំណងនិងចំណាប់អារម្មណ៍ផ្សេងគ្នា ។ ដើម្បីកុំឲ្យមានបញ្ហាជម្លោះនៅក្នុងច្បាប់ដែលត្រូវត្រួតពិនិត្យ គួរតែកុំយកចិត្តទុកដាក់ទៅនឹងភាពពិតប្រាកដណាមួយដែលមិនមានការព្រមព្រៀង ។ គួរឲ្យកត់សម្គាល់ តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានចែងថា ប្រសិនបើអ្នកតំណាងផ្នែកច្បាប់មិនអាចឡើងបង្ហាញពីចំណាប់អារម្មណ៍របស់ជនរងគ្រោះមួយក្រុម ឬច្រើនក្រុមដោយ “យុត្តិធម៌ និងស្មើភាពគ្នា” ទេ អ្នកតំណាងផ្នែកច្បាប់នឹងជម្រាបអង្គជំនុំជម្រះថាជនណានឹងចាត់វិធានការត្រឹមត្រូវ ឧទាហរណ៍ជ្រើសរើសការិយាល័យរបស់ក្រុមប្រឹក្សាសាធារណៈ សម្រាប់ជនរងគ្រោះដើម្បីបង្ហាញពីជនរងគ្រោះមួយក្រុមទាក់ទងទៅនឹងបញ្ហាជាក់លាក់ណាមួយដែលបង្កើតពីជម្លោះផលប្រយោជន៍ ។

ដូចគ្នានេះដែរ ចាំបាច់ត្រូវតែមានការលើកទឹកចិត្តដល់សហមេធាវីតំណាងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីដាក់បញ្ចូលគំនិតខ្វែងយោបល់គ្នាពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រសិនបើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញការប្រឆាំងដាច់ខាតចំពោះការសម្រេចចិត្តជាក់លាក់ណាមួយដែលធ្វើឡើងដោយសហមេធាវីតំណាង នោះចាំបាច់ត្រូវតែមានជម្រើសមួយផ្សេងទៀត ។ បើនិយាយអំពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីវិញ ដូចជាក្រុមប្រឹក្សាផ្នែកច្បាប់ផ្សេងៗទៀតដែរ ចាំបាច់ត្រូវតែស្ថិតនៅក្រោមក្រមសីលធម៌ជាតិនិងអន្តរជាតិដើម្បីតំណាងឲ្យទស្សនៈ និង ផលប្រយោជន៍កូនក្តីរបស់គេ ដែលទាំងនេះអាចធ្វើឲ្យពួកគេស្ថិតនៅក្នុងស្ថានភាពមួយដែលមិនអាចទៅរួចឡើយ ។

ជាងនេះទៅទៀត សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងត្រូវតែទទួលបាននូវការការពារ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែទទួលបាននូវការអនុញ្ញាតផងដែរ តាមរយៈដំណើរការនីតិវិធីក្នុងការជួលមេធាវីដែលគេបានជ្រើសរើស ក៏ដូចជាបញ្ឈប់មេធាវីរបស់គេ និងកំណត់អំពីគោលបំណង និងអត្ថន័យនៃការអនុវត្ត

គោលបំណងទាំងនោះ ។ នេះគឺមានសារសំខាន់ខ្លាំងណាស់ ពីព្រោះអ្នករស់រានមានជីវិតជាច្រើននៅក្នុងសំណុំរឿង០០២ គឺមានសាសនាឬជាតិពន្ធុផ្សេងៗគ្នា ដែលប្រហែលជាមានជួបប្រទះនូវការឈឺចាប់នៅពេលខុសគ្នា ទីកន្លែងខុសគ្នា និងដោយស្នាដៃមនុស្សខុសគ្នា ហើយប្រហែលជាមានគោលបំណងខុសៗគ្នាក្នុងការចូលរួម និងចង់បានសំណងខុសៗគ្នា ។ ភាពខុសប្លែកនិងផលប្រយោជន៍ប្លែកគ្នាទាំងនេះគួរតែត្រូវបានបង្ហាញ ប្រសិនបើពិតជាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្ថិតនៅក្រោមច្បាប់ដែលត្រូវបានត្រួតពិនិត្យ ។

## សិទ្ធិនៅក្នុងការចូលរួម

ស្ថិតនៅក្រោមច្បាប់វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានព្រាងទុកពីមុនមក នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ចូលរួមនៅក្នុងដំណើរការនីតិវិធី "ជនរងគ្រោះនោះនឹងក្លាយជាដើមបណ្តឹងម្នាក់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌរបស់តុលាការ" ។ ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីនោះមានសិទ្ធិក្នុង "ការចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយគាំទ្រការកាត់ទោស" ក៏ដូចជាដើម្បីស្វែងរក "សំណងផ្នែកសីលធម៌និងសំណងរួម" ។ សិទ្ធិក្នុងការចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់តុលាការជាភាគីត្រូវមានសិទ្ធិមួយចំនួន ដូចជា សិទ្ធិកោះហៅ សិទ្ធិត្រួតពិនិត្យនិងអង្កេតសាក្សី និងសិទ្ធិត្រូវបានសួរសំណួរ និងធ្វើការស្នើសុំឲ្យមានវិធានការស៊ើបអង្កេតផ្សេងៗទៀត ។ សិទ្ធិទាំងនេះត្រូវតែរក្សានូវទ្រង់ទ្រាយដូចដើមដើម្បីរក្សាភាពជាភាគីសម្រាប់ដំណើរការនីតិវិធី ។

ពីព្រោះតែសហមេធាវីតំណាងមានបំណងចង់ធ្វើជាតំណាងឲ្យគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានយកមកអនុវត្តតាមរយៈសហមេធាវីតំណាង ។ ឧទាហរណ៍ សិទ្ធិមួយក្នុងចំណោមសិទ្ធិនៃការចូលរួមចម្បង ដែលអាចចូលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងច្បាប់យុត្តាធិការស៊ីវិលនៅលើពិភពលោកបាន ដោយរួមទាំងប្រទេសកម្ពុជា គឺជាសិទ្ធិក្នុងការស្នើសុំឲ្យបើកការស៊ើបអង្កេត ។ ពីមុន សិទ្ធិនេះត្រូវបានយកមកអនុវត្តតាមរយៈមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ឥឡូវវាមិនទាន់ច្បាស់លាស់នៅឡើយទេ ថាតើឥទ្ធិពលនៃការបង្កើតសហមេធាវីតំណាងនឹងមានចំពោះសិទ្ធិនេះដែរឬទេ ប៉ុន្តែគេអាចសន្និដ្ឋានបានថាវាត្រូវបានយកមកអនុវត្តតាមរយៈសហមេធាវីតំណាង ។ ទោះបីជាយ៉ាងណាក៏ដោយ សហមេធាវីតំណាងត្រូវតែទទួលខុសត្រូវចំពោះផលប្រយោជន៍របស់អ្នកនៅរស់រានមានជីវិតទាំងអស់



បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាជួយជនរងគ្រោះបំពេញពាក្យបណ្តឹង

ដែលស្ថិតនៅក្នុងក្រុមបង្រួបបង្រួម ។ ដូច្នេះ ប្រសិនបើក្រុមមួយរបស់អ្នកនៅរស់រានមានជីវិតចង់ស្នើសុំឲ្យមានការស៊ើបអង្កេត ប៉ុន្តែសហមេធាវីតំណាងមានអារម្មណ៍ថា សកម្មភាពនេះអាចប្រឆាំងទៅនឹងនីតិវិធីទាំងមូលនោះ សហមេធាវីតំណាងអាចបដិសេធចំពោះការស្នើសុំឲ្យមានការស៊ើបអង្កេតនេះ ដោយកាត់បន្ថយសិទ្ធិនេះទាំងស្រុង ។ ជាថ្មីម្តងទៀត ការបង្ហាញឡើងអំពីយន្តការវែងយោបល់នេះ គឺមានសារសំខាន់ណាស់ក្នុងការផ្តល់នូវខ្លឹមសារក្នុងការអនុវត្តនូវសិទ្ធិទាំងនេះ ។

ដូចដែលលោកចៅក្រម ឡាវើញ បានលើកឡើងនៅក្នុងការវែងយោបល់មួយថា ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងយុត្តាធិការក្នុងស្រុក “គួរតែចូលរួមក្នុងដំណើរការនីតិវិធីច្បាប់ទាំងមូលដែលគោលបំណងរួម ដើម្បីស្វែងរកការពិតទាក់ទងនឹងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដែលវាប្រហែលជាការទទួលខុសត្រូវចម្បងរបស់ដើមបណ្តឹងរដ្ឋប្បវេណី” ។ ការវែងគំនិតនេះគឺត្រូវបានសម្រេចឡើងនៅពាក់កណ្តាលឆ្នាំ២០០៩ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការដែលថា លុបចោលសិទ្ធិទាំងស្រុងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចូលរួមនៅក្នុងដំណើរការកាត់ទោស និងកាត់បន្ថយសិទ្ធិរបស់គេក្នុងការតាមដានសាក្សីមួយចំនួន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រេចចិត្តបែបនេះ ដោយសារតុលាការអន្តរជាតិដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមនៅក្នុងដំណើរការនីតិវិធី ទោះបីមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានផ្តល់ឲ្យជនរងគ្រោះជាមួយនឹងសិទ្ធិចូលរួមនៅក្នុងដំណើរការកាត់ទោសក៏ដោយ ។ ទោះបីជាការផ្លាស់ប្តូរនីមួយៗចំពោះច្បាប់មិនបានសម្រេចភ្លាមៗ រួមទាំងការសម្រេចចិត្តនាពេលថ្មីៗនេះក៏ដោយ ក៏គម្រោងច្បាប់វិសោធនកម្មមួយដែលមិនបានបម្រើដល់សិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសិទ្ធិក្នុងការស្នើសុំឲ្យមានសកម្មភាពស៊ើបអង្កេត ដែលកំណត់ថា ដើមបណ្តឹងរដ្ឋប្បវេណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមិនមែនជា “ដើមបណ្តឹង” នៅក្នុងដំណើរការនីតិវិធីរបស់តុលាការបន្តទៀតដែរ ។

## សេចក្តីសន្និដ្ឋាន

ប្រសិនបើវិធានដើមបណ្តឹងរដ្ឋប្បវេណីថ្មីត្រូវបានអនុម័ត ដោយមិនបានបម្រើដល់ទំនាក់ទំនងរវាងមេធាវីនិងកូនក្តី និងសិទ្ធិដ៏ពិតប្រាកដមួយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើជា “ភាគី” នៅក្នុងដំណើរការនីតិវិធី នោះវានឹងមិនច្បាស់លាស់ទេថា តើវាជាតួនាទីអ្វី ប្រសិនបើអ្នកនៅរស់រានមានជីវិតនៅតែបន្តមានមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដើម្បីបម្រើដល់តួនាទីដ៏មានអត្ថន័យរបស់គេដូចដែលគិតថាល្អពីមុនមក អង្គជំនុំជម្រះត្រូវតែធ្វើឲ្យប្រាកដថា ច្បាប់នេះមិនត្រូវបានដកចេញច្រើនពេកនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយប្រើឈ្មោះសំណុំរឿងគ្រប់គ្រងយុត្តាធិការ ។ នៅអំឡុងពេលដែលអង្គជំនុំជម្រះមានសិទ្ធិគ្រប់បែបយ៉ាងដើម្បីធ្វើបែបនេះ ប្រសិនបើអង្គជំនុំជម្រះចង់បញ្ឈប់នូវការចូលរួមរបស់ជនរងគ្រោះ អង្គជំនុំជម្រះគួរតែប្រើភាពស្មោះត្រង់ចំពោះអ្នកដែលនៅរស់រានមានជីវិត ។ ដូចដែលអ្នកអង្កេតការណ៍ពីរនាក់បានសរសេរថា “ប្រសិនបើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវជំនួសដោយការតំណាងរបស់ជនរងគ្រោះ តុលាការនេះត្រូវតែពន្យល់ដើមបណ្តឹងទាំងអស់ថា សិទ្ធិនៃការចូលរួមរបស់គេត្រូវបានលុបចោល” ។ ដូចដែលលោកឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងក្នុងទស្សនាវដ្តីស្វែងរកការពិតនៅលេខខែកញ្ញា ឆ្នាំ២០០៩ថា ៖

វាជាការពិតដែលថា ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនមិនបានយល់ទាំងស្រុងចំពោះអត្ថន័យនៃពាក្យ “ដើមបណ្តឹងរដ្ឋប្បវេណី” និងដែនកំណត់នៃតួនាទីរបស់គេនៅក្នុងដំណើរការនីតិវិធីរបស់តុលាការទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាជាទង្វើមួយដែលមិនសមរម្យសម្រាប់តុលាការ ដោយបានលាក់បាំងនិងខកខានមិនបានចុះទៅផ្សព្វផ្សាយតាមមូលដ្ឋាន ។ ប្រសិនបើតុលាការនេះចង់កំណត់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី តុលាការគួរតែមានកាតព្វកិច្ចក្នុងការពន្យល់ផ្នែកច្បាប់ទាំងមូលទៅដល់សាធារណជន និងដើមបណ្តឹងទាំងអស់នៅមុនពេលដែលគម្រោងចុងក្រោយត្រូវបានយកមកអនុវត្ត ។

ការផ្តល់ឲ្យនូវបទពិសោធន៍នៃការឈឺចាប់ និងរបួសផ្នែកសតិអារម្មណ៍ដោយអ្នកនៅរស់រានមានជីវិតទាំងនេះ គឺជារឿងមួយតិចតួចបំផុតដែលអង្គជំនុំជម្រះអាចធ្វើបាន ។

**អានដ្រូ ហ្វ. ដាយមេន**

# ម្ដាយខ្ញុំក្នុងរបបខ្មែរក្រហម

របបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានគេស្គាល់ជាទូទៅថា របបខ្មែរក្រហមបានសម្លាប់ប្រជាពលរដ្ឋខ្មែរអស់ជិតពីរលាននាក់ ។ ទោះបីជារបបនេះបានដួលរលំទៅអស់រយៈពេល៣១ឆ្នាំហើយក៏ដោយ ក៏រឿងនេះហាក់ដូចជានៅថ្មីៗនៅឡើយសម្រាប់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់របបវាលពិឃាតនេះ ហើយនៅតែចងចាំព្រឹត្តិការណ៍ទាំងអស់នោះជានិច្ច ។

ខ្ញុំក៏ដូចជាក្មេងជំនាន់ក្រោយដែលកើតមិនទាន់របបនេះ គិតថា មិនគួរឲ្យជឿទេ ដែលខ្មែរសម្លាប់ខ្មែរអស់ជិតពីរលាននាក់តាមរយៈការសម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ ការកើតជំងឺគ្មានថ្នាំព្យាបាល និងការចោទប្រកាន់ថាក្បត់ ។ ទុក្ខវេទនារបស់ប្រជាជនពលរដ្ឋដែលនៅរស់ និងបានឆ្លងកាត់របបនេះ ពិតជាមិនសូវខុសគ្នាប៉ុន្មានទេ ។ ជាក់ស្ដែង ឪពុកម្ដាយរបស់ខ្ញុំបានរៀបរាប់ឲ្យដឹងថា ដំបូងឡើយម្ដាយរបស់ខ្ញុំរស់នៅភូមិប្រកដីគាំ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ ។ ក្រោយពីរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ចេញពីតំណែងនៅឆ្នាំ១៩៧០ សភាពការណ៍នៅក្នុងប្រទេសមានភាពច្របូកច្របល់ជាខ្លាំង ហើយស្រុកគិរីវង្សដែលនៅជាប់នឹងប្រទេសវៀតណាមមួយភាគធំបានធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់វៀតកុង (កងទ័ពរណសិរ្សវៀតណាម) និងខ្មែរកុម្មុយនីស្ត (ខ្មែរក្រហម) ដែលភាគច្រើនទើបតែបញ្ចប់ការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រទ័ពនៅទីក្រុងហាណូយ ។ ដូច្នេះ ការសិក្សារបស់ម្ដាយខ្ញុំក៏ត្រូវបានផ្អាកដោយសិស្សានុសិស្សនៅតាមសាលា និងគ្រូបង្រៀននៅស្រុកគិរីវង្សបានចូលរួមបម្រើចលនារំដោះរបស់ខ្មែរក្រហម ក្រោមការឃោសនាឲ្យជួយច្បាំងរំដោះទឹកដីពីចក្រពត្តិអាមេរិកនិងរដ្ឋាភិបាល លន់ នល់ ។ ខណៈពេលនោះ យន្តហោះរបស់សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកលើភូមិអ្នកស្រុកដែលធ្វើឲ្យមនុស្សជាច្រើននាក់ស្លាប់បាត់បង់ជីវិត ។

នៅឆ្នាំ១៩៧១ ដោយការប្រយុទ្ធគ្នាកាន់តែសាហាវឡើងៗរវាងភាគីទាំងពីរ បានធ្វើឲ្យប្រជាជនភ័យខ្លាចគ្រប់គ្នា ដោយខ្លះនាំគ្នារត់ចេញពីផ្ទះទៅពួននៅព្រៃ និងខ្លះទៀតសម្ងំលាក់ខ្លួននៅក្នុងផ្ទះមិនហ៊ានចេញទៅណាមកណាទេ ។ ពេលនោះ គ្រួសាររបស់ខ្ញុំក៏បានមកដល់រដ្ឋធានីភ្នំពេញ រួចស្នាក់នៅជាមួយបងប្អូននៅម្ដុំទួលទំពូងរហូតដល់ឆ្នាំ១៩៧៣ ទើបគ្រួសាររបស់ម្ដាយខ្ញុំបានប្រឹងប្រែងធ្វើការរហូតដល់សន្សំលុយទិញផ្ទះបានមួយខ្នងនៅសង្កាត់លេខ៧ក្នុងក្រុងភ្នំពេញ ។

នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៅទីក្រុងភ្នំពេញដែលធ្លាប់តែរស់នៅយ៉ាងសុខសប្បាយ និងកំពុងតែទទួលទេវតាឆ្នាំថ្មីបែរជានាំគ្នាភ័យខ្លាចគ្រប់ៗគ្នាព្រោះស្នូរគ្រាប់កាំភ្លើងគ្រប់ធុនបានលាន់ឮយ៉ាងខ្លាំងនៅគ្រប់ទីកន្លែង ។ ចំណែកគ្រួសាររបស់ខ្ញុំដែលមានសមាជិកទាំងអស់ប្រាំមួយនាក់នាំគ្នាភ័យផងអរផង បន្ទាប់ពីខ្មែរក្រហមវាយដណ្ដើមបានទីក្រុងភ្នំពេញ ។ ប៉ុន្តែមិនបានប៉ុន្មាននាទីផងស្រាប់តែប្រជាជនទាំងអស់ត្រូវកងយោធាក្មេងៗរបស់ខ្មែរក្រហម ដែលមានសម្លៀកបំពាក់ពណ៌ខ្មៅស្រែកគំរាមឲ្យប្រជាជនចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ដោយអះអាង


អ្នកគ្រូ ជា កល្យាណ ទទួលសញ្ញាបត្រផ្នែកបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រ

ថា ពីរបីថ្ងៃនឹងត្រឡប់មកវិញ ហើយមិនចាំបាច់យកអ្វីទៅជាមួយទេ ។ បន្ទាប់មក នៅតាមផ្ទះនីមួយៗនាំគ្នារៀបចំអីវ៉ាន់ និងប្រមូលបងប្អូនឲ្យនៅជុំគ្នា រួចធ្វើដំណើរតាមទិសដៅរបស់អង្គការកំណត់ ។ ពេលធ្វើដំណើរ ខ្មែរក្រហមបានបាញ់កាំភ្លើងនិងបាញ់រះទៅលើយ៉ាងរន្ថើនដើម្បីឲ្យប្រជាជនប្រញាប់ចាកចេញ ប្រសិនបើនរណារឹងទទឹងនឹងបាញ់សម្លាប់ភ្លាមនៅនឹងកន្លែងតែម្តង ។

នៅវេលាម៉ោងប្រហែលមួយ គ្រួសាររបស់ម្តាយខ្ញុំបានចាកចេញពីផ្ទះតាមផ្លូវម៉ៅសេទុងឆ្ពោះទៅផ្លូវជាតិលេខមួយ ដោយប្រើរយៈពេលបួនម៉ោងទើបទៅដល់ច្បារអំពៅ ។ នៅទីនោះ សំឡេងថ្ងូររបស់មនុស្សចាស់ជរា ជនពិការ អ្នករបួស ដែលត្រូវបានបងប្អូនបោះបង់ចោល និងសាកសពនៅតាមផ្លូវដែលទើបតែស្លាប់ថ្មីៗមើលទៅគួរឲ្យអាណិតអាសូរជាទីបំផុត ។ សម្រាកនៅច្បារអំពៅមួយយប់ ព្រលឹមឡើងគ្រួសាររបស់ខ្ញុំក៏បន្តដំណើរទៅមុខទៀត រហូតដល់ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ពីរថ្ងៃក្រោយមក ខ្មែរក្រហមបានកោះហៅប្រជាជនចំណូលថ្មីទៅប្រជុំ ហើយប្រកាសថា គ្រួសារដែលមានស្រុកកំណើតនៅទីណា ត្រូវត្រឡប់ទៅស្រុកនោះវិញ ។ ពេលនោះ គ្រួសាររបស់ខ្ញុំដែលធ្វើដំណើរអស់រយៈពេល៨ថ្ងៃ ក៏បានមកដល់ស្រុកកំណើត ។ បន្ទាប់មក គណៈគ្រប់គ្រងខ្មែរក្រហមបានចាត់តាំងឲ្យគ្រួសារម្តាយខ្ញុំចូលក្នុងកងចល័តដែលធ្វើឲ្យគ្រួសាររបស់ខ្ញុំត្រូវបែកគ្នាទៅធ្វើការរៀងៗខ្លួន ដោយមួយសប្តាហ៍ទើបបានជួបគ្នាម្តង ។ ម្តាយរបស់ខ្ញុំបានរៀបរាប់ឲ្យដឹងថា ដំបូងខ្មែរក្រហមមិនបានធ្វើបាបប្រជាជនទេ ប៉ុន្តែក្រោយមកចាប់ផ្តើមមានការរឹតបន្តឹងជាខ្លាំង ដោយយកមនុស្សទៅសម្លាប់ជារៀងរាល់ថ្ងៃ រហូតធ្វើឲ្យម្តាយរបស់ខ្ញុំព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់ ក៏ដូចជាសមាជិកគ្រួសាររបស់គាត់ដែរ ។ ប៉ុន្តែ ដោយសារអ្នកស្រុកនៅក្នុងភូមិខ្ញុំសុទ្ធតែជាមនុស្សចិត្តល្អ ទើបគ្រួសាររបស់ម្តាយខ្ញុំមិនទទួលរងនូវការលំបាកដូចគ្រួសារដទៃទេ ។




នៅខែឧសភា ឆ្នាំ១៩៧៧ គ្រួសារម្តាយរបស់ខ្ញុំត្រូវជម្លៀសទៅរស់នៅក្នុងភូមិស្ទឹង ឃុំអូរសារាយ ស្រុកត្រាំកក់ ខេត្តតាកែវ ។ នៅទីនោះ គ្រួសាររបស់ម្តាយខ្ញុំកាន់តែព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្លួនជាងមុនទៅទៀត ដោយសារតែបានឮដំណឹងថាតំបន់នេះខ្មែរក្រហមតែងតែយកអ្នកថ្មីទៅសម្លាប់ជានិច្ច ។ ប៉ុន្តែដោយការខិតខំប្រឹងប្រែងធ្វើការ និងមិនដែលធ្វើអ្វីឲ្យមានកំហុស គ្រួសាររបស់ខ្ញុំក៏អាចរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ។

ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ គ្រួសាររបស់ម្តាយខ្ញុំបានបាត់បង់ប្អូនម្នាក់ ហើយបាត់ដំណឹងរហូតដល់បច្ចុប្បន្ននេះ ។ ពេលនោះ បំណងប្រាថ្នាថាវិលត្រឡប់មករស់នៅភ្នំពេញវិញត្រូវប្តូរទិសដៅទៅរស់នៅភូមិទន្លាប់ ឃុំសោម ស្រុកគិរីវង្ស ខេត្តតាកែវវិញ ។ មួយឆ្នាំក្រោយមក ទើបគ្រួសាររបស់ម្តាយខ្ញុំបានវិលត្រឡប់មករស់នៅភ្នំពេញ ។ ចុងក្រោយ ក្រុមគ្រួសាររបស់ម្តាយខ្ញុំនៅតែសង្ឃឹមថាប្អូនប្រុសរបស់គាត់នឹងវិលត្រឡប់មកផ្ទះនៅថ្ងៃណាមួយជាមិនខាន ។ ខ្ញុំយល់ថា របបកម្ពុជាប្រជាធិបតេយ្យជារបបមួយដែលបានសម្លាប់ជនជាតិរបស់ខ្លួនយ៉ាងសាហាវព្រៃផ្សៃ ។ ការរស់នៅរបស់មនុស្សនៅសម័យនោះ ប្រៀបដូចជាសត្វធាតុដែលត្រូវរងការធ្វើបាបគ្មានធម៌មេត្តា ជាពិសេសបណ្តុះគំនិតឲ្យខ្មែរយើងបាត់បង់សីលធម៌ លែងស្គាល់សាច់ញាតិរបស់ខ្លួនអស់រលីង ។ លើសពីនេះទៅទៀត របបនេះអប់រំមនុស្សឲ្យស្អប់ខ្ពើមគ្នាទៅវិញទៅមក ដូចជាកូនរាយការណ៍ទៅអង្គការឲ្យយកឪពុកខ្លួនទៅសម្លាប់ជាដើម ។

ខ្ញុំមិនចង់ឲ្យរបបនេះវិលត្រឡប់មកវិញជាដាច់ខាត ព្រោះរបបនេះបានបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធប្រទេសស្ទើរតែមិនអាចស្តារបាន ជាពិសេសបានបន្សល់ទុកនូវស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការ និងជំងឺផ្លូវចិត្តរាប់រយជំពូក ។

ដូច្នេះ ដើម្បីទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់មកវិញ ខ្ញុំយល់ថា យើងត្រូវតែបង្រៀនឲ្យកូនខ្មែរជំនាន់ក្រោយបានដឹង និងយល់ច្បាស់ពីរបបនេះ ដោយកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ និងអប់រំនិងផ្សព្វផ្សាយកុំឲ្យក្មេងជំនាន់ក្រោយប្រព្រឹត្តអំពើបែបនេះទៀត ។ **ឌា គល្យាណ**



# ប៊ូ ម៉េង :

## អ្នកនៅរស់ជីវិតពីមន្ទីរស-២១

### យុត្តិធម៌សម្រាប់ថ្ងៃអនាគត
### មិនមែនគ្រាន់តែសម្រាប់ជនរងគ្រោះប៉ុណ្ណោះទេ

និពន្ធដោយ ហ៊ុយ វណ្ណៈ

សរសេរបុព្វកថាដោយ សិត ម៉ៃខៀន

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ីតដេន និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 125, May 2010 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.